# សិក្សាព្រះសូត្រ

## ភាគទី ៧




រៀបរៀងដោយ

ខ្ញុំព្រះករុណា

ខ្ញុំបាទ **ប៊ុត សាវង្ស**

# ពាក្យប្រារព្ធ

សៀវភៅសិក្សាព្រះសូត្រភាគទី ៧ នេះ មាន ១០ ព្រះសូត្រ រួមមានខ្លឹមសារតាមព្រះអដ្ឋកថាផងដែរ ក្នុងបិដកលេខ ២២ ចូឡយមកវគ្គ តាមទំព័រក្នុងសៀវភៅនេះ គឺ


១- សាលេយ្យកសូត្រ ទំព័រ ២, ២- វេរញ្ជកសូត្រ ទំព័រ ៨
៣- មហាវេទល្លសូត្រ ទំព័រ ១៧, ៤- ចូឡវេទល្លសូត្រ ទំព័រ ៣០
៥- ចូឡធម្មសមាទានសូត្រ ទំព័រ ៤៣, ៦- មហាធម្មសមាទានសូត្រ ទំព័រ ៥៥
៧- វីមំសកសូត្រ ទំព័រ ៦៥, ៨- កោសម្ពិយសូត្រ ទំព័រ ៨៥
៩- ព្រហ្មនិមន្តនិកសូត្រ ទំព័រ ១០០, ១០- មារតជ្ជនីយសូត្រ ទំព័រ ១១៧


នៅចន្លោះនៃព្រះសូត្រ ខ្ញុំព្រះករុណា ខ្ញុំបាទ បានសរសេរពាក្យរំលឹក ជាពាក្យរាយខ្លះ កំណាព្យខ្លះ សមគួរតាមអធ្យាស្រ័យនៃអ្នកសរសេរនិងអ្នកអានឬស្តាប់ ។ ចំពោះកំណាព្យសូមពុទ្ធបរិស័ទកុំរង្កៀសអ្វីឡើយ ព្រោះមិនមែនជាអនាគតភ័យដូចនៅក្នុងបិដកលេខ ៤៤ ទំព័រ ២២៤ យោធាជីវវគ្គនោះទេ ក្នុងព្រះសូត្រគឺ **យេ បន តេ សុត្តន្តា កវិកតា កាវេយ្យា ចិត្តក្ខរា ចិត្តព្យញ្ជនា ពាហិរកា សាវកភាសិតា តេសុ ភញ្ញមានេសុ**... បើពួកសូត្រណា ដែលកវីតាក់តែង ជាពាក្យកាព្យ

មានអក្ខរៈដ៏វិចិត្រ មានព្យញ្ជនៈដ៏វិចិត្រ ជាពាក្យខាងក្រៅ ជាភាសិតរបស់សាវ័ក ( ខាងក្រៅ ) កាលបើសូត្រទាំងនោះ ដែលបុគ្គលកំពុងពោល ទើបប្រាថ្នាចង់ស្តាប់ ផ្ទៀងត្រចៀកប្រុងស្តាប់ ។ល។

ព្រះពុទ្ធអង្គទ្រង់សម្តែង **ពាហិរកា សាវកភាសិតា** គឺជាភាសិតរបស់ពួកសាវ័កខាងក្រៅព្រះពុទ្ធសាសនា ជាពាក្យវិបល្លាសផ្សេងៗ ដែលព្រះពុទ្ធអង្គទ្រង់មិនបានបញ្ញត្តសម្តែង ( ដីកា = **លិង្គ-វចនវិបល្លាសេន វុត្តន្តិ អាហ ។ សាសនតោ ពហិទ្ធា ឋិតាតិ ន សាសនាវចរា ។ ពាហិរកសាវកេហីតិ ពុទ្ធាទិ អប្បញ្ញាតានំ យេសំ កេសញ្ចិ សាវកេហិ** ) ។ ដូច្នេះ ពាក្យណាដែលយើងរៀនសូត្រមិនខុចធម៌ មិនខូចវិន័យ មានពាក្យកាព្យនមស្ការព្រះរតនត្រ័យ និងភាសិតរំលឹកដាស់តឿនជាដើម សុទ្ធតែគួរស្តាប់ គួររៀនទាំងអស់ ជាពិសេសគឺយើងនៅតែសិក្សាព្រះសូត្រក្នុងព្រះសុត្តន្តបិដកដដែល មិនមែនជាការបោះបង់ចោលព្រះពុទ្ធសាសនា ដូចនៅក្នុងអនាគតភ័យ ៥ យ៉ាងនោះឡើយ ។

**បាត់ដំបង, ថ្ងៃ ១៥ កើត ខែ អស្សុជ ព.ស.២៥៥៩**
**ខ្ញុំព្រះករុណា ខ្ញុំបាទ ម៉ុត សាវឡុ**

# ព្រះសុត្តន្តបិដកខ្មែរលេខ ២២

## មជ្ឈិមនិកាយ មូលបណ្ណាសក
## ចូឡយមកវគ្គ
## មាន ១០ ព្រះសូត្រ គឺ

១- សាលេយ្យកសូត្រ
២- វេរញ្ជកសូត្រ
៣- មហាវេទល្លសូត្រ
៤- ចូឡវេទល្លសូត្រ
៥- ចូឡធម្មសមាទានសូត្រ
៦- មហាធម្មសមាទានសូត្រ
៧- វីមំសកសូត្រ
៨- កោសម្ពិយសូត្រ
៩- ព្រហ្មនិមន្តនិកសូត្រ
១០- មារតជ្ជនីយសូត្រ

# ១-សាលេយ្យកសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់ស្តេចយាងទៅកាន់ទីចារិកក្នុងកោសលជនបទ ព្រមដោយភិក្ខុសង្ឃជាច្រើនព្រះអង្គ ទ្រង់គង់អាស្រ័យនៅនឹងស្រុកព្រាហ្មណ៍ឈ្មោះសាលៈ ។

គ្រានោះ ពួកព្រាហ្មណ៍និងគហបតី អ្នកស្រុកសាលគ្រាមនាំគ្នាចូលគាល់ព្រះដ៏មានព្រះភាគ ហើយបានក្រាបទូលសួរព្រះអង្គអំពីហេតុដែលនាំឲ្យសត្វទាំងឡាយពួកខ្លះក្នុងលោកនេះ ទម្លាយរាងកាយខាងមុខបន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយភូមិ ៤ និងពួកខ្លះ ទៅកើតក្នុងមនុស្ស សុគតិ សួគ៌ទេវលោក ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់អំពីកិរិយាប្រព្រឹត្តមិនស្មើ គឺមិនប្រព្រឹត្តតាមធម៌ បានដល់អកុសលកម្មបថ ១០ ហ្នឹងឯង ដែលមានអកុសលកម្មនោះជាបច្ច័យនៃបដិសន្ធិក្នុងអបាយភូមិ ៤ ចំណែកឯការប្រព្រឹត្តតាមធម៌ ជាកិរិយាប្រព្រឹត្តស្មើត្រឹមត្រូវនៅក្នុងកុសលកម្មបថ ១០ ជាបច្ច័យឲ្យបដិសន្ធិក្នុងសុគតិភព ។

សុចរិតកម្មក្នុងកម្មបថ ១០ ឲ្យបដិសន្ធិក្នុងកាមសុគតិភព

ដោយកម្មប្បច្ច័យ ក៏ជាឧបនិស្ស័យ ឲ្យសម្រេចនូវរូបជ្ឈាន អរូបជ្ឈាន និងឲ្យសម្រេចនូវលោកុត្តរ រហូតដល់អស់នូវអាសវក្កិលេស ទៅតាមការអប់រំចម្រើន ។

ពួកអ្នកស្រុកក្នុងសាលគ្រាម ពោលសរសើរព្រះធម៌ទេសនា និងសូមដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាសរណៈ រហូតអស់ជីវិត ចាប់តាំងអំពីថ្ងៃនេះតទៅ ។

សូមអនុមោទនា !

## ពាក្យរំលឹកចំពោះសេចក្តីស្រឡាញ់

យល់សប្តិល្អ ហើយបានយូរយ៉ាងណាក៏ដោយ ក៏គង់ភ្ញាក់យ៉ាងណាមិញ សេចក្តីស្រឡាញ់ចំពោះអ្វីៗ ក្រៃលែងណាស់យ៉ាងណាក៏ដោយ ចុងក្រោយគឺត្រូវតែព្រាត់ចាកនូវអ្វីៗនោះ ។

មិនខាតពេលព្រោះសេចក្តីស្រឡាញ់ គឺស្រឡាញ់សេចក្តីល្អ។

នឹកឃើញដល់ការស្រឡាញ់សេចក្តីល្អ ក៏នឹកឃើញដល់បុគ្គលសំខាន់ៗ ដូចជាព្រះសម្មាសម្ពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអគ្គសាវ័ក

ព្រះអគ្គសាវិកា ព្រះពុទ្ធមាតា ព្រះពុទ្ធបិតាជាដើម ទាំងនេះគឺជាលទ្ធផលនៃការស្រឡាញ់សេចក្តីល្អ ជាបុគ្គលប្រសើរលើលោកគួរជ្រះថ្លា ។

ស្រឡាញ់អ្វីៗក៏ដោយ កុំភ្លេចស្រឡាញ់ខ្លួន ភ្លេចអ្វីៗបានតែកុំភ្លេចខ្លួន ចោលអ្វីៗបាន តែកុំចោលខ្លួន ខូចអ្វីៗបាន តែកុំខូចខ្លួន ព្រោះខ្លួនជាទីពឹងនៃខ្លួនឯង ដូចដែលព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងអំពីកុសលកម្មបថ ១០ ក្នុងសាលេយ្យកសូត្រ គឺជាទីពឹងសំខាន់ណាស់ ។

ទុក្ខតិចទុក្ខខ្លាំងក្នុងចិត្ត សុទ្ធតែព្រោះសេចក្តីស្រឡាញ់ដែលជាតណ្ហាឆន្ទៈជាបច្ច័យទាំងអស់ ដូច្នេះគួរអាស្រ័យសេចក្តីស្រឡាញ់ដែលជាកុសលឆន្ទៈ អប់រំសតិប្បដ្ឋាន ពិចារណាកាយ វេទនា ចិត្ត ធម៌ ឲ្យឃើញតាមសេចក្តីពិតនៃបរមត្ថ ដែលមិនមែនជាសត្វ មិនមែនជាយើង ទើបអាចលះនូវតណ្ហាឆន្ទៈដែលជាហេតុ ជាបច្ច័យនៃសេចក្តីទុក្ខបាន ។

ក្រឹត្យក្រមនៃសេចក្តីសុខក្នុងចិត្តនៃបុគ្គលម្នាក់ៗ គឺឋិតនៅ

ត្រង់ព្រមទទួលថា គ្រប់យ៉ាងក្នុងលោករមែងប្រែប្រួល ។

កើតទុក្ខព្រោះស្រឡាញ់ចង់បានរបស់ដែលអត់ គួរសិក្សា ចំពោះសេចក្តីទុក្ខហ្នឹងឯង ដែលកើតឡើងជាតួធម៌ មិនមែនជាខ្លួនយើងឡើយ នេះជាសមត្ថភាពពិសេសនៃបុគ្គលអ្នកអប់រំបញ្ញា ។

ក្នុងជីវិតរាល់ថ្ងៃ អ្វីៗទាំងអស់សុទ្ធតែជាធម្មា ស្មើគ្នាជាអនត្តា បញ្ញាបានដឹងហើយ ក៏ស្ងប់នូវការហួងហែង មិនចាប់យកហើយក៏មិនប្រទូស្ត មានតែការសិក្សាអប់រំប៉ុណ្ណោះ ។

រវល់តែចង់បានរបស់ដែលអត់ រហូតភ្លាត់ប្លាតខាតខានមិនបានសុខ ជាមួយនឹងរបស់ដែលមាននៅជុំវិញខ្លួន ទាំងដែលមិនបានសិក្សានូវការពិត ។

មិនចាំបាច់និយាយដល់របស់ដែលអត់ សូម្បីតែរបស់ដែលមាន កំពុងប្រាកដ ក៏ត្រូវលះចោលដែរ គឺនៅត្រង់មិនចាប់ប្រកាន់ហ្នឹងឯង នេះជាតួវិបស្សនា ។

តណ្ហារកអ្វីៗឲ្យយើង ប៉ុន្តែសតិប្បដ្ឋានវិញ មិនមានយើងជា

អ្នកបានអ្វីឡើយ ។

ការចង់បានចម្រើនសតិប្បដ្ឋាន វិបស្សនា ចង់បានស្ងប់ ការចង់នេះក៏មានឧបការៈដល់ការសួរធម៌ ការស្តាប់ធម៌ហើយ ប៉ុន្តែដល់សតិប្បដ្ឋានកើតឡើង គឺរលឹកដឹងថា ធម៌កំពុងប្រាកដ ។

សតិក៏ជាតួធម៌ បញ្ញាក៏ជាតួធម៌ ស្ងប់ក៏ជាតួធម៌ ការចង់បានក៏ជាតួធម៌ ការឃើញ ឮ គិត ។ល។ គឺថាគ្រប់ព្រះអង្គ គ្រប់គ្នាសុទ្ធតែមានបរមត្ថធម៌ស្រេចទៅហើយ ឲ្យតែលក្ខណៈនៃបរមត្ថធម៌នោះៗប្រាកដមិនមែនជាខ្លួនយើង នេះឯងគឺសតិថ្នាក់សតិប្បដ្ឋានមានបញ្ញាភ្លឺស្វាង ។

មានពេលណាដែលអត់សភាវធម៌ តើចង់បានធម៌អ្វីទៀតយកមកធ្វើអ្វី យកមកឲ្យអ្នកណា ? ដូច្នេះកុំភ្លេចថា ធម៌មានហើយកំពុងតែមាន កំពុងតែប្រាកដ នេះជាភ្នែកឃើញធម៌ ហើយក៏ស្ងប់ចំណង់ដែលចង់បានសតិ ។

មានអ្វីៗឲ្យស្រឡាញ់ជាប់ជំពាក់... ព្រោះលោភៈ
មានបុគ្គលជាទីស្អប់... ព្រោះទោសៈ

មានខ្លួនយើង មានសត្វលោក... ព្រោះទិដ្ឋិ
មានតែបរមត្ថមិនមែនសត្វ... ព្រោះសតិប្បដ្ឋាន ។

## កំណាព្យឈ្នះបាបខ្លួនឯងសំខាន់ណាស់

មនុស្សច្រើនច្រណែននឹងយើងបានខ្ពស់ ដល់យើងធ្លាក់ចុះគេរស់សប្បាយ
មានតែម៉ែឪមិត្តល្អទាំងឡាយ ដែលតែងដោះស្រាយជួយស្រង់ទឹកចិត្ត។
មនុស្សច្រើនមិនជ្រាបរឿងឈ្នះខ្លួនឯង ទើបខំប្រជែងសម្តែងចរិត
ការឈ្នះខ្លួនឯងជារឿងជ្រៅពិត ឈ្នះដល់កម្រិតអស់ចិត្តសៅហ្មង ។
សន្តិមេត្តាវាចាធម្មទាន បាបកុំបំពានត្រូវឈានកន្លង
ធម្មសប្បាយដោះស្រាយចំណង ចេះជួយអ្នកផងគន្លងព្រះធម៌ ។
លះបាបខ្លួនឯងអស្ចារ្យប៉ុនណា មុននឹងស្តីថាអ្នកណាមិនល្អ
គួរគិតឲ្យត្រូវតាមផ្លូវព្រះធម៌ គ្មានអ្វីបវរជាងល្អខ្លួនឯង ៕

ដោយ **ច.ស.ច.**

# ២.វេរញ្ជកសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ។ ក៏សម័យនោះឯង ពួកព្រាហ្មណ៍និងគហបតី អ្នកស្រុកវេរញ្ជា នាំគ្នាចូលគាល់ព្រះដ៏មានព្រះភាគ ហើយទូលសួរព្រះអង្គដូចអ្នកស្រុកសាលគ្រាមក្នុងព្រះសូត្រទីមួយដែរ ។

សេចក្តីនៃសំណួរចម្លើយ ដូចគ្នានឹងសាលេយ្យកសូត្រដែរ គ្រាន់តែក្នុងព្រះសូត្រនេះ ព្រះអង្គទ្រង់សម្តែងជាបុគ្គលាធិដ្ឋានគឺ **អធម្មចារី វិសមចារី** បុគ្គលប្រព្រឹត្តមិនត្រូវគន្លងធម៌ ប្រព្រឹត្តមិនសមគួរ ចំណែកនៅក្នុងព្រះសូត្រទី ១ ព្រះអង្គទ្រង់សម្តែងជាធម្មាធិដ្ឋានគឺ **អធម្មចរិយា វិសមចរិយា** កិរិយាប្រព្រឹត្តមិនត្រូវគន្លងធម៌ កិរិយាប្រព្រឹត្តមិនសមគួរ ត្រឹមតែប៉ុណ្ណោះឯង ។

សូមអនុមោទនា !

# ពាក្យរំលឹកចំពោះសេចក្តីស្រឡាញ់

មនុស្សយើងដែលស្រឡាញ់គ្នា គឺយល់ចិត្តគ្នា ចេះសម្រួលចិត្តគ្នាទៅវិញទៅមក និងមើលថែគ្នា ។ កល្យាណមិត្តសំខាន់ណាស់ ប្តីប្រពន្ធល្អក៏ជាកល្យាណមិត្តនឹងគ្នាដែរ ។ មនុស្សយើងរស់នៅបានដោយសារខ្យល់អាកាសដកដង្ហើម គឺថាខ្វះខ្យល់ដកពីរបីនាទីក៏ត្រូវស្លាប់ ប៉ុន្តែយើងសឹងតែភ្លេចបច្ច័យដ៏សំខាន់មួយនេះទៅហើយយ៉ាងណាមិញ មនុស្សយើងមិនអាចរស់នៅបានដោយខ្វះការស្រឡាញ់ពីគ្នាឡើយ ដូច្នេះហើយ យើងមិនត្រូវភ្លេចសេចក្តីល្អសេចក្តីស្រឡាញ់របស់អ្នកណាមួយទេ ព្រោះនេះជាបច្ច័យដ៏សំខាន់សម្រាប់ឲ្យយើងបានរស់ គឺសំខាន់ជាងខ្យល់អាកាសសម្រាប់ដកដង្ហើមទៅទៀត ព្រោះថានេះជាតួគុណ ។ ដើម្បីជាការឆ្លើយតបដ៏ត្រឹមត្រូវ ព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងក្នុងវេរញ្ជកសូត្រនេះមានជាដើមថា ៖

**បាណាតិបាតំ បហាយ** លះបង់ការសម្លាប់សត្វ ។

**បាណាតិបាតា បដិវិរតោ ហោតិ** វៀរស្រឡះចាកបាណាតិបាត ។

**និហិតទណ្ឌោ និហិតសត្ថោ** ជាអ្នកដាក់ចុះនូវដំបង ដាក់ចុះនូវសស្ត្រាវុធ ។

**លជ្ជី** ប្រកបដោយសេចក្ដីខ្មាស ។

**ទយាបន្នោ** ដល់នូវមេត្តាចិត្ត ។

**សព្វបាណភូតហិតានុកម្បី វិហរតិ** ជាអ្នកអនុគ្រោះដោយប្រយោជន៍ ចំពោះពួកសត្វទាំងអស់ ។

បើយើងឃើញគុណតម្លៃនៃការងារ ថាការងារនោះល្អ មានប្រយោជន៍ ហើយយើងក៏សប្បាយចិត្តដែលបានរួមចំណែកក្នុងកិច្ចការនោះ ទាំងគុណតម្លៃនៃការងារនោះៗ បានធ្វើឲ្យយើងមានសេចក្ដីសុខនៅពេលដែលនឹកដល់ទៀត ដូច្នេះគឺយើងគប្បីស្រឡាញ់នូវការងារនោះឯង ឲ្យស្មើនឹងស្រឡាញ់ជីវិតរស់នៅ ។

មនុស្សទាំងឡាយដ៏ច្រើន ពោលសរសើរការងារល្អរបស់យើង មិនស្មើនឹងយើងម្នាក់ឯងដែលមានសេចក្ដីសុខក្នុងផ្លូវដ៏រាបស្មើនៃជីវិតខ្លួនឯងឡើយ ។

មនុស្សយើងគួរតែអប់រំចម្រើនបញ្ញា ឲ្យចូលទៅដល់សេចក្ដី

ពិត ទើបអស់វង្វេងលែងច្រឡំ ។ បញ្ញានេះឯងមានកម្លាំងអាចទម្លាយនូវអវិជ្ជាបាន ដូច្នេះចូរកុំទម្លាយបញ្ញារបស់ខ្លួន ដោយការធ្លាក់ចូលទៅក្នុងនីវរណធម៌ មានកាមច្ឆន្ទនីវរណៈជាដើមឡើយ ព្រោះនីវរណៈជាឧបសគ្គនៃសេចក្ដីចម្រើន ។

ជាច្រើនរឿងក្នុងលោក ដែលមនុស្សយើងខំប្រឹងរត់ប្រណាំងប្រជែងយកជ័យជម្នះ ប៉ុន្តែឱវាទរបស់ព្រះសម្មាសម្ពុទ្ធមានពាក្យមួយថា " ឈប់ " ដែលធ្វើឲ្យអង្គុលិមាលមានជ័យជម្នះ បានបួសជាព្រះអរហន្តមួយអង្គ ។

ប្រយ័ត្នការស្រឡាញ់អ្នកដទៃហើយ ក្លាយទៅជាសត្រូវស្អប់ខ្លួនឯង ព្រោះហេតុតែកិលេសក្នុងចិត្តរបស់ខ្លួន ។

ការតិះដៀលអ្នកដទៃ សូម្បីតែគេខុសពិត ប៉ុន្តែត្រូវប្រយ័ត្នចិត្តថ្នាំងថ្នាក់អាក់អន់របស់ខ្លួន ។ ការមួម៉ៅក្ដៅក្រហាយក្នុងចិត្ត ដែលគិតតែពីកំហុសអ្នកដទៃ រហូតដល់ខ្លួនឯងនៅមិនបានសុខនោះ នេះជាសេចក្ដីល្ងង់របស់សត្វលោកពិតៗ ។

មើលឯកសារសត្វ ធ្វើឲ្យយើងនឹកថា ព្រោះហេតុតែស្រឡាញ់ជីវិតខ្លួនឯង សត្វខ្លះក៏ព្រោះកូនខ្លួនឯងដែរ ចំណែកមនុស្សយើងក៏ដូចគ្នា ប៉ុន្តែមនុស្សយើងមានសេចក្តីស្រឡាញ់ ចម្រើនទៅដោយមេត្តា ដូច្នេះគួរអប់រំ ម្យ៉ាងទៀត មនុស្សយើងបានជួបព្រះធម្មរតនៈហើយ គួរសិក្សាដើម្បីរំលត់នូវសេចក្តីស្រឡាញ់ដែលជាតួលោភៈ ក៏ដើម្បីឲ្យបានរួចផុតអំពីជីវិតសត្វលោកនេះឯង ។

## កំណាព្យរឿងរ៉ាវក្នុងគំនិត

មនុស្សល្អអាក្រក់មានព្រោះគិត រឿងក្នុងគំនិតច្រើនយ៉ាងណា
ហាក់ដូចមាននៅក្នុងលោកា រឿងនេះឧបមាដូចយល់សប្តិ ។
មានអ្នកដែលគួរឲ្យស្រឡាញ់ មានអ្នកគួរក្នាញ់គួរឲ្យស្អប់
មានយើងមានគេមានទាំងទ្រព្យ មានគ្រប់មានសព្វជាសុបិន ។
ទោសៈនាំក្នាញ់កំណាញ់ស្អប់ លោភៈនាំជាប់ទ្រព្យមាសឆ្អិន
ទិដ្ឋិប្រកាន់ខ្មែរចាមចិន ល្ងង់ទេតែប៉ិនប្រសប់អួត ។
សតិប្បដ្ឋានបានរលឹក ឃើញត្រឹមចិត្តនឹកលះអំនួត
អន្លង់ទិដ្ឋិរីងខះស្ងួត បានរួចពីឆ្កួតឃើញត្រៃលក្ខណ៍។

បរមត្ថមានត្រឹមចិត្តនឹកគិត　　រឿងក្នុងគំនិតមិនមានជាក់
បញ្ញត្តិមិនមាននូវត្រៃលក្ខណ៍　　ឃើញសភាវៈដោយបញ្ញា ។
យល់សប្តិល្អណាស់ចប់ត្រឹមភ្ញាក់　　ក្រេបចន្ទត្រជាក់រសកាមា
មានអ្នកស្រឡាញ់ជុំត្រៀបត្រា　　ចប់ត្រឹមមរណាចាកចោលទៅ ។
ភ្លៀងខ្លាំងប៉ុនណាគង់តែរាំង　　មានរឿងភាន់ភាំងកេរ្តិ៍អាស្រូវ
ទុក្ខខ្លាំងគង់តែស្រាកស្រាន្តទៅ　　គ្មានរឿងអ្វីនៅមិនរសាយ ។
ខ្យល់ព្យុះមិនស្មើនឹងខ្យល់មាត់　　មិនបានផ្ទៀងផ្ទាត់ហើយបរិយាយ
ដល់ពេលស្ងប់ខ្យល់ក្តៅស្អុះកាយ　　មានរឿងសប្បាយមិនយូរយារ ។
យប់ស្ងាត់បាត់ងុយគួរកម្មដ្ឋាន　　កវីតែងបានកាព្យនិន្ទា
ក្នុងចិត្តមិនស្ងាត់ព្រោះវេរា　　យកពេលវេលាសាងសត្រូវ ។
ទឹកស្រះថ្លាយង់មើលឃើញដី　　ចិត្តមនុស្សប្រុសស្រីល្អក់ហើយជ្រៅ
ម្លប់មានមិនជ្រកស្រែកថាក្តៅ　　ក្នុងចិត្តមួម៉ៅបន្ទោសមេឃ ។
ទឹកដក់លើភ្នំហៀរធ្លាក់ជ្រោះ　　ហៀរហូរធ្លាក់ចុះចូលដល់ព្រែក
រឿងក្នុងចិត្តគិតខ្លាំងពន់ពេក　　បង្ហូរទឹកភ្នែកជាសមុទ្រ ។
ក្បូនជីវិតសត្វរសាត់ឆ្ងាយ　　រឿងរ៉ាវទាំងឡាយគួរឲ្យស្លុត
រលកជីវិតព្យុះសមុទ្រ　　គ្មានទីបំផុតវដ្តសង្សារ ។
ព្រោះហេតុចង់បានអ្វីដែលអត់　　នាំឲ្យឃ្លាតភ្លាត់ចាកសុខា
របស់មានមិនគ្រប់នឹងតណ្ហា　　រស់រងទុក្ខាចិត្តខ្លួនឯង ។

ឈើត្រូវភ្លើងឆេះទៅជាធ្យូង　　អត់បាយភ្នែករងភ្លើងអត់ផ្សេង
ដុតរោលចិត្តកាយឲ្យចំបែង　　ដុតចិត្តខ្លួនឯងភ្លើងកិលេស ។
មានតែព្រះធម៌មិត្តកល្យាណ　　សតិប្បដ្ឋានកើតចំណេះ
រឿងរ៉ាវក្នុងចិត្តច្រើនដល់ម្ល៉េះ　　តែរឿងទាំងនេះជាបញ្ញត្តិ ។
កាយវេទនាចិត្តនិងធម្មា　　រលឹកគ្រប់គ្រាមិនមែនសត្វ
ទោះជាសតិក៏បរមត្ថ　　បញ្ញាលះកាត់ក្តីកង្វល់ ។
នមោ តស្ស នមស្ការ　　ត្រៃរត្នអស្ចារ្យខ្ញុំសូមដល់
ព្រះពុទ្ធព្រះធម៌សង្ឃនិមល　　ប្រាថ្នាមគ្គផលដល់និព្វាន ៕

ដោយ **ប.ស.ថ.**

# **ត្រូវប្រយ័ត្ន ៤ រឿង**

១- ប្រយ័ត្នស្រឡាញ់គេ ទៅជាការបៀតបៀនខ្លួនឯង ។
២- ប្រយ័ត្នស្អប់គេ ទៅជាការប្រទូស្តនឹងខ្លួនឯង ។
៣- ប្រយ័ត្នវង្វេងនឹងខ្លួនឯង ទៅជាទាស់នឹងការពិត ។
៤- ប្រយ័ត្នខ្លាចអតីត ដល់ថ្នាក់ក្តៅក្រហាយចិត្ត ។

## ត្រូវប្រយ័ត្នត្រចៀក ២ រឿង

១- ស្រឡាញ់ទុកចិត្តគេ ព្រោះពាក្យលួងលោម ។

២- បែកបាក់គ្នាឯង ព្រោះសម្ដីអ្នកដទៃ ។

## ត្រូវប្រយ័ត្នចំណុចខ្សោយរៀងខ្លួន

ចំណុចខ្សោយស្ត្រីនៅលើសម្ដីបុរស ចំណុចខ្សោយបុរសនៅលើសម្រស់នារី ។

## មិនថោកតាមគេថា

អ្នកដទៃមើលងាយ មើលថោកយើងបាន ព្រោះចិត្តគេ មាត់គេ ក្រសែភ្នែកគេ ប៉ុន្ដែបន្ថោកយើង ឬបញ្ចុះគុណតម្លៃយើងមិនបានឡើយ ។ សេចក្ដីល្អរបស់យើង មិនមែននៅលើក្រសែភ្នែកនៃអ្នកដទៃទេ យើងកុំយកក្រសែភ្នែកអ្នកដទៃមកវាស់សេចក្ដីល្អរបស់

យើង ព្រោះសេចក្ដីល្អនៅត្រង់អំពើល្អរបស់យើង កុំតែយើងមើលថោកខ្លួនឯងទៅបានហើយ ។

## សិក្សាការពិត

ក្នុងលោកនេះ វាមិនមានអ្នកណាចេះតែបាននូវរបស់ជាទីពេញចិត្តគ្រប់យ៉ាងនោះទេ គ្រប់គ្នាតែងចាស់ឈឺស្លាប់ និងអកុសលវិបាកផ្សេងៗ ម្យ៉ាងលោភៈមិនចេះគ្រប់ ម្យ៉ាងទៀតទោសៈប្រទូស្តទាស់ ។ល។ ប៉ុន្តែពុទ្ធបរិស័ទត្រូវសិក្សាថា អ្វីៗនោះដែលល្អឬអាក្រក់ យើងពេញចិត្តឬទាស់ចិត្ត គឺសុទ្ធតែជាការពិត ដូច្នេះអាត្មាអញត្រូវអប់រំបញ្ញាទទួលការពិត ហើយរស់នៅជាមួយនឹងការពិតនោះ ដោយចិត្តស្ងប់ ។ របស់ក្នុងលោក មិនអាចឲ្យអ្នកណាបានគ្រប់គ្រាន់នោះឡើយ ប៉ុន្តែជីវិតដែលប្រកបដោយបញ្ញា ជាជីវិតគ្រប់គ្រាន់ ។

# ៣.មហាវេទល្លសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅវត្តជេតពន ។ គ្រានោះឯង ព្រះមហាកោដ្ឋិកៈដ៏មានអាយុ ចេញអំពីផលសមាបត្តិក្នុងសាយណ្ហសម័យ ហើយចូលទៅរកព្រះសារីបុត្តដ៏មានអាយុ ដើម្បីសាកសួរនូវបញ្ហា ជាបញ្ហាដ៏មានរបៀប មានជម្រៅ និងនាំឲ្យមានសេចក្តីរីករាយស្រស់ថ្លា ។

ព្រះមហាកោដ្ឋិកៈ ជាឯតទគ្គៈលើភិក្ខុទាំងឡាយ ក្នុងការបានសម្រេចនូវបដិសម្ភិទា ៤ ព្រោះហេតុនៃបញ្ញាក្នុងបដិសម្ភិទារបស់លោក ទើបអាចតាំងឡើងបាននូវបញ្ហា ហើយអាចវិនិច្ឆ័យបានទៀតផង ។ នៅពេលព្រះមហាថេរគង់ក្នុងទីសម្រាក បានតាំងបញ្ហាគ្រប់ចំណុចគឺមាន ៣២ ចំណុចហើយបានវិនិច្ឆ័យដោយអង្គឯង ធ្វើព្រះសូត្រនេះឲ្យដល់ទីបំផុតរួចហើយស្រេច ទើបគិតថា ព្រះធម៌-ទេសនានេះល្អក្រៃលែងណាស់ ចាំយើងនឹងផ្ទៀងផ្ទាត់ជាមួយនឹងព្រះធម្មសេនាបតីបងប្រុសយើង ដល់តទៅមុខ ព្រះធម៌ទេសនាដែលយើងទាំងពីរអង្គមានមតិដូចគ្នា មានអធ្យាស្រ័យដូចគ្នា បាន

តាំងទុកហើយ នឹងទៅជាព្រះធម៌ទេសនាដែលមានឧបការច្រើនមាំទាំ ដូចជាទូកដែលចតនៅនឹងកំពង់ សម្រាប់អ្នកត្រូវការឆ្លងអន្លង់ទាំង ៤ និងដូចជារថដែលទឹមដោយសេះអាជានេយ្យមួយពាន់សេះ សម្រាប់អ្នកត្រូវការទៅទេវលោក ។

ក្នុងបញ្ហាសាកសួរទាំង ៣២ ចំណុចគឺ

១- បុគ្គលមិនមានបញ្ញា

២- បុគ្គលអ្នកមានបញ្ញា

៣- ធម្មជាតិដែលហៅថាវិញ្ញាណ

៤- បញ្ញានិងវិញ្ញាណដូចគ្នាឬផ្សេងគ្នា

៥- បញ្ញានិងវិញ្ញាណប្លែកគ្នាត្រង់ណា

៦- ហៅថាវេទនាដោយហេតុដូចម្តេច

៧- ហៅថាសញ្ញាដោយហេតុដូចម្តេច

៨- វេទនា សញ្ញា វិញ្ញាណ ច្រឡំគ្នាឬអត់

៩- ធម្មជាតិដឹងដោយមនោវិញ្ញាណដ៏បរិសុទ្ធ

១០- ធម៌ដែលគប្បីដឹងដោយបញ្ញាចក្ខុ

១១- ប្រាជ្ញាមានសេចក្តីថាដូចម្តេច

១២- បច្ច័យនៃសម្មាទិដ្ឋិ ២ យ៉ាង

១៣- សម្មាទិដ្ឋិទំនុកបម្រុងដល់ចេតោវិមុត្តិនិងបញ្ញាវិមុត្តិ

១៤- ភពមានប៉ុន្មាន

១៥- ការកើតក្នុងភពថ្មីទៀត ព្រោះហេតុដូចម្តេច

១៦- ការមិនកើតក្នុងភពថ្មីទៀត ព្រោះហេតុដូចម្តេច

១៧- បឋមជ្ឈានដូចម្តេច

១៨- បឋមជ្ឈានមានអង្គប៉ុន្មាន

១៩- បឋមជ្ឈានលះអង្គប៉ុន្មាន

២០- ឥន្ទ្រិយ ៥ មានភ្នែកជាដើមមានអ្វីជាទីពឹង

២១- ឥន្ទ្រិយ ៥ មានភ្នែកជាដើមតាំងនៅបានព្រោះអ្វី

២២- អាយុតាំងនៅបានព្រោះអាស្រ័យអ្វី

២៣- ឧស្មាគឺចំហាយភ្លើងធាតុតាំងនៅបានព្រោះអ្វី

២៤- ឧស្មានិងអាយុអាស្រ័យគ្នាដូចអណ្តាតភ្លើងនិងពន្លឺ

២៥- អាយុសង្ខារនិងវេទនីយធម៌ផ្សេងគ្នា

២៦- ធម៌បីប្រការលះបង់រាងកាយ

២៧- អ្នកស្លាប់និងអ្នកចូលនិរោធប្លែកគ្នាដូចម្តេច

២៨- អរូបសមាបត្តិទី ៤ មុនចូលនិរោធសមាបត្តិ

២៩- ផលសមាបត្តិនៅពេលចេញពីនិរោធ

៣០- នៅក្នុងផលសមាបត្តិបានយូរព្រោះបច្ច័យបីយ៉ាង

៣១- បច្ច័យពីរយ៉ាងក្នុងការចេញពីផលសមាបត្តិ

៣២- វិមុត្តិ ៤ យ៉ាងផ្សេងគ្នាឬដូចគ្នា

វិមុត្តិ ៤ យ៉ាងគឺអប្បមាណាចេតោវិមុត្តិ ១ អាកិញ្ចញ្ញា-ចេតោវិមុត្តិ ១ សុញ្ញតាចេតោវិមុត្តិ ១ និងអនិមិត្តាចេតោវិមុត្តិ ១ ។ វិមុត្តិទាំង ៤ នេះផ្សេងគ្នាទាំងព្យញ្ជនៈ ទាំងអត្ថក៏មាន ផ្សេងគ្នាតែព្យញ្ជនៈ ចំណែកអត្ថដូចគ្នាក៏មាន ។

វិមុត្តិទាំង ៤ ផ្សេងគ្នាដោយអត្ថគឺ ចេតោវិមុត្តិទី ១ បានដល់ព្រហ្មវិហារធម៌ថ្នាក់រូបាវចរជ្ឈាន មានសត្វជាអារម្មណ៍ ចេតោវិមុត្តិទី ២ បានដល់អរូបជ្ឈានទី ៣ មាន នត្ថិ ភាវប្បញ្ញត្តិជាអារម្មណ៍ ចេតោវិមុត្តិទី ៣ បានដល់វិបស្សនាមហាកុសល មហាកិរិយា ជាកាមាវចរភូមិ មានសង្ខារធម៌ជាអារម្មណ៍ ចំណែកចេតោវិមុត្តិទី ៤ បានដល់អរហត្តផលសមាបត្តិ ជាលោកុត្តរភូមិ មានព្រះនិព្វានជាអារម្មណ៍ ។ ដូច្នេះវិមុត្តិទាំង ៤ ដែលជាចេតោវិមុត្តិនេះ ផ្សេងគ្នា

ដោយភូមិ ទាំងផ្សេងដោយអារម្មណ៍ ។ ចំណែកមានអត្ថដូចគ្នា ព្រោះសំដៅយកមគ្គ ៤ ផល ៤ ដែលមានព្រះនិព្វានជាអារម្មណ៍ ។ មគ្គ ៤ ផល ៤ ឈ្មោះថា អប្បមាណាចេតោវិមុត្តិ ព្រោះមិនមានកិលេសធ្វើនូវប្រមាណ ឈ្មោះថា អាកិញ្ចញ្ញាចេតោវិមុត្តិ ព្រោះមិនមានកិលេសជាគ្រឿងកង្វល់ ឈ្មោះថា សុញ្ញតាចេតោវិមុត្តិ ព្រោះសូន្យចាកកិលេស ឈ្មោះថា អនិមិត្តាចេតោវិមុត្តិ ព្រោះមិនមានកិលេសធ្វើនូវនិមិត្តជាគ្រឿងសម្គាល់ ។ ដូច្នេះមគ្គ ៤ ផល ៤ ជាលោកុត្តរ ផ្សេងគ្នាតែឈ្មោះប៉ុណ្ណោះ ព្រោះពាក្យថា មិនមានប្រមាណ មិនមានកង្វល់ មានសភាពសូន្យ និងមិនមាននិមិត្ត សុទ្ធតែជាឈ្មោះនៃព្រះនិព្វានទាំងអស់ ។

សូមអនុមោទនា !

# ពាក្យរំលឹកនឹកគុណព្រះមហាថេរ

នឹកជ្រះថ្លាចំពោះគុណនៃព្រះមហាថេរធំៗ ទាំងនោះណាស់ ទាំងគុណស្ងប់ត្រជាក់ ទាំងគុណចាក់ធ្លុះនូវអត្ថនៃធម៌ ។ ការប្រណាំងប្រជែងគ្នា ការមួលបង្កាច់គ្នាជាដើមក្នុងលោកនេះ នៅទីបំផុត គ្រប់

គ្នាក៏ដឹងខ្លួនថា ដូចដណ្ដើមគ្នាចូលទៅក្នុងគំនរភ្លើងដូច្នោះឯង គឺមានតែការក្ដៅក្រហាយ ក្រវល់ក្រវាយប៉ុណ្ណោះ ។ មហាសេដ្ឋីបរិភោគទឹកនឹងផ្ដិលមាស ជាមួយគ្នានោះ អ្នកក្របរិភោគទឹកនឹងត្រឡោកដូង កាលបើពេញចិត្តហើយ គឺរមែងមានសេចក្ដីសុខដូចគ្នា នេះជាការអះអាងបញ្ជាក់អំពីសេចក្ដីសុខនៅលើចិត្តជាសំខាន់ ។ ជីវិតដែលបានសម្រេចជោគជ័យ មិនមែននៅត្រង់បានអ្វីធំដុំក្នុងលោកនេះទេ វានៅត្រង់ដែលថា អ្នកនោះមានសេចក្ដីដឹងខ្លួនឯងថាជីវិតរបស់ខ្លួនមានសេចក្ដីសុខ ស្ងប់ត្រជាក់ ប្រាសចាកសេចក្ដីក្ដៅក្រហាយក្នុងអារម្មណ៍អតីតកាល និងប្រាសចាកការភ័យខ្លាចចំពោះអនាគតារម្មណ៍ ។

## កំណាព្យនមស្ការព្រះមហាថេរ

ខ្ញុំសូមនមស្ការមហាថេរៈ មហាកោដ្ឋិកៈគួរជ្រះថ្លា
បដិសម្ភិទាជាបញ្ញា ចាក់ធ្លុះអត្ថានិងធម្មា ។
និរុត្តិបដិភាណមានគ្រប់បួន ចងធម៌ជាក្បួនបែបសន្ធនា
រួចរាល់ស្រេចបាច់ទើបម្ចីម្នា ចូលមករកគ្នាជាសំអាង ។

ព្រះសារីបុត្តមេទ័ពធម៌ បញ្ញាបវរល្អគ្រប់យ៉ាង
គង់នៅទីណាជាតំណាង ដូចព្រះពុទ្ធយាងទៅទីនោះ។
បកស្រាយក្នុងមហាវេទល្លសូត្រ ធម៌ជ្រៅរហូតធម៌ចាក់ធ្លុះ
នាំអ្នកប្រតិបត្តិឲ្យបានលុះ មគ្គផលទុំជ្រុះរុះចាកទុក្ខ ។
ខ្ញុំនឹកគុណព្រះមហាសាវ័ក ឯតទគ្គៈអ្នកនាំមុខ
បារមីនាំឲ្យផុតចាកគុក ផុតចាកទោសទុក្ខវដ្តសង្សារ។
ចិត្តខ្ញុំជ្រះថ្លាក្នុងមហាគុណ យកបុណ្យជាទុនតាំងសច្ចា
រួមគ្នាលើកទង់ព្រះសាសនា បញ្ញាចាស់ក្លានិព្វានហោង៕

ដោយ **ម.ស.វ.**

## រៀនអត់ រៀនធន់

បើខ្វះខាតសេចក្តីអត់ធន់ហើយ គុណធម៌ដទៃៗ ព្រមទាំងសេចក្តីសុខ រមែងមិនចម្រើនឡើងឡើយ មានតែត្រូវបាត់បង់ដោយពិត ។ ជាពិសេស ត្រូវរៀនអត់ចំពោះអារម្មណ៍ដែលនាំឲ្យកើតរាគៈ និងរៀនធន់ចំពោះអារម្មណ៍ដែលនាំឲ្យក្រោធ ។

# កំណាព្យរៀនអត់រៀនធន់

រៀនអត់ជាមួយនឹងអារម្មណ៍ ដែលនាំរាគៈធ្លាក់ជោកជាំ
រៀនធន់ជាមួយនឹងអារម្មណ៍ ដែលនាំឲ្យក្រោធឆោតឆៅឆាវ។
អត់ធន់ទន់ចិត្តត្បិតគុណធម៌ បញ្ញាមុតល្អប្រៀបដូចដាវ
រស់នៅសុខស្ងប់ចប់រឿងរ៉ាវ ខន្តីកាន់ដាវកម្ចាត់ទោស ។
សីលប្រាំប្រចាំល្អអស្ចារ្យ ល្អគ្រប់សិក្ខាស្ពានកំហុស
ជំនួញជួញដូរមិនមានខុស រស់នៅរួចទោសរួចវេរា ។
ឧបោសថសីលរំកិលឆ្ងាយ ចាកកាមទាំងឡាយវិសុទ្ធា
ស្តាប់ធម៌ទេស្នាសាសន្ទនា សព្វេ ធម្មា អនត្តា ។
រៀនអត់រៀនធន់ធ្ងន់ដូចភ្នំ បង្គំពុទ្ធមន្តទន់ចិន្តា
រាត្រីត្រជាក់ចន្ទភ្លឺថ្លា លុះនេក្ខម្មាមហាសុខហោង ៕

ដោយ **ប.ស.ទ.**

# មាគ៌ាសន្តិភាព

កុំមានសេចក្តីសុខ ដោយគ្រាន់តែពាក្យសរសើររបស់អ្នកដទៃ ហើយក៏កុំខូចចិត្តសោកសៅ ជាមួយនឹងពាក្យនិន្ទាជេរស្តីនៃអ្នកដទៃ

ដែរ គឺយើងត្រូវរស់នៅជាមួយនឹងការងារល្អរបស់យើង ការងារល្អទើបជាផ្លូវដើរដ៏ប្រសើរនៃជីវិត មិនមែនមាត់អ្នកដទៃទេ ។ ក្នុងដំណើរផ្លូវ ត្រូវភាវនាដោយបញ្ញាជាក់ច្បាស់ថា គ្រប់យ៉ាងគឺជាធម្មានេះជាការដើរផ្លូវទៅរកសេចក្ដីស្ងប់ មិនមានកង្វល់ ។

## ពិភពនៃសេចក្ដីស្ងប់

មនុស្សយើង ច្រើនតែសម្លឹងមើលអ្នកដទៃរំលងហួសចិត្តខ្លួនឯង តាមពិត បើមិនមានចិត្តគិតទេ រឿងអ្វីៗទាំងអស់ក៏មិនមានដែរ ។ កាលបើចិត្តសៅហ្មង ក៏សម្លឹងឃើញរឿងអាក្រក់ តែបើចិត្តល្អស្អាតវិញ ក៏បានមើលឃើញរឿងល្អ ។ ការដែលយើងរស់នៅក្នុងរឿងអាក្រក់ ដែលជាអារម្មណ៍មិនល្អ ក៏ដូចជាការរស់នៅក្នុងគំនរភ្នក់ភ្លើងដែរ ដូច្នេះគួរអប់រំចិត្តឲ្យបានល្អស្អាត តាមផ្លូវសតិប្បដ្ឋានយើងនឹងបានរស់នៅក្នុងពិភពនៃសេចក្ដីស្ងប់ មានតែអារម្មណ៍ល្អៗដែលជាអារម្មណ៍នៃទានសីលភាវនា ចំណែកអារម្មណ៍មិនល្អវិញចេះតែសាបរលាបទៅ ។

# ចំណេះដឹងដែលរៀនចេះពីសេចក្តីស្រឡាញ់

ដោយបរមត្ថ ចិត្តចេតសិករូបមិនមែនជាតួខ្លួន សត្វ បុគ្គល ណាឡើយ ដូច្នេះហើយពាក្យថា យើងស្រឡាញ់ខ្លួន បើមិនស្រឡាញ់ តួកុសលធម៌ទេ តើស្រឡាញ់អ្វីទៅវិញទៅ ។ កុសលធម៌ មិនមែន ជាតួខ្លួនយើងពិត ប៉ុន្តែកុសលធម៌នាំឲ្យអស់ទុក្ខ បានដល់បរមសុខ គឺអនុប្បាទនិរោធ ។ អ្នកដែលធ្វើបាបទាំងឡាយ ក៏គិតថាស្រឡាញ់ ខ្លួនឯងដែរ ប៉ុន្តែសួរថា ខ្លួនឯងដែលជាទីស្រឡាញ់នោះគឺបានដល់ អ្វី ? ជាជីវិតរូប ឬការសោយអារម្មណ៍ ឬក៏ការដឹងអារម្មណ៍...ទោះ ជាអ្វីក៏ដោយ គួរគិតថា បានជាទីពឹងឲ្យអស់ទុក្ខដែរឬទេ ។ អ្នកដែល ធ្វើអត្តឃាត ព្រោះគិតថា មិនបានការស្រឡាញ់ពីអ្នកដទៃ គំនិត នេះខុសទេ តាមពិត ព្រោះមិនបានការស្រឡាញ់ពីខ្លួនឯងឲ្យចំអ្វី ដែលត្រូវស្រឡាញ់ បើយើងស្រឡាញ់ខ្លួនឯងគឺកុសលធម៌ហើយ ទោះជាអ្នកណាមិនស្រឡាញ់យើង ឬឈប់ស្រឡាញ់យើងក៏ដោយ ក៏យើងមិនធ្វើអត្តឃាតដែរ ព្រោះខ្លួនយើងនេះឯង ជាទីពឹងនៃ ខ្លួនឯង ។ យើងចង់ឲ្យអ្នកដទៃស្រឡាញ់យើង តើចង់ឲ្យអ្នកដទៃ នោះស្រឡាញ់អ្វីទៅដែលជាយើង ? តាំងពីក្បាលចុះមកដល់ចុង

បាតជើង ពេញដោយរបស់មិនស្អាត ច្រើនដោយកិលេសទៀត តើយើងអាចជាទីពឹងឲ្យអ្នកដទៃរួចផុតចាកទុក្ខបានដែរឬទេ ? ដូច្នេះសូមឲ្យតែអ្នកដទៃនោះឯង ចេះស្រឡាញ់សេចក្តីល្អគឺកុសលធម៌ទៅបានហើយ ។ សេចក្តីស្រឡាញ់ពីខាងក្រៅជាភ្ញៀវចូលមករកជីវិតយើង គេនឹងទៅវិញ មិនមែនសម្រាប់ឲ្យយើងហួងហែងទេ ប៉ុន្តែសម្រាប់ឲ្យយើងរៀន គឺថាយើងទទួលសេចក្តីស្រឡាញ់ជាភ្ញៀវដោយសេចក្តីសុខ ព្រមដោយការចេះដឹង លុះដល់រួចកិច្ចហើយយើងក៏សប្បាយចិត្តនឹងជូនដំណើរភ្ញៀវត្រឡប់ទៅវិញដែរ ជាទីបំផុត យើងបានទទួលការចេះដឹងអំពីសេចក្តីស្រឡាញ់ដែលចូលមកបង្រៀនយើង ចំណេះដឹងនោះ **គឺការលះបង់ម្នីឯឯ** នៅសល់តែខ្លួនយើងម្នាក់ដែលយើងស្រឡាញ់មកយូរហើយ ត្រូវដើរចេញអំពីលោកនេះ ដោយមិនអាល័យ ។

## បើមិនប្រកាន់ទេក៏មិនកើតទុក្ខដែរ

យើងតែងឈឺក្បាល ឈឺភ្នែក ឈឺពោះ ឈឺដៃ ឈឺជើង ។ល។ ប៉ុន្តែយើងមិនដែលឈឺកន្ទុយទេ ព្រោះមនុស្សយើងមិន

មានកន្ទុយហ្នឹងឯង យ៉ាងណាមិញ បើយើងមិនចាប់ប្រកាន់ចំពោះអារម្មណ៍ណាហើយ អារម្មណ៍នោះក៏មិនមានឲ្យយើងកើតទុក្ខផ្លូវចិត្តដែរ ។ ការដែលមិនចាប់ប្រកាន់ទៅបាន វាទាល់តែយើងដឹងថារបស់នោះក្តៅ ដូចការមិនចាប់ភ្លើង ឬ មកអំពីយើងដឹងថារបស់នោះចាប់មិនបាន ប្រៀបដូចជាអាកាសទទេ ពុំនោះសោត មកអំពីយើងដឹងថារបស់នោះមានម្ចាស់ គឺអ្វីៗដែលកើតពីបច្ច័យ រមែងអស់ទៅសូន្យទៅជាធម្មតា ដូចការមិនប្រព្រឹត្តអទិន្នាទានដែរ ។

## ព្រមតាមការពិតទើបមិនកើតទុក្ខ

បើយើងចង់ធ្វើជាផែនដី ដើម្បីឲ្យព្រះចន្ទវិលជុំវិញខ្លួនយើង ប្រាកដជាយើងត្រូវកើតទុក្ខធំហើយ ប៉ុន្តែបើយើងដឹងថា ព្រះចន្ទវិលជុំវិញផែនដី ចំណែកយើងក៏រស់នៅលើផែនដី មានខ្មើត មានរនោចជាធម្មតា មិនប្រាថ្នាអ្វីអំពីព្រះចន្ទទៀតទេ យើងក៏គ្មានទុក្ខអ្វីជាមួយនឹងព្រះចន្ទដែរ យ៉ាងណាមិញ បើយើងចង់ឲ្យអ្វីៗចេះតែប្រព្រឹត្តទៅតាមចំណង់របស់យើង យើងនឹងត្រូវកើតទុក្ខរហូត ទៅតាមពេលដែលយើងមិនបានដូចចិត្ត ប៉ុន្តែបើយើងមិនប្រាថ្នាអ្វីអំពីលោកនេះទេ

ព្រោះយើងបានជួបជាមួយនឹងការពិតហើយ នេះឯងដែលឈ្មោះថា បុគ្គលត្រេកអរនឹងព្រះនិព្វាន រមែងរួចផុតចាកទុក្ខទាំងពួង ក៏ដូច្នោះដែរ ។

## កុំភ្លេចវិលជុំវិញខ្លួនឯង

ផែនដីវិលជុំវិញព្រះអាទិត្យ ហើយក៏វិលជុំវិញខ្លួនឯងដែរយ៉ាងណាមិញ កាលដែលយើងដឹងអារម្មណ៍ ដឹងរឿងអ្វីៗជុំវិញពិភពលោក ក៏មិនគប្បីភ្លេចពិចារណាធម៌ជាខាងក្នុងថា តើយើងឬក៏គ្រាន់តែជាចិត្តចេតសិកប៉ុណ្ណោះ ដែលដឹងនូវអារម្មណ៍ ដឹងរឿងនោះៗ ម្យ៉ាងទៀត កាលដែលយើងស្រឡាញ់អ្វីៗជាខាងក្រៅដោយសព្វគ្រប់ ក៏កុំភ្លេចស្រឡាញ់ខ្លួនឯងគឺកុសលធម៌ជាខាងក្នុង ព្រោះមានតែកុសលធម៌នេះឯង ដែលជាទីពឹងធ្វើឲ្យយើងរួចផុតអំពីរឿងអាក្រក់គ្រប់យ៉ាង ធ្វើឲ្យមានតែអារម្មណ៍ល្អៗ រហូតដល់មានព្រះនិព្វានជាអារម្មណ៍នៃផលសមាបត្តិ តាំងនៅក្នុងលោកុត្តរសុខទៀតផង ។

# ៤. ចូឡវេទល្លសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅនាវត្តវេឡុវ័ន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង វិសាខឧបាសក បានចូលទៅរកធម្មទិន្នាភិក្ខុនី ដើម្បីសាកសួរបញ្ហាធម៌ ។ បញ្ហាសាកសួរមាន ៣៤ ចំណុចគឺ

១- សក្កាយៈ បានដល់ឧបាទានក្ខន្ធ ៥ ។

២- ហេតុដែលនាំឲ្យកើតសក្កាយៈ គឺតណ្ហា ។

៣- ការរលត់សក្កាយៈ គឺការរលត់តណ្ហា រលត់ទុក្ខ ។

៤- បដិបទាជាដំណើររំលត់សក្កាយៈគឺមគ្គមានអង្គ ៨ ។

៥- ឧបាទាន គឺជាឧបាទានក្ខន្ធ ឬផ្សេងគ្នា ។

៦- តើសក្កាយទិដ្ឋិដូចម្តេច ។

៧- ដែលហៅថាមិនមានសក្កាយទិដ្ឋិតើដូចម្តេច ។

៨- មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរតើដូចម្តេច ។

៩- អដ្ឋង្គិកមគ្គដ៏ប្រសើរនោះ ជាសង្ខតៈ ឬអសង្ខតៈ ។

១០- អដ្ឋង្គិកមគ្គដ៏ប្រសើរសង្គ្រោះក្នុងខន្ធ ៣ ។

១១- សមាធិ  សមាធិនិមិត្ត  សមាធិបរិក្ខារ  សមាធិភាវនា ។

១២- សង្ខារ ៣ មានកាយសង្ខារជាដើម ។

១៣- កាយសង្ខារ  វចីសង្ខារ  ចិត្តសង្ខារតើដូចម្តេច ។

១៤- ដូចម្តេចបានជាហៅធម៌ទាំងនោះថាជាសង្ខារ ។

១៥- សញ្ញាវេទយិតនិរោធ តើដូចម្តេច ។

១៦- ចូលនិរោធសមាបត្តិ  តើសង្ខារណារលត់មុន ។

១៧- ការចេញពីនិរោធសមាបត្តិ  តើដូចម្តេច ។

១៨- ការចេញពីនិរោធសមាបត្តិ  សង្ខារណាកើតមុន ។

១៩- ចេញពីនិរោធមក  តើផស្សៈប៉ុន្មានពាល់ត្រូវ ។

២០- ចេញពីនិរោធមកចិត្តបង្អោនទៅរកវិវេក ។

២១- វេទនាមានប៉ុន្មាន ។

២២- តើវេទនាទាំង ៣ សោយអារម្មណ៍ដូចម្តេចខ្លះ ។

២៣- តើវេទនាទាំង ៣ មានអ្វីជាសុខ  មានអ្វីជាទុក្ខ ។

២៤-  តើអនុស័យអ្វី ដែលដេកសំងំក្នុងវេទនានីមួយៗ ។

២៥- តើអនុស័យនីមួយៗ សុទ្ធតែដេកសំងំក្នុងវេទនានោះឬ ។

២៦- តើអនុស័យអ្វី ត្រូវលះដោយវេទនាអ្វី ។

២៧- តើអនុស័យនោះៗ សុទ្ធតែត្រូវលះដោយវេទនានោះៗឬ ។

២៨- សុខវេទនា មានរាគៈជាគ្រឿងប្រៀបផ្ទៀប ។

២៩- ទុក្ខវេទនា មានបដិឃៈជាគ្រឿងប្រៀបផ្ទៀប ។

៣០- អទុក្ខមសុខវេទនា មានអវិជ្ជាជាគ្រឿងប្រៀបផ្ទៀប ។

៣១- អវិជ្ជា មានវិជ្ជាជាគ្រឿងប្រៀបផ្ទៀប ។

៣២- វិជ្ជា មានវិមុត្តិជាគ្រឿងប្រៀបផ្ទៀប ។

៣៣- វិមុត្តិ មានព្រះនិព្វានជាគ្រឿងប្រៀបផ្ទៀប ។

៣៤- ព្រះនិព្វានមានអ្វីជាគ្រឿងប្រៀបផ្ទៀប ។

កាលដែលវិសាខឧបាសក ក្រាបទូលព្រះដ៏មានព្រះភាគអំពីសំណួរចម្លើយក្នុងព្រះធម៌ទាំង ៣៤ ចំណុចនេះហើយ ទើបព្រះដ៏-មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលវិសាខៈ ធម្មទិន្នាភិក្ខុនីជាបណ្ឌិត ម្នាលវិសាខៈ ធម្មទិន្នាភិក្ខុនីជាស្ត្រីមានប្រាជ្ញាច្រើន ម្នាលវិសាខៈ បើទុកជាអ្នកត្រឡប់សួរសេចក្តីនោះ នឹងតថាគតវិញ តថាគតក៏ត្រូវព្យាករសេចក្តីនោះ ដូចសេចក្តីដែលនាងធម្មទិន្នាភិក្ខុនីព្យាករហើយ

ដូច្នោះដែរ សេចក្តីនៃប្រស្នានោះ យ៉ាងហ្នឹងហើយ អ្នកចូរចាំទុកនូវប្រស្នានោះ យ៉ាងនេះចុះ ។

សូមអនុមោទនា !

# សិក្សាចំណុចខ្លះៗនៃព្រះសូត្រ

វិសាខឧបាសក ជាស្វាមីរបស់នាងធម្មទិន្នា កាលដែលនាងនៅជាគ្រហស្ថ ។ ពេលដែលព្រះដ៏មានព្រះភាគ បានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណហើយ ទ្រង់ត្រាស់សម្តែងនូវព្រះធម្មចក្កប្បវត្តនសូត្រ ទ្រង់គង់នៅក្នុងវស្សាទី ១ នាឥសិបតនមិគទាយវ័ន ទ្រង់ណែនាំភិក្ខុ ៦០ អង្គជាព្រះអរហន្តឲ្យចេញផ្សព្វផ្សាយព្រះសាសនា ស្តេចយាងមកកាន់ឧរុវេលាសេនានិគម ណែនាំជដិលមួយពាន់នាក់ឲ្យបានបួសសម្រេចព្រះអរហត្ត ហើយទ្រង់យាងមកប្រោសព្រះបាទពិម្ពិសារ ។ លើកទីមួយ វិសាខឧបាសកបានសម្រេចសោតាបត្តិផល ជាមួយនឹងព្រះបាទពិម្ពិសារ ព្រមដោយមនុស្ស ១១ ម៉ឺននាក់ទៀត ក្រោយមក ស្តាប់ព្រះធម៌លើកទីពីរបានសម្រេចសកទាគាមិផល ក្រោយមកទៀត ស្តាប់ព្រះធម៌ទៀត ក៏បានសម្រេច

អនាគាមិផល ។ កាលដែលនាងធម្មទិន្នាបានស្តាប់រឿងលោកុត្តរធម៌ ហើយ ក៏ជ្រះថ្លាសូមការអនុញ្ញាតពីស្វាមីដើម្បីចូលកាន់ផ្នួស ។ កាល វិសាខឧបាសកអនុញ្ញាតហើយ ក៏បួសក្នុងសម្នាក់ភិក្ខុនី ក្នុងកាល នោះ វិសាខឧបាសកបានផ្តាំថា **អភិរមយ្យេ ស្វាក្ខាតោ ធម្មោតិ** ព្រះនាងម្ចាស់ចូរត្រេកអរចុះ ព្រះធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់ សម្តែងទុកល្អហើយ ។

ប្រវត្តិសង្ខេបរបស់ព្រះនាងធម្មទិន្នាក្នុងអដ្ឋកថាផ្សេងៗ គឺ ១ សែនកប្បមុន នាងកើតក្នុងព្រះនគរហង្សវត្តី ជាស្រីបម្រើក្នុងផ្ទះ អ្នកដទៃ នាងមានបញ្ញា សង្រួមក្នុងសីល បានកាត់សក់ខ្លួនឯងលក់ ដើម្បីបានទេយ្យវត្ថុថ្វាយទានដល់ព្រះសុជាតៈ ជាព្រះអគ្គសាវ័កនៃ ព្រះសម្មាសម្ពុទ្ធបទុមុត្តរៈ ដោយអានិសង្សនៃទាននោះ ម្ចាស់ផ្ទះ បានផ្សំផ្គុំនាងជាមួយនឹងកូនប្រុសគាត់ ។ ថ្ងៃមួយបានទៅវត្តជាមួយ នឹងម្តាយក្មេក កាលនោះ ព្រះសម្មាសម្ពុទ្ធបានប្រកាសតែងតាំង ភិក្ខុនីក្នុងតំណែងលើភិក្ខុនីទាំងឡាយផ្នែកខាងធម្មកថិក នាងមាន សេចក្តីជ្រះថ្លាថ្វាយមហាទានដល់ព្រះសម្មាសម្ពុទ្ធ និងព្រះភិក្ខុសង្ឃ ហើយប្រាថ្នានូវតំណែងនោះឯង ។ ក្នុងកប្បទី ៩២ មុនភទ្ទកប្បនេះ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធផុស្សៈ នាងត្រូវបានគេតែងតាំងឲ្យជា ធំក្នុងការធ្វើទាន ព្រោះនាងជាភរិយារបស់នាយឃ្លាំងនៃព្រះរាជបុត្រ

បីអង្គ ។ ក្នុងកាលនោះ ព្រះរាជបុត្របីអង្គបងប្អូននឹងគ្នាជាម្ចាស់ទ្រព្យក្នុងការថ្វាយទាន បានមកជាជដិលបងប្អូនបីនាក់ ព្រមទាំងបរិវារនៅឱរុវេលាសេនានិគមហ្នឹងឯង ក្រោយមកជ្រះថ្លានឹងព្រះសម្មាសម្ពុទ្ធសូមបួសបានជាឯហិភិក្ខុ ស្តាប់អាទិត្តបរិយាយសូត្រសម្រេចព្រះ-អរហត្តជាព្រះអរហន្តទាំង ១ ពាន់អង្គ។ ដោយព្រះរាជបុត្រទាំងបីអង្គក្នុងកាលនោះរក្សាសីល ១០ ក្នុងការថ្វាយទានដល់ព្រះ-សម្មាសម្ពុទ្ធផុស្សៈនិងភិក្ខុសង្ឃដ៏ច្រើនអង្គ ក៏បានចាត់នាយស្មៀននាយឃ្លាំង និងអ្នកថ្វាយចង្ហាន់ នាយស្មៀនបានមកជាព្រះបាទ-ពិម្ពិសារ នាយឃ្លាំងបានមកជាវិសាខឧបាសក ចំណែកអ្នកថ្វាយចង្ហាន់បានមកជាព្រះរដ្ឋបាលត្ថេរ ឯអ្នកដែលប្រទូស្តចំពោះទានក្នុងកាលនោះ បានធ្លាក់នរក ក្រោយមកបានជាប្រេតឈ្មោះថា ប្រេតជាញាតិព្រះបាទពិម្ពិសារ ។

ក្នុងភទ្ទកប្បនេះ ព្រះកស្សបទសពលបានត្រាស់ដឹងឡើង ព្រះនាងធម្មទិន្នាក្នុងកាលនោះ ជាព្រះរាជធីតាទី ៦ នៃព្រះបាទកឹកិស្តេចក្រុងពារាណសី ។ ព្រះរាជធីតានៃព្រះបាទកឹកិមាន ៧ អង្គគឺ

១- ព្រះនាងសមណី បានមកជាព្រះខេមាថេរី

២- ព្រះនាងសមណគុត្តា បានមកជាព្រះឧប្បលវណ្ណាថេរី

៣- ព្រះនាងភិក្ខុនី បានមកជាព្រះបដាចារាថេរី

៤- ព្រះនាងភិក្ខុទាសិកា បានមកជាព្រះកុណ្ឌលកេសីថេរី

៥- ព្រះនាងធម្មា បានមកជាព្រះកិសាគោតមីថេរី

៦- ព្រះនាងសុធម្មា បានមកជាព្រះធម្មទិន្នាថេរី

៧- ព្រះនាងសង្ឃទាសី បានមកជាវិសាខាឧបាសិកា ។

ព្រះរាជធីតាទាំង ៧ អង្គ ថ្វាយទាន ទំនុកបម្រុងព្រះសម្មាសម្ពុទ្ធនិងព្រះភិក្ខុសង្ឃ ទាំងការប្រព្រឹត្តនូវព្រហ្មចរិយធម៌មេថុនវិរតិអស់ ២ ម៉ឺនឆ្នាំ ។ ព្រះនាងសុធម្មា បានចុតិហើយបដិសន្ធិក្នុងឋានតាវត្តិង្ស ក្នុងជាតិចុងក្រោយ បានកើតក្នុងត្រកូលសេដ្ឋីមានសម្បត្តិស្តុកស្តម្ភ សម្បូរដោយកាមសុខគ្រប់យ៉ាង ក្នុងក្រុងរាជគ្រឹះដ៏ឧត្តម មានឈ្មោះថាធម្មទិន្នា ។ កាលដែលនាងធម្មទិន្នា ប្រកបដោយរូបសម្បត្តិនិងគុណសម្បត្តិ តាំងនៅក្នុងបឋមវ័យ ក៏បានវិសាខៈជាបុត្រសេដ្ឋីក្រុងរាជគ្រឹះផងគ្នាជាស្វាមី ទាំងពីរនាក់មានសម្បត្តិ ៨០ កោដិ រស់នៅពេញប្រៀបទៅដោយសេចក្តីសុខជាមួយគ្នា ។ កាលវិសាខឧបាសកស្តាប់ព្រះធម៌បានសម្រេចអនាគាមិផល ក៏ដល់ពេលដែលព្រះនាងធម្មទិន្នាចេញបួសហ្នឹងឯង វិសាខឧបាសកជិតដិតនឹងព្រះបាទពិម្ពិសារណាស់ បានក្រាបទូលព្រះរាជា សូមការ

អនុញ្ញាតរៀបចំផ្លូវព្រះនគរ និងសូមអង្រឹងមាស ឲ្យធម្មទិន្នាងូតទឹកក្រអូប ប្រដាប់ទៅដោយគ្រឿងប្រដាប់គ្រប់យ៉ាង អង្គុយក្នុងអង្រឹងមាស ហែហមដោយពពួកញាតិ បូជាទៅដោយផ្កាក្រអូបជាដើមទៅកាន់សម្នាក់ភិក្ខុនី ។ លុះបួសរួចហើយ ទើបវិសាខឧបាសកផ្តាំថា ព្រះនាងម្ចាស់ ចូរត្រេកអរចុះ ព្រះធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងទុកល្អហើយ ផ្តាំរួចហើយក៏ថ្វាយបង្គំលាត្រឡប់មកផ្ទះ ។

ព្រះនាងធម្មទិន្នា បាននិមន្តចេញពីក្រុងទៅគង់នៅវត្តស្រុកស្រែ ត្រឹមតែពីរបីថ្ងៃក៏បានសម្រេចព្រះអរហត្តផល រួចហើយក៏ត្រឡប់មកក្រុងវិញ ដើម្បីឲ្យពួកញាតិបានបំពេញបុណ្យ និងដើម្បីការមិនលំបាកដោយបច្ច័យដល់ភិក្ខុនីសង្ឃផង ព្រោះព្រះនាងសម្បូណ៌ទៅដោយបច្ច័យ ៤ ដែលញាតិបានបូជា ។ ចំណែកវិសាខ-ឧបាសក ជ្រាបអំពីដំណើរត្រឡប់ចូលក្រុងវិញនៃព្រះនាងធម្មទិន្នា ក៏បានទៅកាន់សម្នាក់ភិក្ខុនីជាលើកទី ២ ដើម្បីសាកសួរឲ្យដឹងមូលហេតុនៃការត្រឡប់ចូលក្រុងវិញនៃព្រះនាងធម្មទិន្នានោះឯង ។

ការដែលវិសាខឧបាសក លើកយកសក្កាយៈមកសួរ ព្រោះគិតថា បើអាត្មាអញសួរថា « ព្រះនាងម្ចាស់នៅត្រេកអរក្នុងផ្នួស ឬមិនត្រេកអរទេ » ដូច្នេះមិនមែនជាកិច្ចរបស់បណ្ឌិតដែលត្រូវសួរ

ឡើយ មានតែយើងសួរអំពីឧបាទានក្ខន្ធ ៥ វិញ យើងនឹងបានដឹងថា នាងនៅត្រេកអរក្នុងផ្នួសឬអត់ ដោយការឆ្លើយតបបញ្ហា ។

ព្រះនាងធម្មទិន្នា មិនបានបដិសេធសំណួរចោល ឬក៏តប ដោយសេចក្ដីមិនត្រេកអរថា យើងមិនដឹងកាយខ្លួនឯង ឬកាយអ្នក ដទៃអ្វីនោះទេ ទៅសួរព្រះថេរីដទៃទៅ ដូច្នេះឡើយ គឺព្រះនាងបាន ឆ្លើយយ៉ាងពីរោះចំពោះសំណួរទី ១ នេះ ពាក្យថា **សក្កាយៈ** ដែល ប្រែថា កាយរបស់ខ្លួន បានដល់ឧបាទានក្ខន្ធ ៥ ។ បុគ្គលដែលមាន បញ្ញាបានកំណត់ដឹងឧបាទានក្ខន្ធ ៥ រមែងត្រេកអរក្នុងព្រហ្មចរិយធម៌ ទាំងសាសនព្រហ្មចរិយៈ ទាំងមគ្គព្រហ្មចរិយៈ។ លាភ យស អំណាច ស្ដេចចក្រ បុណ្យស័ក្តិទេវតា មិនអាចឲ្យអស់ខ្វល់នឹងខ្លួនឯងឡើយ មានតែបញ្ញាកំណត់ដឹងនាមរូបក្នុងឧបាទានក្ខន្ធ ៥ ប៉ុណ្ណោះ ទើបជា រតនៈដ៏ត្រជាក់ ស្ងប់ដោយប្រពៃ អស់ភ័យ អស់ខ្វល់ នេះឯងដែល ជាចំណុចធ្វើឲ្យវិសាខឧបាសក ជ្រាបថាព្រះនាងធម្មទិន្នាត្រេកអរក្នុង ព្រះធម្មរតនៈហើយ ។

វិសាខឧបាសក សួរក្នុងអរិយសច្ចទាំង ៤ តាមលំដាប់ហើយ នៅគិតក្រែងថា ព្រះនាងធម្មទិន្នាឆ្លាតក្នុងការស្ដាប់ព្រះធម៌មក អាច ឆ្លើយសំណួរក្នុងសច្ចៈទាំង ៤ នេះ តាមរយៈនៃការស្ដាប់ប៉ុណ្ណោះ ដូច្នោះហើយ ដើម្បីឲ្យកាន់តែច្បាស់ ក៏បានសួរសំណួរទី ៥ ទាក់ទង

នឹងសច្ចៈទាំងពីរខាងដើម ជាធម៌អាច់កំបាំងនិងមានជម្រៅដ៏ក្រៃលែង ។ ក្នុងឧបាទានក្ខន្ធ ៥ មានរូបូបាទានក្ខន្ធជាដើម មិនមែនជាឧបាទានទេ ព្រោះឧបាទានគ្រាន់តែជាចំណែកមួយនៃសង្ខារូបាទានក្ខន្ធប៉ុណ្ណោះ គឺបានដល់លោភចេតសិក និងទិដ្ឋិចេតសិក ដូច្នេះឧបាទានក៏មិនមែនជាខន្ធវិមុត្តិ ឬខន្ធទី ៦ អ្វីទៅនោះឡើយ ម្យ៉ាងទៀតនៅក្នុងព្រះសូត្រនេះ ឧបាទានសំដៅយកតែឆន្ទរាគៈដែលត្រេកអរពេញចិត្តក្នុងឧបាទានក្ខន្ធ ៥ ប៉ុណ្ណោះ ( **បញ្ចសុ ឧបាទានក្ខន្ធេសុ ឆន្ទរាគោ តំ តត្ថ ឧបាទានន្តិ** )។

គប្បីជ្រាបក្នុងអរិយសច្ចទាំងពីរដែលជាវដ្តៈថា សេចក្តីទុក្ខមិនមែនអ្នកដទៃធ្វើឲ្យ ហើយក៏មិនមែនបុគ្គលធ្វើឲ្យខ្លួនឯងនោះដែរ សេចក្តីទុក្ខមានពិត ព្រោះឆន្ទរាគៈក្នុងឧបាទានក្ខន្ធ ៥ ជាហេតុ ។ ឆន្ទរាគៈ មិនមែនជាសត្វបុគ្គលណាទេ គ្រាន់តែជាចំណែកមួយនៃសង្ខារក្ខន្ធប៉ុណ្ណោះ ចំណែកឧបាទានក្ខន្ធ ៥ ដែលជាទុក្ខអរិយសច្ចក៏ដោយអត្ថថា អនត្តា អត់មែនជាសត្វបុគ្គលណាដែរ ។ គប្បីជ្រាបអរិយសច្ចទី ៣ ថា ការរលត់អស់មិនមានសេសសល់នូវសច្ចៈពីរខាងដើមនោះឯង គឺជានិរោធអរិយសច្ច បានដល់**អនុប្បាទនិរោធ** ត្រូវនឹងពាក្យថាវដ្តុបច្ឆេទោ កាត់ផ្តាច់នូវវដ្តៈ មិនមែនដាច់ឯងៗទេ គឺព្រោះអរិយសច្ចទី ៤ ជាតួធ្វើកិច្ចឲ្យសម្រេច ។

កាលដែលបានស្តាប់ការឆ្លើយតបបញ្ហាទី ៥ របស់ព្រះនាងធម្មទិន្នាភិក្ខុនីហើយ វិសាខឧបាសកក៏បានប្រាកដក្នុងចិត្តថា ភិក្ខុនីនេះបានសម្រេចនូវបញ្ញាចាក់ធ្លុះហើយ បានទីពឹងក្នុងព្រះសាសនា បានបញ្ញាបដិសម្ភិទា ដល់នូវភាពក្លាហានកម្ចាត់ភព ជាមហាខីណាស្រពដែលអាចដោះស្រាយបញ្ហាដែលយើងសាកសួរបាន ព្រះនាងមានបញ្ញាភ្លឺស្វាង ដូចជាប្រទីបរាប់ពាន់ដួងក្នុងវេលារាត្រី ។

ក្នុងសំណួរទី ១១ បានដល់សមាធិជាអង្គនៃលោកុត្តរមគ្គ មានសតិប្បដ្ឋាន ៤ ជាបច្ច័យ ទើបសតិប្បដ្ឋាន ៤ នេះ ឈ្មោះថា សមាធិនិមិត្ត ហើយមានសម្មប្បធាន ៤ ជាធម៌ទំនុកបម្រុង ទើបសម្មប្បធាន ៤ នេះ ឈ្មោះថា សមាធិបរិក្ខារ ។ អង្គមគ្គទាំងបីនេះសហការគ្នា ប្រៀបដូចសម្លាញ់បីនាក់បេះផ្កាចម្ប៉ា ម្នាក់ឱនខ្នងឲ្យម្នាក់ទៀតឡើងឈរលើខ្នង ហើយសម្លាញ់ម្នាក់ទៀតឈរអែបដើម្បីឲ្យអ្នកឈរលើខ្នងគេនោះតោងទប់ខ្លួនឲ្យនឹង ទើបបេះផ្កាចម្ប៉ាបានយ៉ាងណាមិញ សម្មប្បធាន ៤ ជាសម្មាវាយាមោ ប្រៀបដូចអ្នកឱនខ្នងឲ្យសម្មាសមាធិឡើងឈរ តែមិនអាចឈរនឹងខ្លួនមិនញញីញញ័រនោះឡើយ ទាល់តែដៃម្ខាងតោងទប់ខ្លួនទៅនឹងសម្លាញ់ម្នាក់ទៀតគឺសម្មាសតិ ទើបនឹងធឹងមាំមួនហើយឈោងបេះផ្កាចម្ប៉ាគឺព្រះនិព្វានដែលជាអារម្មណ៍ក្នុងពេលលោកុត្តរមគ្គនោះឯង ។ ចំណែកសមាធិ-

ភាវនាគឺចម្រើនមគ្គជាលោកុត្តរមួយខណៈដែលធ្វើសមុច្ឆេទប្បហាន-កិច្ចហ្នឹងឯង ក្នុងខណៈនោះមគ្គមានអង្គ ៨ មានសម្មាទិដ្ឋិជាដើមនិងមានសម្មាសមាធិជាគម្រប់ ៨ ។

## កំណត់ដឹងឧបាទានក្ខន្ធ ៥ សំខាន់ណាស់

មិនមែនរួចផុតចាកទុក្ខព្រោះគ្រាន់តែគេសរសើរ ហើយក៏មិនមែនមិនរួចផុតចាកទុក្ខ ព្រោះគ្រាន់តែគេនិន្ទានោះឡើយ ត្រូវរៀនរស់នៅឲ្យជាសុខជាមួយនឹងការកំណត់ដឹងសក្កាយៈគឺឧបាទានក្ខន្ធ ៥ ។

## កុំភ្លេចនឹកគុណមិត្តសម្លាញ់ដ៏ល្អ

សទ្ធាហ្នឹងឯង ដែលបបួលឲ្យយើងបំពេញគ្រប់សេចក្ដីល្អ ហើយយើងក៏បានជាមនុស្សល្អ ដល់ព្រះរតនត្រ័យជាទីពឹងទីរលឹកច្រើនទៅដោយអារម្មណ៍ល្អៗ មានសេចក្ដីសុខ ។

## ភាពពិតក្នុងរឿងមួយ

ជាការពិត ទោះជាមិនមានអ្នកណាមកស្រឡាញ់យើង ក៏យើងមិនកើតទុក្ខដែរ ឲ្យតែយើងចេះស្រឡាញ់ខ្លួនឯងឲ្យបានពិតប្រាកដ ទាំងបានដឹងថា អ្វីៗគ្រប់យ៉ាងនឹងត្រូវលះបង់ ដូចភិក្ខុនីជាមាតារបស់ព្រះកុមារកស្សបៈជាដើម ។

## ឲ្យតែនៅមានខ្យល់ចេញចូលគឺមិនទាន់ស្លាប់ទេ

មិនមានអ្នកណារស់នៅមិនបាន ដោយគ្រាន់តែគេបោះបង់ខ្លួនចោលនោះទេ ប៉ុន្តែបើខ្លួនឯងបោះបង់ខ្លួនឯងចោល ខ្លួនឯងមិនចេះស្រឡាញ់ខ្លួនឯងទេ នោះទើបដល់ថ្នាក់រស់នៅមិនបាន ។ តាមពិត បើយើងសិក្សាព្រះធម៌ មានបញ្ញាមិនត្រូវការអ្វីពីលោកនេះ រស់នៅគ្រាន់តែដើម្បីសិក្សាការពិតរបស់ជីវិត ការពិតនៃលោក ក៏ល្មមគ្រប់គ្រាន់ចំពោះសេចក្តីសុខស្ងប់ហើយ ។

# ៥-ចូឡធម្មសមាទានសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅនាព្រះមហាវិហារជេតពន ត្រាស់សម្តែងអំពីធម្មសមាទាន ៤ យ៉ាងមានដូចតទៅ

១- សុខក្នុងបច្ចុប្បន្ន ប៉ុន្តែមានវិបាកជាទុក្ខតទៅ

២- ទុក្ខក្នុងបច្ចុប្បន្ន ទាំងមានវិបាកជាទុក្ខតទៅ

៣- ទុក្ខក្នុងបច្ចុប្បន្ន ប៉ុន្តែមានវិបាកជាសុខតទៅ

៤- សុខក្នុងបច្ចុប្បន្ន ទាំងមានវិបាកជាសុខតទៅ ។

ធម្មសមាទានទី ១ គឺព្រោះយល់ខុសថាកាមទាំងឡាយមិនមានទោស ហើយក៏បរិភោគនូវកាមទាំងឡាយនោះតាមការពេញចិត្ត មានការប្រព្រឹត្តនូវកាមេសុមិច្ឆាចារជាដើម ដែលជាបច្ច័យឲ្យបដិសន្ធិក្នុងអបាយភូមិ ៤ មាននរកជាដើម ។

ធម្មសមាទានទី ២ មានការយល់ខុសហើយ ធ្វើខ្លួនឲ្យទុក្ខលំបាក ដូចជាពួកអចេលក៏ជាដើម ក៏នាំឲ្យមានវិបាកជាទុក្ខក្នុងអបាយភូមិថែមទៀតដែរ ។

ធម្មសមាទានទី ៣ មានទុក្ខក្នុងបច្ចុប្បន្នព្រោះរាគៈ ទោសៈ មោហៈខ្លាំងក្លា ប៉ុន្តែទោះបីមានសេចក្តីទុក្ខពាល់ត្រូវក្តី ទោះបីទោមនស្សហើយមានមុខទទឹកដោយទឹកភ្នែកក្តី គឺនៅតែប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌បរិសុទ្ធបាន ក្រោយអំពីអស់ជីវិតក៏បានកើតនៅក្នុងទេវលោក សុគតិភព ។

ធម្មសមាទានទី ៤ ព្រោះរាគៈ ទោសៈ និងមោហៈមិនខ្លាំងក្លា ទាំងបានឈានសុខក្នុងបច្ចុប្បន្នទៀត ទាំងបដិសន្ធិតទៅក្នុងសុគតិភពទៀត ។

លុះព្រះដ៏មានព្រះភាគសម្តែងនូវធម្មសមាទាន ៤ ប្រការចប់ហើយ ភិក្ខុអ្នកស្តាប់ទាំងនោះក៏មានចិត្តត្រេកអរ រីករាយនឹងព្រះធម៌-ទេសនារបស់ព្រះដ៏មានព្រះភាគ ។

សូមអនុមោទនា !

# សិក្សាខ្លឹមសារក្នុងធម្មសមាទាន

**ធម្មសមាទាន** គឺជាការកាន់យកតាមដែលបុគ្គលជឿថាជាធម៌ ។ ធម្មសមាទានទី ១ សំដៅយកពួកសមណព្រាហ្មណ៍ជាបរិព្វា-

ជកអ្នកបួសក្រៅព្រះពុទ្ធសាសនា ប៉ុន្តែពួកនេះចាញ់បោកកាមគុណ សម្គាល់ថាអត់ទោស ត្រេកអរជាមួយពួកនាងបរិព្វាជិកាក្មេងៗ បរិភោគទាំងវត្ថុកាមទាំងកិលេសកាម សោយសុខក្នុងបច្ចុប្បន្នដោយ មិនដឹងថាអ្វីដែលសោយតាមពិតនោះឡើយ ចេះតែប្រកាន់ថាខ្លួនឯង អ្នកសោយ អ្នកសប្បាយ ជាអ្នកបាននូវសម្ផស្សជាទីត្រេកអរ តាម ពិតដោយបរមត្ថ រូបជាធាតុមិនដឹង ឯការសោយអារម្មណ៍ ដឹងច្បាស់ នូវអារម្មណ៍ មិនមែនជាសត្វបុគ្គលណាឡើយ មានការអស់ទៅ ប៉ុន្តែ នៅមានផលវិបាកជាទុក្ខ ប្រៀបបីដូចជាការបរិភោគនូវផ្លែឈើផ្អែម តែពុល ។

ធម្មសមាទានរបស់ពួកអចេលក៏ ឃើញទោសកាមគុណ មិន បរិភោគសេពសោយឡើយ ប៉ុន្តែមានមិច្ឆាទិដ្ឋិយល់ខុសក្នុងការ លះបង់នូវកាមនោះ ដោយខិតខំធ្វើខ្លួនឲ្យលំបាកឥតប្រយោជន៍ ប្រៀបបីដូចជាការបរិភោគនូវផ្លែឈើល្វីងហើយពុលទៀត ។

ធម្មសមាទានទី ៣ និងទី ៤ បានដល់អ្នកបួសក្នុងព្រះពុទ្ធ-សាសនា គឺទី ៣ ដូចការបរិភោគថ្នាំល្វីង ប៉ុន្តែមានប្រសិទ្ធិភាព

ចំណែកទី ៤ ដូចការបរិភោគថ្នាំដែលផ្សំដោយសប្បិ ឬមធុបាយាស ទាំងមានប្រសិទ្ធិភាពឲ្យជារោគបានទៀតផង ។

បុគ្គលដែលមានរាគៈ ទោសៈ មោហៈខ្លាំងក្លា អាស្រ័យការសន្សំកម្មដែលមានអលោភៈខ្សោយ អទោសៈខ្សោយ និងអមោហៈខ្សោយ ហើយកម្មនោះឲ្យបដិសន្ធិ ជាឧបនិស្ស័យនៃចរិតមនុស្សផ្សេងៗគ្នា បណ្ឌិតគប្បីបែងចែកកុសលមូលទាំងបី ខ្លាំងឬខ្សោយឆ្លាស់គ្នា មិនមែនសុទ្ធតែខ្សោយទាំងបី ឬខ្លាំងទាំងបីព្រមគ្នានោះទេ។

## កុសលកម្ម ៨ យ៉ាងដែលបានសន្សំហើយ

១- លោភៈ អទោសៈ អមោហៈ កុសលកម្មទី ១ នោះ មានអលោភៈខ្សោយ ដែលធ្វើឲ្យបុគ្គលនោះកើតមកដោយអំណាចនៃកុសលកម្មនោះជាបច្ច័យ ជាអ្នកលោភលន់ មានរាគចរិត ប៉ុន្តែមានប្រក្រតីនៅជាសុខព្រោះមិនក្រោធ ទាំងមានបញ្ញាច្រើន ។

២- លោភៈ ទោសៈ អមោហៈ កុសលកម្មទី ២ នោះ មាន

អលោភៈ និងអទោសៈខ្សោយ ដែលធ្វើឲ្យបុគ្គលនោះកើតមកដោយអំណាចនៃកុសលកម្មនោះជាបច្ច័យ ជាអ្នកលោភលន់ផង ច្រើនទៅដោយសេចក្តីក្រោធផង ប៉ុន្តែមានបញ្ញា ។

៣- លោភៈ អទោសៈ មោហៈ កុសលកម្មទី ៣ នោះ មានអលោភៈ និងអមោហៈខ្សោយ ដែលធ្វើឲ្យបុគ្គលនោះកើតមកដោយអំណាចនៃកុសលកម្មនោះជាបច្ច័យ ជាអ្នកលោភលន់ផង ល្ងង់ផង ប៉ុន្តែមានប្រក្រតីនៅជាសុខព្រោះមិនក្រោធ ។

៤- លោភៈ ទោសៈ មោហៈ កុសលកម្មទី ៤ នោះ មានកុសលមូលខ្សោយទាំងបី គប្បីជ្រាបតាមន័យខាងដើមៗ ។

៥- អលោភៈ ទោសៈ មោហៈ កុសលកម្មទី ៥ នោះ មានអលោភៈខ្លាំង ដែលធ្វើឲ្យបុគ្គលនោះកើតមកដោយអំណាចនៃកុសលកម្មនោះជាបច្ច័យ ជាអ្នកមិនលោភលន់ មានរាគៈខ្សោយ តែជាអ្នកឆេវឆាវ ខឹងច្រើន និងល្ងង់ទៀតផង ។

៦- អលោភៈ អទោសៈ មោហៈ កុសលកម្មទី ៦ នោះ មាន អលោភៈ និងអទោសៈខ្លាំង ដែលធ្វើឲ្យបុគ្គលនោះកើតមកដោយអំណាចនៃកុសលកម្មនោះជាបច្ច័យ ជាអ្នកមិនលោភលន់ មានប្រក្រតីនៅជាសុខព្រោះមិនក្រោធ តែជាបុគ្គលល្ងង់ ។

៧- អលោភៈ ទោសៈ អមោហៈ កុសលកម្មទី ៧ នោះ មាន អលោភៈនិងអមោហៈខ្លាំង ដែលធ្វើឲ្យបុគ្គលនោះកើតមកដោយអំណាចនៃកុសលកម្មនោះជាបច្ច័យ ជាអ្នកមិនលោភលន់ហើយមានបញ្ញា តែឆេវឆាវឆាប់ខឹង ។

៨- អលោភៈ អទោសៈ អមោហៈ កុសលកម្មទី ៨ នោះ មាន កុសលមូលខ្លាំងក្លាទាំងបី ល្អជាងគេទាំងអស់ ជាកម្មប្បច្ច័យឲ្យបដិសន្ធិបានមកជាបុគ្គលមានរាគៈ ទោសៈនិងមោហៈខ្សោយ មានបដិបទាជាសុខក្នុងការប្រព្រឹត្តព្រហ្មចរិយធម៌ ។

មនុស្សយើង មានចរិតផ្សេងៗគ្នា ទៅតាមកម្មឲ្យបដិសន្ធិយ៉ាងនេះឯង ទើបអ្នកមានបញ្ញាមិនប្រកាន់ចំពោះបុគ្គលណាៗឡើយ

ព្រោះជាការពិតនៃបរមត្ថទៅតាមបច្ច័យដែលមាន ផលរមែងកើតឡើងយ៉ាងត្រឹមត្រូវ ។

ត្រូវយល់ថា បុណ្យដែលឲ្យបដិសន្ធិ មិនមានលោភៈ ទោសៈ មោហៈទេ ប៉ុន្តែនៅពេលធ្វើបុណ្យអ្វីមួយ បើពេលនោះវាមានលោភៈ ទោសៈ មោហៈច្រើន ក៏ធ្វើឲ្យបុណ្យខ្សោយ គឺអលោភៈខ្សោយ អទោសៈខ្សោយ អមោហៈខ្សោយ បុណ្យខ្សោយនោះឯងដែលឲ្យបដិសន្ធិ ។

បើពេលធ្វើបុណ្យអ្វីមួយនោះ វាមិនច្រើនទៅដោយកិលេសចូលមកច្របូកច្របល់ទេ គឺមានតែចិត្តជ្រះថ្លា តាំងពីបុព្វចេតនា មកដល់មុញ្ចនចេតនា រហូតដល់អបរចេតនា បុណ្យនោះមានកម្លាំងខ្លាំង-ក្លាដោយអលោភៈ អទោសៈ និងអមោហៈ ឲ្យបដិសន្ធិល្អណាស់ ។

## រឿងជាអារម្មណ៍របស់ចិត្ត

មនុស្សយើងតែងកើតទុក្ខមិនសុខចិត្ត ក្តៅក្រហាយនៅក្នុងរឿងផ្សេងៗ តើមានអ្នកណាដែលអត់រឿងជាអារម្មណ៍ហើយក្តៅចិត្តភ័យព្រួយ ក្រវល់ក្រវាយដូចជាត្រូវថ្នាំពិសទេ ? រឿងជាអារម្មណ៍

របស់ចិត្ត បើចិត្តកើតទុក្ខ សតិរលឹកដឹងចិត្តដែលកើតទុក្ខនោះឯង ជំនួសការចង់បានរឿងដទៃផ្សេងទៀត ព្រោះថា ចិត្តកើតទុក្ខឬទុក្ខរបស់ចិត្តជាធម៌ពិត ជាសភាវៈពិត ជាបរមត្ថមិនមែនសត្វបុគ្គលតួខ្លួនយើងឡើយ ។ មិនមែនរឿងអ្វីៗចេះតែមកបង្ខំឲ្យយើងកើតទុក្ខភ័យព្រួយសោកសៅនោះទេ ពិតមែនថាវាជាអារម្មណ៍ ប៉ុន្តែវានៅត្រង់ការធ្វើទុកក្នុងចិត្ត បើធ្វើទុកក្នុងចិត្តខុស រឿងនោះជារឿងអាក្រក់តាមចិត្តគិត បើធ្វើទុកក្នុងចិត្តត្រូវជាឧបាយនាំឲ្យកើតបញ្ញា រឿងនោះជារឿងល្អទេតើ មានអាក្រក់ដូចចិត្តល្ងង់គិតឯណា ។

## កំណាព្យមានតែព្រះធម៌ទើបជាមិត្ត

កុំតាមចិត្តចង់អន្លង់ទុក្ខ　　សច្ចៈឲ្យសុខខំសិក្សា
ចិត្តចង់នាំឆ្ងាយវដ្តសង្សារ　　បញ្ញាឃើញពិតជិតនិព្វាន ។
ដឹងថាការពិតចិត្តអស់ខ្វល់　　នេះហើយជាផលនៃធម្មទាន
មគ្គអង្គប្រាំបីជាព្រហ្មយាន　　រឿងទាំងប៉ុន្មានត្រូវបញ្ចប់ ។
រឿងត្រូវបញ្ចប់ត្រឹមសច្ចៈ　　ចិត្តឥតអួលអាក់អស់ខឹងស្អប់
សតិប្បដ្ឋានបានចិត្តស្ងប់　　បញ្ចប់តណ្ហាត្រឹមការពិត ។

កុំគិតកែរឿងកែចិត្តវិញ ចិត្តដែលម្នោម្នេញព្រោះគំនិត
រឿងជាអារម្មណ៍នៃការគិត ចិត្តល្អគឺពិតជារឿងល្អ ។
មានអ្នកឲ្យស្អប់ព្រោះទោសៈ បើជាមោហៈវង្វេងធម៌
បើជាលោភៈស្អាតហើយល្អ មានៈឡើងកស្រេចតែអញ ។
មានអ្នកស្រឡាញ់ព្រោះមេត្តា បញ្ញាលះការគិតឈ្នះចាញ់
ទានសីលភាវនាលះកំណាញ់ លះឯងលះអញលះមោហា ។
សូមរឿងល្អៗពីខ្លួនឯង សូមកុំប្រឹងស្វែងតាមតណ្ហា
បើចិត្តកើតទុក្ខត្រូវសិក្សា ចិត្តនេះហើយណាជាតួធម៌ ។
គិតចង់រកធម៌ពេលមានទុក្ខ តណ្ហានាំមុខដូចជាប់ជ័រ
ត្រូវស្តាប់ឲ្យយល់អ្វីជាធម៌ ពីកើតដល់មរណ៍ធម៌ទាំងអស់ ។
កាយយើងកាយគេសក្កាយៈ បញ្ញាឃើញជាក់ថាសូន្យសោះ
ចិត្តចេតសិករូបធម៌ទាំងអស់ មិនគួរអាឡោះអាល័យស្តាយ ។
កុំគិតតែកែអ្នកដទៃ រឿងនាំមោះមៃកុំកកាយ
គិតមើលខ្លួនឯងកិច្ចទាំងឡាយ ធ្វើការសប្បាយឆ្ងាយពីទោស ។
កុំចង់រារាំងច្បាប់ធម្មជាតិ តែត្រូវឲ្យឃ្លាតពីកំហុស
កុំចង់បានអ្វីអតីតនោះ កុំឲ្យជាប់ខ្ពោះរបស់ក្នុងលោក ។
ចូរកុំប្រមាទក្នុងជីវិត កាមគុណត្រូវគិតកុំងុយងោក
រូបកាយក្មេងចាស់សំបុករោគ កុំទុកចិត្តលោកថាមិនលាញ ។

ធម្មសមាទានមានបួនយ៉ាង ទីមួយអែបខាងសាងជំនាញ
ចំណោះលោភៈរាគៈទាញ ទីពីរជំនាញខាងទុក្ករា ។
ទីបីស្មារតីប្រព្រឹត្តធម៌ ទ្រទ្រង់បានល្អពុទ្ធសាស្នា
រាគៈទោសៈមោហៈក្លា បោកផ្ទប់យ៉ាងណាសីលមិនធ្លាយ។
ទីបួនផ្គួនបីប្រពៃគាប់ តែបួនមានភ័ព្វជាប់ពីនាយ
សុខាបដិបទារស់នៅងាយ បុណ្យល្អវេចស្លាយជាសំណាង ។
រឿងក្នុងវដ្តៈកន្លងទៅ ហួងហែងផ្សាក្តៅគ្មានទីអាង
សមុទ្ទទឹកភ្នែកបាបកម្មសាង ជាតិនេះសំណាងបានជួបព្រះ ។
មានតែព្រះធម៌ទើបជាមិត្ត ជាប់តាមជីវិតពិតជាឈ្នះ
បញ្ញាធម្មគុណបុណ្យតេជះ និព្វានស្រឡះឈ្នះទុក្ខហោង ៕

ដោយ **ម.ស.វ.**

## ស្អប់គេព្រោះចង់បានអ្វី

បើយើងខឹងស្អប់អ្នកណាៗ គួរតែគិតថាអ្នកណានោះជាសុខ ឬជាទុក្ខ តាមពិត ឲ្យតែមានបញ្ចក្ខន្ធគឺមានទុក្ខ ថែមទុក្ខព្រោះកិលេសទៀត បើដូច្នោះតើយើងចង់បានអ្វីពីអ្នកដែលមានទុក្ខដែរនោះ គេស្តី

ឲ្យយើងក៏គេមានទុក្ខរបស់គេ ទោះជាអ្នកណាៗគឺសុទ្ធតែជាអ្នកមានទុក្ខ យើងខឹងស្អប់ យើងកើតទុក្ខមិនសុខចិត្ត ព្រោះភ្លេចគិតថា គេក៏មានទុក្ខដែរ ព្រោះហេតុដូច្នេះ គួរតែនឹកដល់គុណព្រះអរិយបុគ្គល នឹកដល់គុណព្រះនិព្វានវិញ ពោលគឺកុំបណ្តោយឲ្យចិត្តទៅតាមអ្នកដែលមានកិលេសផងគ្នានោះ ត្រូវអប់រំឲ្យចិត្តទៅតាមព្រះពុទ្ធអង្គ រកសេចក្តីស្ងប់ស្ងាត់វិញ ។

## កំណាព្យរក្សាខ្លួនឯងដោយខន្តី

រក្សាខ្លួនឯងដោយខន្តី ថែអ្នកដទៃដោយមេត្តា
បើយើងខឹងស្អប់នឹងអ្នកណា គួរតែគិតថាគេក៏ទុក្ខ ។
បើគិតឃើញហើយស្បើយទុក្ខា ព្រោះមានមេត្តាជាប្រមុខ
មានតែនិព្វានបរមសុខ មិនបាច់កើតទុក្ខជាមួយគេ ។
អ្វីមកដើម្បីកន្លងទៅ សញ្ញាចាំនៅរឿងទទេ
បើមុខតែអស់មិនបិតថេរ ត្រូវគិតគ្មាន់គ្នេរចោលឲ្យហើយ ។
រៀនចោលរបស់ដែលអស់ទៅ របស់សល់នៅកុំកៀកកើយ

ឯអនាគតមិនមែនត្រើយ ការលះហ្នឹងហើយដល់ត្រើយពិត។
ព្រះពុទ្ធសាស្នាគឺជាក់ចុះ នូវទោសកំហុសបាបរួបរឹត
ឡើងកាន់ផ្លូវឈ្នះលះងងឹត ចាក់ធ្លុះការពិតនិព្វានហោង ៕

ដោយ **ប.ស.ឋ.**

## សម្បូរណ៍រឿងល្អក្នុងជីវិត

មនុស្សដែលមានសេចក្តីសុខ មិនមែនគេចេះតែបានជួបរឿងល្អៗឯងៗក្នុងជីវិតរបស់គេនោះទេ ប៉ុន្តែមកអំពីគេសិក្សាព្រះធម៌ អប់រំចម្រើនកុសលចិត្តគ្រប់មុខ ទើបធ្វើឲ្យរឿងនោះ អារម្មណ៍នោះ ល្អសម្រាប់ជីវិតរបស់គេដោយពិត ។ វាដូចជាមើមក្តួចដែលគេធ្វើឲ្យអស់ជាតិពុល ហើយបរិភោគជំនួសបាយបាន យ៉ាងណា អារម្មណ៍ពិសពុល អារម្មណ៍ក្តៅ អារម្មណ៍ជាគ្រឿងញៀន ក៏ដោយសារកិលេសកើតឡើងកាន់យកជាអារម្មណ៍ប៉ុណ្ណោះ ប៉ុន្តែវាបែរទៅជាអារម្មណ៍ល្អរបស់កុសលធម៌ អារម្មណ៍នៃសេចក្តីសុខស្ងប់របស់សមថៈ វិបស្សនា ក៏យ៉ាងនោះដែរ ។

# ៦.មហាធម្មសមាទានសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅនាព្រះមហា-វិហារជេតពន ព្រះអង្គទ្រង់ត្រាស់សម្ដែងអំពីបំណងប្រាថ្នារបស់សត្វទាំងឡាយ ។

សត្វទាំងឡាយប្រាថ្នាឲ្យអារម្មណ៍មិនល្អ គឺអារម្មណ៍មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត ឲ្យសាបសូន្យទៅ ចំណែកអារម្មណ៍ល្អៗ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត គប្បីចម្រើនឡើង ប៉ុន្តែទោះជាសត្វទាំងឡាយប្រាថ្នាដូច្នេះក៏ដោយ ក៏មិនបានសម្រេចដូចប្រាថ្នាគឺបានតែអារម្មណ៍មិនល្អ ចំណែកអារម្មណ៍ល្អៗរមែងសាបសូន្យទៅ តើព្រោះហេតុអ្វី ។

**យថាតំ អវិទ្ទសុនោ** ព្រោះបុថុជ្ជនអន្ធពាលមិនដឹងតាមពិត ក៏រមែងដូច្នោះឯង ។ បុថុជ្ជនល្ងង់ខ្លៅ មិនស្គាល់ធម៌ដែលគួរសេពគប់ ក៏មិនស្គាល់ធម៌ដែលមិនគួរសេពគប់ដែរ ព្រោះហេតុតែមិនស្គាល់ធម៌ដូច្នេះ ក៏បានសេពគប់នូវធម៌ដែលមិនគួរសេពគប់ ហើយបែរជាមិនសេពគប់នូវធម៌ដែលគួរសេពគប់ទៅវិញ ដូច្នេះទើបមិន

បានសម្រេចតាមប្រាថ្នា បានតែអារម្មណ៍មិនល្អទៅវិញហ្នឹងឯង ។

**យថាភូតំ វិទិត្វសុនោ** ព្រះអរិយសាវ័កជាអ្នកចេះដឹងតាមពិត មានសភាពផ្ទុយគ្នាអំពីបុថុជ្ជនអន្ធពាលដែលមិនដឹងតាមពិត ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងនូវធម្មសមាទាន ៤ យ៉ាង ធម្មសមាទានក្នុងព្រះសូត្រនេះ គឺព្រះអង្គទ្រង់ត្រាស់យកអកុសលកម្មបថ ១០ និងកុសលកម្មបថ ១០ មកជាធម៌ដែលគេកាន់យកជាការប្រព្រឹត្ត មានបាណាតិបាតជាដើម ។ ៤ យ៉ាងគឺ

១- ទុក្ខក្នុងបច្ចុប្បន្ន ទាំងមានទុក្ខជាវិបាកតទៅ

២- សុខក្នុងបច្ចុប្បន្ន តែមានទុក្ខជាវិបាកតទៅ

៣- ទុក្ខក្នុងបច្ចុប្បន្ន តែមានសុខជាវិបាកតទៅ

៤- សុខក្នុងបច្ចុប្បន្ន ទាំងមានសុខជាវិបាកតទៅ

**អវិជ្ជាគតោ** បុគ្គលដែលធ្លាក់នៅក្នុងអំណាចនៃអវិជ្ជារមែងមិនដឹង មិនស្គាល់នូវធម្មសមាទានទាំង ៤ នេះតាមពិតឡើយ ម្ល៉ោះហើយ ក៏បានសេពគប់នូវធម្មដែលនាំឲ្យបាននូវអារម្មណ៍មិនល្អ មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត ចំណែកអារម្មណ៍ល្អៗសាបសូន្យអស់ នេះជារឿងរបស់បុថុជ្ជនល្ងង់ខ្លៅ ( **យថាភូតំ អវិទិត្វសុនោ** ) ដែលមិនបានវៀរចាកនូវអកុសលកម្មបថ ១០ នោះ

ដូចបាលីថា **តំ អវិទ្វា អវិជ្ជាគតោ យថាភូតំ នប្បជា-នន្តោ តំ សេវតិ តំ ន បរិវជ្ជេតិ** ប្រែថា បុគ្គលមិនដឹងនូវធម្មសមាទាននោះ ជាអ្នកធ្លាក់ចូលក្នុងអំណាចនៃអវិជ្ជា រមែងមិនដឹងច្បាស់តាមសេចក្តីពិត ក៏បានសេពនូវធម្មសមាទាននោះ មិនវៀរចាកនូវធម្មសមាទាននោះឡើយ ។

**វិជ្ជាគតោ** ជាអ្នកដែលធ្លាក់ក្នុងអំណាចនៃវិជ្ជា រមែងមានការចេះដឹងនៅក្នុងធម្មសមាទាន ៤ យ៉ាងនេះ តាមសេចក្តីពិត ក៏មិនបានសេពគប់នូវធម្មសមាទានណា ដែលនាំឲ្យបាននូវអារម្មណ៍មិនល្អ គឺជាបុគ្គលវៀរចាកនូវធម្មសមាទាននោះ ដែលធ្វើឲ្យអារម្មណ៍ទាំង-ឡាយដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រមែងចម្រើនឡើង នេះជារឿងរបស់ព្រះអរិយសាវ័កអ្នកចេះដឹង ( **យថាតំ វិទ្ធ-សុនោ** ) ដែលបានវៀរចាកនូវអកុសលកម្មបថ ១០ ដូចបាលីព្រះពុទ្ធដីកាថា **តំ វិទ្វា វិជ្ជាគតោ យថាភូតំ បជានន្តោ តំ ន សេវតិ តំ បរិវជ្ជេតិ** ប្រែថា បុគ្គលដែលបានដឹងនូវធម្ម-សមាទាននោះ ជាអ្នកធ្លាក់ចូលក្នុងអំណាចនៃវិជ្ជា មានការដឹងច្បាស់តាមសេចក្តីពិត រមែងមិនសេពនូវធម្មសមាទាននោះឡើយ គឺវៀរចាកនូវធម្មសមាទាននោះឯង ។

អ្នកសិក្សាក្នុងព្រះសូត្រនេះ អាចសង្ស័យងេងងោងបាន បើមិនបានភ្ជាប់សេចក្តីអំពីខាងដើមនៃព្រះសូត្រទេនោះ ។ សេចក្តីខាងដើមគឺការដែលចេះតែបាននូវអារម្មណ៍មិនល្អ អារម្មណ៍ល្អសាបសូន្យគឺព្រោះហេតុអកុសលកម្មបថ ១០ នោះឯង ជាបន្តគឺព្រះដ៏មានព្រះ-ភាគ ទ្រង់ត្រាស់អំពីអន្ធបុថុជ្ជន ( **យថាតំ អវិទ្ធសុនោ** ) ដែលមិនដឹងនូវធម្មសមាទានទាំង ៤ រមែងសេពនូវអកុសលកម្មបថ ១០ ( **តំ សេវតិ** ) មិនវៀរនូវអកុសលកម្មបថ ១០ នោះ ( **តំ ន បរិវជ្ជេតិ** ) មិនមែនសេពនូវធម្មសមាទានទាំង ៤ មិនវៀរនូវធម្ម-សមាទានទាំង ៤ នោះៗទេ ។ ចំណែកខាងព្រះអរិយសាវ័ក ( **យថាតំ វិទ្ធសុនោ** ) ដែលបានចេះដឹងក្នុងធម្មសមាទានទាំង ៤ ហើយ រមែងមិនសេពនូវអកុសលកម្មបថ ( **តំ ន សេវតិ** ) វៀរចាកនូវអកុសលកម្មបថនោះ ( **តំ បរិវជ្ជេតិ** ) គឺមិនមែនបានសេចក្តីថា មិនសេពនូវធម្មសមាទានទាំង ៤ នោះ វៀរចាកនូវធម្មសមាទានទាំង ៤ នោះឡើយ ។

ធម្មសមាទានទី ១ គឺអកុសលកម្មបថ ១០ ដែលអ្នកប្រព្រឹត្តប្រកបដោយទុក្ខទោមនស្ស ទោះជាកាមេសុមិច្ឆា អភិជ្ឈា និងមិច្ឆា-ទិដ្ឋិ កើតនៅតែក្នុងលោភមូលចិត្ត ប៉ុន្តែកម្មបថបីនេះប្រកបដោយ

ទុក្ខទោមនស្សក្នុងបុព្វចេតនា និងអបរចេតនា នៅក្នុងធម្មសមាទាន ទី ១ នេះ ។

ធម្មសមាទានទី ២ គឺអកុសលកម្មបថ ១០ ដែលអ្នកប្រព្រឹត្ត ប្រកបដោយសុខសោមនស្ស ទោះជា បាណាតិបាត ផរុសវាចា និងព្យាបាទ ដែលកើតនៅតែក្នុងទោសមូលចិត្តក៏ដោយ ប៉ុន្តែរមែង សុខសោមនស្សក្នុងបុព្វចេតនា និងអបរចេតនា ប្រព្រឹត្តទៅនៅក្នុង ធម្មសមាទានទី ២ នេះ ។

ធម្មសមាទានទី ៣ គឺកុសលកម្មបថ ១០ ដែលជាទុក្ខ-ទោមនស្ស ដោយបុព្វចេតនា និងអបរចេតនា ។

ធម្មសមាទានទី ៤ គឺកុសលកម្មបថ ១០ ដែលប្រព្រឹត្តទៅជា សុខដោយចេតនាទាំងបីកាល ។

ធម្មសមាទានទី ១ ប្រៀបដូច ផ្លែននោងព្រៃ រសជាតិល្វីង ទាំងដែលគេយកមកលាយដោយថ្នាំពិសទៀត ធម្មសមាទានទី ២ ប្រៀបដូច ភាជន៍សំរឹទ្ធិពេញដោយទឹកផ្អែមឆ្ងាញ់ តែលាយដោយថ្នាំ ពិស ធម្មសមាទានទី ៣ ប្រៀបដូច ទឹកមូត្រស្អុយលាយដោយថ្នាំ សម្រាប់ព្យាបាលរោគស្គមលឿង ធម្មសមាទានទី ៤ ប្រៀបដូច ទឹកដោះ ទឹកឃ្មុំ និងទឹកអំពៅលាយគ្នាធ្វើថ្នាំព្យាបាលរោគធ្លាក់ ឈាម ។ ធម្មសមាទានពីរខាងដើម ក្នុងសេចក្តីប្រៀបគឺធ្វើឲ្យអ្នក

ផឹកនោះឯងមិនឆ្ងាញ់ក៏ដោយ ឆ្ងាញ់ក៏ដោយ លទ្ធផលគឺស្លាប់ដោយជាតិពិសហ្នឹងឯង ចំណែកពីរខាងចុង ទាំងមិនឆ្ងាញ់ ទាំងឆ្ងាញ់ គឺសុទ្ធតែបានជារោគនោះៗ ដោយអំណាចនៃភេសជ្ជៈព្យាបាលរោគ។

នៅខាងចុងនៃព្រះសូត្រ ព្រះបរមសាស្ដាទ្រង់ត្រាស់សម្ដែងធម្មសមាទានទី ៤ ដែលមានសេចក្ដីសុខក្នុងបច្ចុប្បន្នផង ទាំងមានសេចក្ដីសុខតទៅផង ប្រៀបដូចជាព្រះអាទិត្យរះក្នុងសរទសម័យមេឃស្រឡះក្នុងខែខាងចុងនៃវស្សានរដូវ មានរស្មីរុងរឿងត្រចះត្រចង់ ។ ធម្មសមាទានទី ៤ នេះ អាចគ្របសង្កត់នូវពាក្យផ្សេងៗរបស់ពួកសមណព្រាហ្មណ៍ដទៃក្រៅព្រះពុទ្ធសាសនាដ៏ច្រើន ដូចពាក្យថា សេចក្ដីសុខគឺទាល់តែធ្វើខ្លួនឲ្យលំបាកទើបបាន ដូច្នេះជាដើម ។ ក្នុងព្រះអដ្ឋកថា ប្រាប់ថា ព្រះសូត្រនេះ ពួកទេវតាជ្រះថ្លាពេញចិត្តដ៏ក្រៃលែង ទាំងបានលើករឿងទេវតាជាព្រះសោតាបន្នមួយអង្គ ពោលពាក្យសាធុការ អនុមោទនាក្នុងការស្វាធ្យាយនូវព្រះសូត្រនេះ នៃព្រះភិក្ខុមួយអង្គ ។

សូមអនុមោទនា !

# កំណាព្យធម្មសមាទាន ៤ យ៉ាង

ខន្ធប្រាំធ្ងន់ពិតឥតប្រយោជន៍ ត្រូវឃើញដូចខ្មោចគេបូជា
ជីវិតត្រូវដុតដោយជរា ព្យាធិគ្រាំគ្រាភ្លើងប្រចាំ ។
មុខតែនឹងស្លាប់ចាប់ជាតិថ្មី មិនគួរប្រុសស្រីធ្វើបាបកម្ម
បម្រើជីវិតចិត្តប្រេះស្រាំ រស់រងបាបកម្មចាំមរណា ។
ធ្វើបាបបានអ្វីទាំងក្តីទុក្ខ ទោះបីបានសុខរស់ហ៊ឺហា
តែការស្រេកឃ្លានគ្មានអត្តា វេទនាតណ្ហាសោយអារម្មណ៍ ។
ធ្វើបុណ្យលះបាបលះគំនុំ បាបតូចបាបធំកុំសន្សំ
លំបាកយ៉ាងណាត្រូវអត់ទ្រាំ ធ្វើបុណ្យត្រូវខំទើបសម្រេច ។
ធ្វើបុណ្យលះបាបចិត្តមនោរម្យ បារមីបន្ទុំតមិនដាច់
ស្តាប់ធម៌ទេស្នាបានសម្រេច បាបត្រូវកាត់ផ្តាច់សម្រេចធម៌ ។
ធម្មសមាទានមានបួនយ៉ាង ទីមួយត្រូវវាងពីរកុំល
ទីបីត្រូវតែតាំងជំហរ ទីបួនសាទរអបអរក្រៃ ។
ទីបួនជួនទ្រង់ត្រាស់ទេស្នា ដោយក្តីឧបមាដូចជាថ្ងៃ
សង្កត់វាទៈអ្នកដទៃ សរទសម័យថ្ងៃភ្លឺច្បាស់ ។
មនុស្សនិងទេវតាបានស្តាប់ធម៌ មានទិដ្ឋិល្អស្វាងស្រឡះ

ហាក់ដូចអណ្តែតក្នុងអាកាស ចិត្តផុតស្រឡះច្បាស់ការពិត ។
ខ្ញុំសូមបូជាផ្កាទាំងឡាយ វន្ទាដោយកាយសប្បាយចិត្ត
នមស្ការគុណត្រៃរត្នពិត សូមបាននៅជិតជួបសប្បុរស ។
សូមបានស្តាប់ធម៌បានសម្រេច សូមបានកាត់ផ្តាច់បាបទាំងអស់
ទានសីលភាវនាជាចិត្តស្មោះ សូមរំដោះគ្រោះផុតទុក្ខហោង ៕

ដោយ **ប.ស.ទ.**

# ចេះស្រឡាញ់សេចក្តីល្អ

បើមិនចេះស្រឡាញ់សេចក្តីល្អរបស់ខ្លួនឯងផង តើនឹងចេះស្រឡាញ់សេចក្តីល្អរបស់អ្នកដទៃយ៉ាងដូចម្តេចទៅ ។ បើយើងមិនចេះស្រឡាញ់សេចក្តីល្អសម្រាប់ខ្លួនទេ នៅពេលគេជេរយើង ឬគេថាយើងមិនល្អ មិនបានការយ៉ាងនេះ យ៉ាងនោះ យើងគួរតែត្រេកអរ មិនត្រូវខឹងអន់ចិត្តទេ ពីព្រោះសមនឹងយើងដែលមិនចេះស្រឡាញ់សេចក្តីល្អហ្នឹងឯង គេថាត្រូវហើយតើ ប៉ុន្តែបើយើងចេះស្រឡាញ់សេចក្តីល្អរបស់យើង យើងក៏មិនត្រូវខឹងស្អប់នឹងអ្នកដែលស្តីថាឲ្យយើងដែរ ពីព្រោះការខឹងស្អប់នោះ មិនមែនជាសេចក្តីល្អដែលយើង

ស្រឡាញ់ឡើយ បើយើងខឹងក្រោធ ថ្នាំងថ្នាក់អាក់អន់ចិត្ត បានសេចក្ដីថា យើងមិនចេះស្រឡាញ់សេចក្ដីល្អទេ ។

## រស់នៅម្នាក់ឯងប្រសើរជាង

រស់នៅម្នាក់ឯងប្រសើរជាង គឺប្រសើរជាងការមានបាបមិត្ត ប្រសើរជាងការរស់នៅជាមួយនឹងបុគ្គលពាល ក៏ដូចគ្នានឹងការបិទមាត់នៅស្ងៀម វាប្រសើរជាងការដែលមិនបានពិចារណាហើយនិន្ទាបុគ្គលដែលគួរសរសើរឬសរសើរបុគ្គលដែលគួរនិន្ទា ព្រោះការនិន្ទាឬការសរសើរនោះវាជាបាបមិត្តខាងក្នុង ឈ្មោះថារស់នៅដោយការសេពគប់នឹងបុគ្គលពាល គឺខ្លួនឯងដែលល្ងង់ខ្លៅហ្នឹងឯង ដូច្នេះទើបពោលថាការបិទមាត់នៅស្ងៀមវាប្រសើរជាង ដូចគ្នានឹងការរស់នៅម្នាក់ឯងប្រសើរជាងសេពគប់នឹងបុគ្គលពាលដូច្នោះដែរ ។

## កំណាព្យសិក្សាឲ្យចេះដឹងខុសត្រូវ

បើមិនស្រឡាញ់សេចក្ដីល្អ ដែលជាគុណធម៌ខ្លួនឯងទេ

ដូច្នោះបើមានអ្នកណាជេរ មិនគួរខឹងទេគួរត្រេកអរ ។
តែថាបើយើងស្រឡាញ់ពិត គុណធម៌ប្រណីតថ្លៃបវរ
ក៏យើងមិនត្រូវខឹងតបត ព្រោះខឹងមិនល្អមិនមែនគុណ ។
ស៊ូនៅម្នាក់ឯងប្រសើរជាង បាបមិត្តត្រូវវាងកុំសេពស៊ុន
បិទមាត់នៅស្ងៀមមិនខាតបុណ្យ ជៀលអ្នកមានគុណអស់ទុនមនុស្ស។
ពាលមើលទោសគេជាកម្លាំង ដូចខ្យល់បក់ខ្លាំងកម្លាំងព្យុះ
ប្រាជ្ញមិនសម្លឹងខឹងប្រទូស្ត កម្លាំងចាក់ធ្លុះថ្លឹងថ្លែងការណ៍ ។
សមណៈអ្នកស្ងប់អប់រំចិត្ត មានខន្តីពិតពលខ្លាំងក្លា
ពហុស្សូតរៀនចេះពិចារណា កម្លាំងបញ្ញាដឹងខុសត្រូវ ។
កុសលទាំងឡាយគួរបំពេញ ដូចទានម្ដេចមិញគួរពេកក្រូវ
ព្រោះជាប្រយោជន៍ទៅច្រើនផ្លូវ ទាំងអ្នករស់នៅទាំងអ្នកស្លាប់ ។
ចំណែកសីលវិញអភយទាន ចាំបាច់ត្រូវមានយ៉ាងចំណាប់
កុសលភាវនាត្រូវប្រញាប់ ស្រូតឲ្យបានឆាប់ដល់និព្វាន ។
និព្វានរួចផុតពីវដ្ដៈ និរោធសច្ចៈទុក្ខមិនមាន
ដឹងដោយបច្ចវេក្ខណញ្ញាណ ចូលព្រះនិព្វានផុតទុក្ខហោង ៕

ដោយ **ច.ស.ទ.**

# ៧. វីមំសកសូត្រ

ព្រះមានព្រះភាគ ទ្រង់គង់នៅព្រះជេតពនមហាវិហារ ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីភិក្ខុអ្នកពិចារណា ( វីមំសកេន ) ។ ការពិចារណាមានបីយ៉ាងគឺ

១- **អត្ថវីមំសកៈ** ពិចារណាអត្ថ ( សេចក្តីនៃធម៌ ) ។

២- **សង្ខារវីមំសកៈ** ពិចារណាសង្ខារធម៌ ( ខន្ធ ៥ ) ។

៣- **សត្ថុវីមំសកៈ** ពិចារណារកគ្រូ ( ព្រះសាស្តា ) ។

ក្នុងព្រះសូត្រនេះ សំដៅយកការពិចារណាក្នុងព្រះសាស្តាសម្មាសម្ពុទ្ធ ឲ្យឃើញសេចក្តីបរិសុទ្ធរបស់ព្រះអង្គតាមរយៈនៃការឃើញ និងតាមរយៈនៃការឮ ។ បានជាព្រះអង្គទ្រង់ត្រាស់ឲ្យពិចារណាដូច្នេះ ព្រោះដើម្បីឲ្យឃើញអំពីភាពនៃបុគ្គលដែលជាកល្យាណមិត្តត្រូវសេពគប់ ។ បុគ្គលណា គិតយ៉ាងនេះថា ព្រះតថាគតមានជាតិដ៏ខ្ពង់ខ្ពស់ ដល់ព្រមដោយរូបលក្ខណៈល្អក្រៃលែង មានកេរ្តិ៍ឈ្មោះ ល្បីសុសសាយ ជាបុគ្គលដែលគេរាប់អានដ៏សំខាន់

ណាស់ ដូច្នេះក្តី គិតថា យើងអាស្រ័យព្រះតថាគតហើយនឹងបាន នូវបច្ច័យមានចីវរប្បច្ច័យជាដើម ដូច្នេះក្តី បុគ្គលនោះ មិនត្រូវមក អាស្រ័យនឹងតថាគតទេ ។ ចំណែកបុគ្គលណាបានពិចារណាហើយ កំណត់យ៉ាងនេះថា ព្រះតថាគត អាចធ្វើនាទីជាសាស្តាឲ្យសម្រេច ដល់យើងបាន ដោយប្រការដូច្នេះ បុគ្គលនោះចូរសេពគប់នឹង តថាគតចុះ ។

នៅក្នុង **សត្តធម្មសូត្រ** នេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ សម្តែងអំពីការពិចារណាគ្រូដែលជាភិក្ខុផងដែរ ។ ពិចារណាឃើញ លោកដ៏មានអាយុអង្គនេះ បានសមាទាននូវកុសលធម៌ អស់កាលដ៏ យូរអង្វែងណាស់មកហើយ ទោះជាលោកដ៏មានអាយុអង្គនេះ មាន កិត្តិសព្ទបរិបូណ៌ មានយសបរិបូណ៌ ទោសទាំងឡាយជំពូកខ្លះក្នុង លោកនេះ នៃភិក្ខុអង្គនេះ ក៏មិនមាន ជាអ្នកមិនមានភ័យ ៤ យ៉ាង គឺ កិលេសភ័យ ១ វដ្តភ័យ ១ ទុគ្គតិភ័យ ១ និងឧបវាទភ័យ ១ ព្រោះ លោកប្រាសចាករាគៈហើយ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ឲ្យសេចក្តីសំខាន់ចំពោះការ មានកល្យាណមិត្តនេះណាស់ ព្រោះការមានកល្យាណមិត្ត ជាព្រហ្ម-ចរិយធម៌ទាំងមូល គឺឲ្យសម្រេចអរិយមគ្គអង្គ ៨ ។ ជាអង្គ ប្រកបខាងក្រៅប្រព្រឹត្តទៅដើម្បីប្រយោជន៍ដ៏ក្រៃលែង ។ ជាគុណ

ញុាំងវិមុត្តិឲ្យចាស់ក្លា ។ល។

នៅខាងចុងនៃព្រះសូត្រ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់អំពីសទ្ធាមិនកម្រើក ចាក់ឫសខ្ជាប់ខ្ជួន តម្កល់ស៊ប់ក្នុងព្រះតថាគត ជាសទ្ធាប្រកបដោយហេតុ មានសោតាបត្តិមគ្គជាមូលដ៏មាំមួន ។ ព្រះ-អដ្ឋកថាលើកអំពីសទ្ធារបស់ឧបាសកឈ្មោះសូរអម្ពដ្ឋៈ ដែលក្នុងកាលនោះ ឧបាសកទើបតែបានសម្រេចសោតាបត្តិផលថ្មីៗ មារាធិរាជបាននិម្មិតខ្លួនជាព្រះសម្មាសម្ពុទ្ធ មកដើម្បីញុាំងសទ្ធារបស់ឧបាសកឲ្យញាប់ញ័រ ហេតុនេះមិនមែនជាឋានៈអាចប្រព្រឹត្តទៅបានឡើយ ព្រោះសទ្ធារបស់ឧបាសកសូរអម្ពដ្ឋៈ មានសោតាបត្តិមគ្គជាមូលហ្នឹងឯង ។

សូមអនុមោទនា !

## កុំទាន់និយាយអ្វីៗនៅពេលខឹង

នៅពេលខឹង កុំនិយាយអ្វីឡើយ ទោះជាចង់ដាស់តឿនគេប្រដៅអ្វីគេ ឬបកស្រាយការពិតយ៉ាងណាក៏ដោយ ចាំបាត់ខឹងសិន

សឹមនិយាយ ។ បើយើងនិយាយពេលខឹងក្រោធ វាប្រៀបដូច ការយកទឹកក្តៅទៅស្រោចបន្លែ ដូច្នោះដែរ ទោះជាយើងមានបំណងឲ្យវាដុះលូតលាស់ ក៏វាប្រាកដជាងាប់ ។

## សតិរលឹកដឹងការខឹងក្រោធ

សេចក្តីក្រោធ ក៏ជាសភាវៈពិត ជាបរមត្ថដែលកើតអំពីបច្ច័យគួរដល់សតិរលឹកសិក្សា ។ ឲ្យតែបានដឹងសភាវធម៌ ជាប្រក្រតី ទោះជាសភាវៈមានលក្ខណៈជាអ្វីក៏ដោយ ទីបំផុតកង្វល់នឹងខ្លួនយើងក៏ត្រូវបាត់អស់ ។

## កុំឱបសេចក្តីទុក្ខ

គ្រប់យ៉ាងសំខាន់នៅត្រង់ការគិតរបស់យើង មិនមែននៅត្រង់រឿងនោះទេ ។ រឿងអតីតកាល វានៅត្រង់ **អតីតា ធម្មា** គឺចិត្ត

ចេតសិករូបដែលកន្លងទៅ បើយើងគិតយល់ថា អតីតកាល ទាំងដែលជាសភាវៈពិតត្រឹមត្រូវមួយរយភាគរយ ទាំងការកន្លងទៅក៏ពិតត្រឹមត្រូវតាមលក្ខណៈរបស់សង្ខារទៀត ដូច្នេះ វាមិនមានអ្វីដែលឲ្យយើងកើតទុក្ខមិនសុខចិត្ត ក្តៅក្រហាយស្តាយក្រោយ ឬអាឡោះ-អាល័យនោះឡើយ ហើយសេចក្តីទុក្ខក៏រសាត់ចេញពីដើមទ្រូងយើងទៅដែរ ។

## ត្រៀមរស់នៅជាមួយនឹងអនាគត

ព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងនូវសម្បរាយិកត្ថ គឺប្រយោជន៍ក្នុងលោកខាងមុខ បានដល់ សទ្ធា សីល ចាគៈ និងបញ្ញា ទាំងនៅក្នុងធម្មសមាទានសូត្រក៏ដូចគ្នា ដូច្នេះយើងត្រូវត្រៀមរស់នៅជាមួយនឹងអនាគតឲ្យបានល្អ ។ ជីវិតយើងមិនមែនត្រឡប់ទៅរស់នៅក្នុងអតីតកាលវិញទេ ទីបំផុតយើងក៏ត្រូវភ្លេចចោលទៅដែរ ចំពោះអនាគតក៏មិនទៀងទាត់ គ្រាន់តែជាដំណើរឆ្លងកាត់ប៉ុណ្ណោះ ព្រះ-និព្វានទើបជាទីបំផុតទុក្ខ ។

# មានសតិរស់នៅជាមួយនឹងបច្ចុប្បន្ន

ប្រសិនបើអ្វីៗមិនកន្លងទៅទេ ក៏មិនមែនឋិតនៅជាខ្លួនយើងដែរ ដូច្នេះឲ្យតែឃើញធម៌ជាបច្ចុប្បន្នជាសភាវៈដែលមានពិត មួយលក្ខណៈៗ មិនមែនជាខ្លួនយើងស្រេចទៅហើយនោះ ក៏មិនចាំបាច់ទាស់ចិត្តនឹងសភាវៈនោះៗ ហើយត្រូវការសភាវៈដទៃមកជំនួសនោះដែរ ។ សតិប្បដ្ឋានសំខាន់មិនមែនក្នុងគំនិតថាយើងបានអ្វីនោះទេ គឺនៅត្រង់មិនចាប់ប្រកាន់ថារបស់យើង ថាយើង ថាជាខ្លួនរបស់យើង មានតែរលឹកដឹង និងបញ្ញាកំណត់សភាវៈពិតតែប៉ុណ្ណោះ ។

# គ្រប់គ្រងខ្លួនឯងក្នុងផ្លូវសុខស្ងប់

បើយើងបានដើរនៅក្នុងផ្លូវនៃសេចក្ដីសុខស្ងប់ហើយ យើងកុំចាំបាច់ដូរទៅដើរក្នុងផ្លូវផ្សេង ដោយគ្រាន់តែ ចង់ឲ្យអ្នកដទៃមកស្រឡាញ់យើង ឬដើម្បីអ្វីផ្សេងទៀតក្នុងលោកនោះឡើយ បើអ្នកដទៃណា មករាប់អានយើងក្នុងដំណើរដូចគ្នា គឺយើងដើរផ្លូវជាមួយ

គ្នាទៅ ព្រោះផ្លូវត្រូវ ផ្លូវនៃសេចក្តីសុខស្ងប់សំខាន់ណាស់ ។

## អ្វីដែលទៀងទាត់ពិតប្រាកដ

អ្វីដែលទៀងទាត់ពិតប្រាកដ គឺសង្ខារធម៌ដែលមិនទៀងហ្នឹងឯង ក្នុងនោះមានសេចក្តីស្លាប់មួយផងដែរ ដែលប្រាកដប្រជាជាទីបំផុត ចំណែកព្រះនិព្វានទៀងតែពីសុខ ព្រោះមិនមានសភាវៈដែលមិនទៀង ព្រះនិព្វានជានិរោធសច្ច ព្រោះរលត់សច្ចៈពីរខាងដើម ព្រះនិព្វានជាអនុប្បាទនិរោធ ។

## រត់មិនរួចពីការពិត

មិនមានទីណា សម្រាប់ឲ្យយើងរត់រួចអំពីការពិតឡើយ សូម្បីតែព្រះនិព្វាន ប៉ុន្តែបើយើងបានដឹងការពិតដោយបញ្ញា យើងនឹងបានសុខ ដូច្នេះ ចូរកុំទាស់នឹងការពិត កុំចាំបាច់រត់គេចអំពីការពិត

ត្រូវសិក្សាការពិតគ្រប់យ៉ាងវិញ ការពិតជាបរមត្ថដោយអត្ថថា អនត្តា ការពិតចែកជាពីរផ្នែក មួយគឺវដ្តៈ មួយទៀតជាវិវដ្តៈ ។

## ពាក្យថាយើងទៅព្រះនិព្វាន

ពាក្យថាយើង គឺជាឈ្មោះនៃបញ្ចក្ខន្ធដែលតគ្នាមួយសង្សារវដ្ត មកហ្នឹងឯង លុះដល់វដ្តៈអស់បច្ច័យដោយអំណាចអរិយមគ្គ វដ្តៈក៏ត្រូវដាច់អស់មិនមានជាតិ មិនមានភព ទើបឈ្មោះថាយើងទៅព្រះនិព្វាន បើពោលដោយបរមត្ថគឺទុក្ខ និងការរលត់ទុក្ខតែប៉ុណ្ណឹងឯង ។

## រៀនឲ្យស្គាល់ទុក្ខតាមពិត

យើងខ្លាចទុក្ខដោយអវិជ្ជា ប្រាកដជារត់មិនរួចពីសេចក្ដីទុក្ខឡើយ ដូចគ្នានឹងចង់បានសុខដោយអត់បញ្ញាដែរ ដូច្នេះមានតែវិធី

ម្យ៉ាងគត់គឺរៀនឲ្យស្គាល់ទុក្ខតាមពិត ព្រោះទុក្ខដោយអត្ថថា អនត្តា ។

## បញ្ញាភាវនា

ក្នុងលោកនេះ មិនមានអ្នកណាចេះតែបានអ្វីៗដូចចិត្តចង់នោះទេ ប៉ុន្តែក្នុងលោកនេះ អ្វីៗគ្រប់យ៉ាងជាការពិត បុគ្គលល្ងង់រវល់តែកើតទុក្ខព្រោះមិនបានដូចចិត្ត ចំណែកអ្នកមានបញ្ញា រស់នៅជាសុខជាមួយនឹងការពិត បញ្ញាចេះតែចម្រើនឡើងៗ នេះហៅថា បញ្ញាភាវនា ។

## ឲ្យអភ័យខ្លួនឯង

ការមិនឲ្យអភ័យដល់អ្នកដទៃ ក៏កែប្រែរឿងរ៉ាវក្នុងអតីតកាលមិនបាន ការឲ្យអភ័យក៏នៅតែកែប្រែអតីតកាលមិនបានដូចគ្នា ប៉ុន្តែអាចកែប្រែចិត្តរបស់យើងក្នុងបច្ចុប្បន្នឲ្យល្អឡើងបាន ដូច្នេះបើយើង

ឲ្យអភ័យគេមិនបានទេ ក៏ត្រូវតែឲ្យអភ័យដល់ខ្លួនដែរ ។ អតីតកាលមិនបានមកបៀតបៀនយើងទេ បើយើងដឹងថាគ្រប់គ្នាប្រព្រឹត្តទៅតាមកម្ម អ្វីៗត្រូវតែប្រែប្រួល ម្យ៉ាងទៀតយើងឈប់ប្រឆាំងនឹងការពិត យកការពិតមកជាអារម្មណ៍នៃសេចក្ដីស្ងប់ទៀតផង ។

## ចេះគិតឲ្យបានសុខ

សុខជាមួយនឹងគំនិតដែលចេះគិតយល់ថា ក្នុងលោកនេះគ្រប់យ៉ាងរមែងផ្លាស់ប្ដូរប្រែប្រួល ។ រឿងដែលអាក្រក់ប្រទូសរ៉ាយចិត្តយើងនោះ មិនមែនអ្នកដែលស្រឡាញ់យើងប្រែប្រួលទេ គឺយើងខ្លួនឯងទេតើ ដែលមិនព្រមទទួលថា ក្នុងលោកនេះ គ្រប់យ៉ាងរមែងផ្លាស់ប្ដូរប្រែប្រួល ។ នៅពេលយើងកើតទុក្ខព្រោះមិនបានអ្វីដូចប្រាថ្នា ត្រូវរៀនគិតឲ្យឃើញសច្ចៈក្នុងលោក គឺក្នុងលោកនេះ មិនចេះតែបានអ្វីៗដូចចិត្តចង់ឡើយ ហើយក៏មិនអាចសុខជាមួយនឹងរបស់ដែលយើងស្រឡាញ់បានរហូតដែរ កាលបើយើងចេះសិក្សាសច្ចៈក្នុងលោកដូច្នេះ យើងនឹងចេះដោះស្រាយបញ្ហាខ្វាយខ្វល់

ដោយខ្លួនឯងបាន ។

## លោកនេះបង្រៀនឲ្យយើងចេះលះបង់

បើយើងរៀនចេះអំពីលោកនេះ គឺលោកនេះមិនបានបង្រៀនឲ្យយើងគ្រប់គ្រងហួងហែងទេ សត្វលោកសោកសៅព្រោះហេតុតែការហួងហែងថារបស់យើងហ្នឹងឯង ដូច្នេះការដែលយើងរស់នៅយ៉ាងមានសេចក្ដីសុខ មិនមែនព្រោះការគ្រប់គ្រងហួងហែងទេ គឺព្រោះការចេះលះបង់ទេតើ ។

## រស់នៅជាមួយនឹងស្មារតី

បើអ្នកដែលយើងស្រឡាញ់ទៅចោលយើង គឺយើងកុំឃុំឃាំងគេអី ឲ្យអភ័យទៅ ហើយក៏មិនលំបាកនឹងឃុំឃាំងខ្លួនឯងទុកក្នុង

សេចក្តីសោកដែរ មិនចាំបាច់បរិភោគស្រាបំភ្លេចទុក្ខទៀតផង រស់នៅជាមួយនឹងការមានស្មារតី ប្រសើរណាស់ ។

## ត្រូវចេះស្រឡាញ់ខ្លួនឲ្យបានល្អ

ខំប្រឹងរកប្រាក់អស់ជាងពាក់កណ្តាលជីវិត ស្រាប់តែបានមកជួបនឹងរឿងហើយកើតទុក្ខ ដោយមិនអាចដោះស្រាយបានដោយទ្រព្យសម្បត្តិ មាសប្រាក់នោះឡើយ ព្រោះបញ្ហានៅត្រង់ការដែលមិនបានស្រឡាញ់ខ្លួនឯងឲ្យបានល្អ គឺចេះស្រឡាញ់តែទ្រព្យសម្បត្តិ និងរបស់ខាងក្រៅរហូតមក បណ្តោយឲ្យខ្លួនឯងលិចលង់ក្នុងលោក ។ ការស្រឡាញ់ខ្លួនបានល្អត្រឹមត្រូវនោះ គឺចេះរក្សាខ្លួនទុកក្នុងហេតុនៃសេចក្តីសុខ មិនប្រព្រឹត្តអំពើដែលជាទោស សិក្សាការពិតក្នុងលោក អប់រំចិត្តឲ្យប្រាសចាកការហួងហែង មាននេក្ខម្មៈប្រាសចាកកាម ។

## ធម្មទានឥឲ្យភ្នែកឃើញធម៌ពិត

បើយើងអាចឲ្យញាតិមិត្តណាម្នាក់ បានភ្លឺស្វាងក្នុងចិត្តដោយពន្លឺនៃបញ្ញា មានភាពកក់ក្តៅព្រោះបាននូវទីពឹង ការឲ្យនេះឈ្មោះថាធម្មទាន ទាំងអ្នកឲ្យទាំងអ្នកទទួលសុទ្ធតែបានរីករាយក្នុងព្រះរតនត្រ័យដូច្នេះបញ្ញាដែលដឹងការពិតនៃជីវិត ប្រសើរជាងទ្រព្យទាំងពួង ។

## ធ្វើអ្វីៗត្រូវចេះគិតដល់អ្នកដែលស្រឡាញ់យើងផង

ជារឿយៗ យើងតែងតែយំជាមួយនឹងអ្នកដែលមិនស្រឡាញ់យើង ទាំងដល់ថ្នាក់ធ្វើអំពើមិនគួរគប្បីផ្សេងៗទៀតផង ដែលអំពើទាំងនេះព្រមដោយសេចក្តីទុក្ខសោករបស់យើង វាជាការប្រទូស្តបៀតបៀនដល់អ្នកដែលស្រឡាញ់យើងជាទីបំផុត មានមាតាបិតាជាដើម ដោយយើងមានទំនងដូចជាមិនដឹងរឿងនេះផង ។

# ងាយតែលំបាក

វាជាការងាយណាស់ ដែលនាំគ្នាធ្លាក់ចូលក្នុងអន្លង់នៃសេចក្ដីស្រឡាញ់ ប៉ុន្តែវាជាការលំបាកដែលនឹងត្រូវរស់នៅជាមួយគ្នា ។ មនុស្សដែលស្រឡាញ់យើងណាស់ ក៏ចេះអស់សេចក្ដីស្រឡាញ់នោះទៅបាន ដូច្នេះចំពោះគូគ្រងគួរតែរៀបចំឲ្យមានសទ្ធា សីល ចាគៈ និងបញ្ញាស្មើៗគ្នា គឺអាចរស់នៅបានសុខជាមួយគ្នាច្រើន ហើយបើប្រាថ្នាជួបគ្នា រមែងជួបដល់ព្រះនិព្វាន ប៉ុន្តែបើយើងរកអ្នកដែលមានធម៌ទាំង ៤ នេះជាគូគ្រងមិនបានទេ ក៏យើងត្រូវតែរស់នៅជាមួយធម៌ទាំង ៤ នេះក្នុងជីវិតរបស់យើងឲ្យបានខ្ជាប់ខ្ជួនដែរ ព្រោះសទ្ធាគឺជាមិត្តដ៏ល្អ សីលជាគ្រឿងអាភរណៈដ៏វិសេស ចាគៈជាស្បៀងដ៏សំខាន់ ចំណែកបញ្ញាជាអាវុធចាំបាច់សម្រាប់ការពារខ្លួន រក្សាខ្លួនឲ្យរួចផុតអំពីអន្តរាយគ្រប់យ៉ាង ។ ត្រូវតែយល់ព្រមថា ក្នុងលោកនេះ នៅមានសេចក្ដីសុខសន្ទឹកសន្ធាប់ណាស់ ដែលមិនចាំបាច់បានតែអំពីម្នាក់នោះទេ គឺសុខជាមួយនឹងកល្យាណមិត្ត សុខជាមួយនឹងអំពើល្អបរិសុទ្ធរបស់ខ្លួន រហូតដល់សុខផុតលោកគឺព្រះនិព្វាន ដែលជាបរមសុខ ។

# មនុស្សដែលមានសេចក្ដីសុខ

មនុស្សដែលមានសេចក្ដីសុខ មិនមែនថាគេចេះតែបានអារម្មណ៍ល្អៗឯងៗទៅនោះទេ នេះមកអំពីអ្នកនោះឯងសិក្សាត្រូវតាមសេចក្ដីពិតចំពោះអារម្មណ៍ ចេះឲ្យអភ័យ និងចេះគិតរកចំណុចល្អដើម្បីសេចក្ដីសុខស្ងប់នៃចិត្ត ។ អ្វីៗដែលយើងជួបប្រទះរាល់ថ្ងៃទាំងអារម្មណ៍ក្នុងគំនិត បើយើងមិនចេះគិតឲ្យបានសុខខ្លួនឯងទេ យើងក៏រមែងកើតទុក្ខរាល់ថ្ងៃហ្នឹងឯង ។ យើងតែងស្វែងរករបស់ដែលមានតម្លៃ ថ្លៃៗក្រៅខ្លួន បែរទៅជាឲ្យយើងកើតទុក្ខព្រោះការស្វែងរកចង់បាននោះទៅវិញ ដោយប្រការផ្សេងៗ ប៉ុន្តែបើយើងស្វែងរកឃើញតម្លៃនៃជីវិតខ្លួនឯងនៅត្រង់ការឈ្នះសេចក្ដីទុក្ខ យើងមានតែរស់នៅដោយសេចក្ដីស្ងប់ចិត្តជាមួយនឹងគ្រប់អារម្មណ៍ហ្នឹងឯង ។

# កុំភ្លេចថាយើងប្រាថ្នាសុខ

មនុស្សដែលមានទុក្ខ ទើបប្រាថ្នាសេចក្ដីសុខ ប៉ុន្តែដោយការជាប់ជំពាក់នឹងរបស់ដែលនាំឲ្យសុខយូរៗទៅ វាទៅជាព្រមឲ្យខ្លួនឯង

មានទុក្ខព្រោះហេតុតែចង់បានរបស់ដែលខ្លួនឯងស្រឡាញ់ជាប់ជំពាក់នោះទៅវិញ បានជាភ្លេចថាបំណងប្រាថ្នាគឺសេចក្តីសុខទេតើ ។ តាមពិត សេចក្តីសុខក្នុងជីវិតគឺមិនចាំបាច់មានអ្វីៗជាខាងក្រៅច្រើននោះទេ ជាពិសេសគឺសេចក្តីសុខផ្លូវចិត្ត ចាំបាច់តែចំណេះដឹងនិងគុណធម៌ដែលត្រូវអប់រំចម្រើនប៉ុណ្ណោះ ។ សេចក្តីទុក្ខផ្លូវចិត្តទាំងអស់ សុទ្ធតែអាចដោះស្រាយបានតាមផ្លូវព្រះធម៌ ដោយមិនចាំបាច់បានអ្វីតាមចំណង់នោះឡើយ បើដោះស្រាយសេចក្តីទុក្ខផ្លូវចិត្តបានហើយ ទុក្ខក្នុងវដ្តៈក៏ឈ្មោះថាដោះស្រាយបាន ព្រោះមិនមានហេតុនៃវដ្តទុក្ខតទៅទៀតហ្នឹងឯង ។

## ហួងហែងច្រើន ទុក្ខក៏ច្រើន

កាលនៅពីតូច ឈឺត្រឹមរត់ដួលខ្លួនឯង ដល់ពេលធំឡើង សេចក្តីទុក្ខមិនមែនច្រើនទៅតាមអាយុច្រើននោះទេ ប៉ុន្តែវាច្រើនឡើងទៅតាមសេចក្តីប្រកាន់ហួងហែង បានសេចក្តីថា ប្រកាន់ច្រើនទុក្ខក៏ច្រើនដែរ ។ សង្ខារធម៌ អត់មានអ្វីជាម្ចាស់លើអ្វីឡើយ មានតែការកើតឡើងហើយ រលត់ទៅវិញតែប៉ុណ្ណោះ ប៉ុន្តែយើងមានការ

ចាប់ប្រកាន់ឲ្យកើតទុក្ខខ្លួនឯង តាមធម្មតានៃធម្មជាតិ ដូចផែនដីមានប្រក្រតីវិលជុំវិញព្រះអាទិត្យដូច្នោះឯង ក្នុងន័យដែលថា យើងទៅចាប់ប្រកាន់លោកនេះ ឲ្យកើតទុក្ខខ្លួនឯង មានទំនងជាការស្រឡាញ់លោកនេះណាស់ ទាំងដែលលោកនេះពោរពេញទៅដោយទុក្ខ ក៏នៅតែមិនដឹងខ្លួន ។

## នៅពីតូចមានម៉ែ ឥឡូវមានព្រះធម៌

នៅពីតូច មានសេចក្ដីសុខជាមួយនឹងម៉ែ គឺទឹកមុខម៉ែប្រកបដោយសេចក្ដីអាណិតស្រឡាញ់ សំឡេងម៉ែលួងលោមបំពេ ដៃម៉ែបបោសអង្អែល និងជាពិសេសគឺភ្លៅម៉ែ...បានផ្ដេកក្បាលលើទ្រូងម៉ែហើយក៏បាត់យំ គេងលក់ទៅ ឥឡូវមកមានសេចក្ដីសុខជាមួយនឹងព្រះធម៌ គឺសៀវភៅធម៌ សំឡេងព្រះធម៌ សិក្សាព្រះធម៌ សម្លួស្សត្រូវសភាវៈឃើញការពិត និងជាពិសេសគឺបានអប់រំចិត្តចម្រើនបញ្ញា...មានចិត្តបង្អោនទៅកាន់ព្រះនិព្វាន បាត់ទុក្ខក្រវល់ក្រវាយ មានសេចក្ដីសុខស្ងប់ ដោយប្រការដូច្នេះឯង ។

# កំណាព្យនាងខ្លាឆ្មោះត្រើយមិនវិលវិញ

ខ្ញុំនៅពីតូចទាស់ចិត្តយំ ទឹកមុខម៉ែខ្ញុំអប់ឧណ្ហចិត្ត
សំឡេងលួងលោមអមអាណិត រងំមែនពិតផ្អិតឱរា ។
ដៃម៉ែបបោសអង្អែលកូន ជាក្បូនជីវិតចិត្តមេត្តា
ភ្លៅម៉ែឋានសុខសមប្រាថ្នា គេងកើយឱរាមាតាខ្ញុំ ។
ពីតូចឈឺត្រឹមត្រង់រត់ដួល ឥឡូវប្រែប្រួលព្រោះទុក្ខធំ
ទុក្ខព្រោះហួងហែងដែងគ្នាផ្តុំ ទុក្ខព្រោះធ្វើខ្ញុំនៃតណ្ហា ។
ពីតូចហួងហែងត្រឹមភ្លៅម៉ែ ឥឡូវហួរហែហួងកាមា
ហួងដល់ហួតហែងចំបែងផ្សា ក្តៅក្នុងឱរាតណ្ហាដុត ។
ពីតូចមានម៉ែតែឥឡូវ ព្រះធម៌ប្រាប់ផ្លូវត្រូវបរិសុទ្ធ
រៀនធម៌នៅព្រះមហាគន្ធកុដិ ដើម្បីរួចផុតភពសោកា ។
ពីមុនមុខម៉ែតែឥឡូវ ខ្ញុំមើលសៀវភៅផ្លូវយាត្រា
ខ្ញុំអានខ្ញុំកត់បទខ្លឹមសារ ខ្ញុំគិតពិចារណ៍ការប្រតិបត្តិ ។
ពីមុនមាត់ម៉ែតែឥឡូវ មាត់អ្នកនាំផ្លូវត្រូវបង្ហាត់
ព្រះធម៌សម្តែងឲ្យបែងកាត់ តាមអ្វីដែលបាត់បង់ធម្មតា ។
ពីមុនដៃម៉ែតែឥឡូវ ដៃដែលពាល់ត្រូវគឺអត្ថា
អត្ថនៃព្រះធម៌ល្អខ្លឹមសារ អង្អែលចិន្តាឱរាស្ងប់ ។

ពីមុនភ្លៅម៉ែតែឥឡូវ    រលឹកដឹងត្រូវភ្លៅគូគាប់
គឺជាបល្ល័ង្កតាំងចិត្តស្ងប់    បញ្ញាឃើញសព្វសង្ខារធម៌ ។
ពីមុនផ្ដេកក្បាលលើទ្រូងម៉ែ    ឥឡូវបង្វែរទិសបវរ
សតិប្បដ្ឋានបានគោចរ    ទ្រូងម៉ែស្មោះសរគឺនិព្វាន ។
សម្មាទិដ្ឋិស្នុះនាំមុខ    ជាក្បាលនាំសុខមុខព្រហ្មយាន
នេះគឺផ្ដេកក្បាលទៅនិព្វាន    ទ្រូងម៉ែសុខសាន្តគ្មានកង្វល់ ។
គេងលក់បាត់យំសំងំសុខ    មិននៅក្នុងស្រុកទុក្ខរចល់
នេះគឺជាលោកុត្តរផល    និព្វានជាខ្នល់ខ្នើយសុខសាន្ត ។
ពីមុននៅតូចឥឡូវធំ    បានហាត់អប់រំអប់សន្ដាន
កង្វល់ហួងហែងទាំងប៉ុន្មាន    នឹងលះបង់បានក្សាន្តសុខា ។
សូមថ្វាយបង្គំគុណកែវបី    គុណបុណ្យបារមីគ្រូអាចារ្យ
គុណម៉ែកូនគាប់កើយឱរា    ទាំងគុណបិតាគុណអ្នកស្រុក ។
គុណមិត្តកល្យាណបានកក់ក្ដៅ    គុណធម៌នាំផ្លូវសំដៅសុខ
ទាំងគុណញាតិផៅក្នុងក្រៅស្រុក    ឧបត្ថម្ភគ្រប់មុខសំបុកទាន ។
គ្រប់គ្នាគ្រប់ជាតិញាតិវដ្ដៈ    ធ្លាប់រួមសន្ថវៈធ្លាប់បំពាន
ធ្លាប់កើតឋានសួគ៌សុខវិមាន    ឬប្រេតអត់ឃ្លានមានទុក្ខធំ ។
ឱវដ្ដសង្សារមហាទឹកភ្នែក    ភារៈទូលរែកធ្លាប់ស្រែកយំ
បញ្ចក្ខន្ធាគួរនាភ្នំ    ឥឡូវខ្ញុំសុំលាអ្នកហើយ ។

ខ្ញុំនឹងជិះយានអរិយមគ្គ មារមិនអាចទាក់ខ្ញុំបានឡើយ
យើងធ្លាប់ជួបគ្នាប៉ុណ្ណឹងហើយ នាវាឆ្ពោះត្រើយមិនវិលវិញ៕

ដោយ **ប.ស.ឋ.**

# ពិភពនៃសេចក្ដីស្ងប់

ដើម្បីជួយខ្លួនឯងដែលចេះតែក្ដៅក្រហាយស្អប់អ្នកដទៃ ឲ្យបានសុខស្ងប់មុនពេលស្លាប់ គឺត្រូវចេះសម្លឹងមើលសេចក្ដីល្អរបស់គេខ្លះផង ទោះតិចតួចក៏ដោយ ប្រៀបដូចទឹក យ៉ាងហោចណាស់ក៏បានមួយក្អឹក ពីរក្អឹកបំបាត់ខះកដែរ ជាពិសេសគឺកុំចេះតែចង់បានសេចក្ដីល្អពីគេសព្វគ្រប់នោះ យើងធ្វើឲ្យសម្បូណ៌បែបក្នុងខ្លួនឯងមិនទាំងបានផង បើយើងធ្វើឲ្យខ្លួនឯងបាន ម៉េចក៏មិនត្រាស់ដឹងទៅ ចាំបាច់នៅខឹង នៅកើតទុក្ខ នៅមានរាគៈ ទោសៈ មោហៈធ្វើអ្វី ។ តាមពិតសេចក្ដីល្អដែលយើងមានខ្លះៗនោះ ក៏ព្រោះបច្ច័យនៃសេចក្ដីល្អនោះមានត្រឹមប៉ុណ្ណឹង ចំណែកអ្នកដទៃវិញក៏ដូចគ្នា សុទ្ធតែមានហេតុផលជាបរមត្ថពិត ក្នុងបុគ្គលម្នាក់ៗ ដូច្នេះ បើយើងមានបញ្ញាទទួលអារម្មណ៍ជាការពិតបាន យើងនឹងរស់នៅក្នុងពិភពនៃសេចក្ដីស្ងប់ ។

# ៨.កោសម្ពិយសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ក៏សម័យនោះឯងពួកភិក្ខុមានការឈ្លោះទាស់ទែងគ្នា ។ សម័យដែលឈ្លោះទាស់ទែងគ្នា គឺមិនមានមេត្តាកាយកម្ម មិនមានមេត្តាវចីកម្ម មិនមានមេត្តាមនោកម្មឡើយ ជាហេតុឲ្យប្រព្រឹត្តទៅដើម្បីសេចក្តីមិនចម្រើន ដើម្បីសេចក្តីទុក្ខដល់អ្នកដែលឈ្លោះទាស់ទែងគ្នានោះ អស់កាលជាអង្វែង ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់អំពីសារាណីយធម៌ ៦ ប្រការ គឺធម៌ជាទីរលឹក ជាទីធ្វើឲ្យកើតសេចក្តីស្រឡាញ់ ជាទីធ្វើឲ្យកើតសេចក្តីគោរព រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀងគ្នា និងដើម្បីមូលមតិគ្នា ។ ក្នុងបណ្តាពាក្យទាំងនេះគឺ

**សារាណីយា** ជាហេតុឲ្យរលឹកដល់គ្នា ដោយសេចក្តីថា ទោះជាពេលវេលាកន្លងទៅយូរហើយក៏ដោយ នៅតែមិនភ្លេច មានការនឹកឃើញគុណសម្បត្តិដែលប្រកបដោយធម៌ ។

**បិយករណា** រមែងធ្វើឲ្យជាទីស្រឡាញ់នៃសព្រហ្មចារី ។

**គរុករណា** រមែងធ្វើឲ្យកើតនូវសេចក្ដីគោរព ។

**សង្គហាយ** ដើម្បីប្រយោជន៍ដល់ការសង្គ្រោះគ្នា ។

**អវិវាទាយ** ដើម្បីប្រយោជន៍ដល់ការមិនវិវាទគ្នា ។

**សាមគ្គិយា** ដើម្បីប្រយោជន៍ដល់ការព្រមព្រៀងគ្នា ។

**ឯកីភាវាយ** ដើម្បីប្រយោជន៍ដល់ភាពតែមួយ ។

សារាណីយធម៌ ៦ ប្រការរាប់យកមេៗគឺ

១- **មេត្តាកាយកម្ម** ទាំងចំពោះមុខ ទាំងកំបាំងមុខ ។

២- **មេត្តាវចីកម្ម** ទាំងចំពោះមុខ ទាំងកំបាំងមុខ ។

៣- **មេត្តាមនោកម្ម** ទាំងចំពោះមុខ ទាំងកំបាំងមុខ ។

៤- **សាធារណភោគី** ជាអ្នកចែកគ្នាបរិភោគ ។

៥- **សីលសាមញ្ញគតោ វិហរតិ** ជាអ្នកមានសីលស្មើគ្នា ។

៦- **ទិដ្ឋិសាមញ្ញគតោ វិហរតិ** ជាអ្នកមានទិដ្ឋិស្មើគ្នា ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កំពូលនៃផ្ទះមានកំពូល ជាច្បង ជាទីរួបរួម ជាទីប្រជុំចុះ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ បណ្ដាសារាណីយធម៌ទាំង ៦ ប្រការនេះ មានតែទិដ្ឋិដ៏ប្រសើរ ជាទីស្រោចស្រង់នេះឯង ដែលជាច្បង ជាទីរួបរួម ជាទីប្រជុំចុះ ( នៃធម៌ទាំង ៥ នោះ ) អាចដឹកនាំសត្វដែលប្រតិបត្តិតាម ឲ្យ

អស់ទុក្ខដោយប្រពៃបាន យ៉ាងនោះដែរ ។

ចំពោះសារាណីយធម៌ទី ៦ នេះ សំដៅយកសម្មាទិដ្ឋិក្នុងសោតាបត្តិមគ្គ ជាបន្តព្រះអង្គទ្រង់ត្រាស់សម្តែងអំពីញាណ ៧ យ៉ាងរបស់ព្រះសោតាបន្នបុគ្គលគឺ

**ញាណទី ១** បានដឹងអំពីសម្មាទិដ្ឋិក្នុងសោតាបត្តិមគ្គដែលបានលះនូវបរិយុដ្ឋានកិលេស ៨ យ៉ាងគឺនីវរណៈ ៥ ការខ្វល់ខ្វាយគិតរឿងលោកនេះ ១ ការខ្វល់ខ្វាយគិតរឿងលោកខាងមុខ ១ និងការបង្កហេតុ ឈ្លោះទាស់ទែងគ្នា ចាក់ដោតគ្នាដោយលំពែងគឺមាត់ ១ និងបានដឹងថា ចិត្តរបស់អាត្មាអញ បានតម្កល់ទុកដោយប្រពៃហើយដើម្បីជាប្រយោជន៍ដល់ការត្រាស់ដឹងនូវអរិយសច្ចទាំង ៤ ។

**ញាណទី ២** បានដឹងអំពីសម្មាទិដ្ឋិក្នុងសោតាបត្តិមគ្គនោះឯងដែលធ្វើឲ្យបាននូវសេចក្តីស្ងប់រំងាប់ក្នុងចិត្តរបស់ខ្លួន ( **លភាមិ បច្ចត្តំ សមថំ** ) និងការបាននូវការរំលត់កិលេសក្នុងចិត្តរបស់ខ្លួន ( **លភាមិ បច្ចត្តំ និព្វុតិន្តិ** ) ។

**ញាណទី ៣** បានដឹងអំពីសម្មាទិដ្ឋិក្នុងសោតាបត្តិមគ្គនោះឯងមិនមានក្នុងសមណព្រាហ្មណ៍ដទៃក្រៅអំពីព្រះពុទ្ធសាសនាឡើយ ។

**ញាណទី ៤** បានដឹងថាបុគ្គលដែលបរិបូណ៌ដោយសម្មាទិដ្ឋិក្នុងសោតាបត្តិមគ្គ ( **តថារូបាយ ទិដ្ឋិយា** ) អាត្មាអញក៏ប្រកប

ដោយទិដ្ឋិតាមធម្មតា មានសភាពយ៉ាងនោះដែរ ។ ជាធម្មតានៃបុគ្គលដែលបរិបូណ៌ដោយទិដ្ឋិគឺចេញចាកអាបត្តិ ដោយមិនមានបិទបាំងទុកឡើយ ( **អចិត្តភាបត្តីយេទ អាបជ្ជតិ តម្បិ អសញ្ចិច្ច នោ សញ្ចិច្ច អាបន្នំ ន បដិច្ឆាទេតិ** ) ប្រៀបដូចក្មេងតូចប្រញាប់ដកដៃឬជើងដែលប៉ះភ្លើងដូច្នោះឯង ។

**ញាណទី ៥** បានដឹងថា ជាធម្មតានៃបុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ គង់មានការខ្វល់ខ្វាយក្នុងកិច្ចការខ្ពស់និងទាបរបស់ពួកសព្រហ្មចារី តែលោកមានសេចក្តីប្រាថ្នាដ៏ក្លៀវក្លាក្នុងអធិសីលសិក្ខា អធិចិត្តសិក្ខា និងអធិប្បញ្ញាសិក្ខា ដូចមេគោមានកូនខ្ចី ខំប្រឹងស៊ីស្មៅផង ថ្មិតថ្មមកូនផង ដូច្នោះឯង ។

**ញាណទី ៦** បានដឹងថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិប្រកបដោយទិដ្ឋិមានកម្លាំង ( **ពលតាយ សមន្នាគតោ** ) រមែងយកចិត្តទុកដាក់ជាមួយនឹងអ្នកសម្តែងនូវធម្មវិន័យ ដែលព្រះតថាគតបានសម្តែងទុកមក ប្រមូលចិត្តឲ្យមូល តាំងទុកនូវត្រចៀកចាំស្តាប់ ។ ព្រះអរិយសាវ័កទាំងឡាយ ជាអ្នកស្រឡាញ់ការស្តាប់ធម៌ ទៅស្តាប់ធម៌មិនអង្គុយលក់ មិនសន្ទនាជាមួយនឹងអ្នកណាៗ និងមានចិត្តមិនរវើរវាយ ដោយពិតគឺមិនឆ្អែតក្នុងការស្តាប់ធម៌ឡើយ ប្រៀបដូចបានបរិភោគនូវទឹកអម្រឹត ។

**ញាណទី ៧** បានដឹងថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ប្រកបដោយទិដ្ឋិមានកម្លាំង រមែងបានដឹងអត្ថ ( **លភតិ អត្ថវេទំ** ) រមែងបានដឹងធម៌ ( **លភតិ ធម្មវេទំ** ) និងបាននូវបាមោជ្ជដែលប្រកបដោយធម៌ ( **លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ** ) អំពីការដែលបានស្តាប់នូវធម្មវិន័យ ដែលព្រះតថាគតបានសម្តែងទុកមក តាមដែលបណ្ឌិតបានប្រកាសសម្តែងនោះឯង ។

ញាណទាំង ៧ ប្រការ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា **អរិយំ លោកុត្តរំ អសាធារណំ បុថុជ្ជនេហិ** ប្រែថា ជាអរិយៈ ជាលោកុត្តរ មិនសាធារណៈដល់ពួកបុថុជ្ជនឡើយ ។

ក្នុងពាក្យថា **អរិយំ** មានសេចក្តីអធិប្បាយថា ព្រោះញាណនោះរមែងមានដល់ព្រះអរិយៈ មិនមានដល់បុថុជ្ជនឡើយ ។

ក្នុងពាក្យថា **លោកុត្តរំ** ដោយសេចក្តីថា បុគ្គលពួកណាមាននូវលោកុត្តរធម៌ ( ញាណទាំង ៧ នេះ ) ក៏មានចំពោះតែបុគ្គលពួកនោះប៉ុណ្ណោះ គឺមិនមានដល់ពួកបុគ្គលដទៃឡើយ ( ក្នុងដីកាពោលថា **លោកុត្តរហេតុភាវាយ លោកុត្តរន្តិ វុត្តំ** )។

ក្នុងពាក្យថា **អសាធារណំ បុថុជ្ជនេហិ** គឺមិនទូទៅដល់បុថុជ្ជនទាំងឡាយ ព្រោះមិនមានដល់ពួកបុថុជ្ជនហ្នឹងឯង ។

នៅខាងចុងនៃព្រះសូត្រ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតានៃអរិយសាវ័កដែលប្រកបដោយអង្គទាំង ៧ ប្រការយ៉ាងនេះ សម្រេចល្អហើយ ក្នុងការធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ( **ឯវំ សត្តង្គសមន្នាគតស្ស ខោ ភិក្ខវេ អរិយសាវកស្ស ធម្មតា សុសមន្និដ្ឋា ហោតិ សោតា-បត្តិផលសច្ឆិកិរិយាយ** )។

ពាក្យថា **ធម្មតា សុសមន្និដ្ឋា** ប្រែថា ត្រួតមើលល្អហើយនូវធម្មតា ដោយសេចក្ដីថា សភាវៈគឺលោកបានពិនិត្យពិចារណាល្អហើយ ។

ពាក្យថា **សោតាបត្តិផលសច្ឆិកិរិយាយ** ប្រែថា ដោយការធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល នេះជាពាក្យពោលដល់ហេតុ អធិប្បាយថា ដោយញាណដែលធ្វើឲ្យជាក់ច្បាស់ហើយដោយសោតាបត្តិផល ។

ពាក្យថា **ឯវំ សត្តង្គសមន្នាគតស្ស** ដោយសេចក្ដីថា បុគ្គលដែលប្រកបដោយញាណជាគ្រឿងពិចារណាដ៏ធំទាំង ៧ ប្រការនេះ យ៉ាងនេះឯង ( **ឯវំ ឥមេហិ សត្តហិ មហាបច្ចវេក្ខ-ណញ្ញាណេហិ សមន្នាគតោ** )។

ដោយសេចក្តីបញ្ជាក់ចុងក្រោយនេះគឺថា ព្រះសោតាបន្ន-បុគ្គលដែលមានញាណទាំង ៧ ប្រការនេះ មានសភាពដែលបានពិចារណាល្អហើយដូច្នេះ នោះព្រោះមកអំពីបានធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ទើបព្រះដ៏មានព្រះភាគទ្រង់បញ្ចប់ព្រះសូត្រដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កដែលប្រកបដោយអង្គទាំង ៧ ប្រការនេះ ឈ្មោះថាជាអ្នកប្រកបដោយសោតាបត្តិផល។

សូមអនុមោទនា !

## បើគេឈប់ស្រឡាញ់ត្រូវឲ្យចេះស្រឡាញ់ខ្លួនឯង

| | |
|---|---|
| បើឈឺចិត្តឲ្យចេះស្រោក | បើលំបាកឲ្យចេះប្រឹង |
| បើខឹងឲ្យចេះអត់ | បើព្រាត់ឲ្យចេះព្រម |
| បើល្មមឲ្យចេះគ្រប់ | បើគប់ឲ្យចេះគិត |
| បើអាណិតឲ្យចេះជួយ | បើព្រួយឲ្យចេះប្រុង |
| បើបម្រុងឲ្យចេះត្រៀម | បើបៀមឲ្យចេះបិទ |
| បើគិតឲ្យចេះកាញ់ | បើស្រឡាញ់ឲ្យចេះថៃ |

បើធ្វើស្រែឲ្យចេះសាបព្រោះ បើម៉ែឪនៅរស់ឲ្យចេះធ្វើបុណ្យ
បើស្រឡាញ់គុណឲ្យចេះរលឹក បើរៀនសន្ធឹកឲ្យចេះចាក់ធ្លុះ
បើគេប្រទូស្តឲ្យចេះចុះចាញ់ បើគេឈប់ស្រឡាញ់
ត្រូវឲ្យចេះស្រឡាញ់ខ្លួនឯង ៕

ដោយ **ប.ស.ទ.**

## ជំនួយស្មារតីដល់អ្នកមានទុក្ខ

ពេលណាដែលគិតថាបាត់បង់គេហើយ ខ្លួនឯងមិនអាចរស់នៅបាន ពេលនោះគឺជាពេលដែលអ្នកកំពុងតែភ្លេចស្រឡាញ់ខ្លួនឯង ។

យើងត្រូវតែបើកភ្នែកសម្លឹងមើលការពិតនៃជីវិត កុំចេះតែលេបថ្នាំឲ្យដេកលក់ដើម្បីបំភ្លេចរឿងនោះ ។ យើងចង់បំភ្លេចទុក្ខ តែទុក្ខមិនបំភ្លេចយើងទេ ដើម្បីឈ្នះទុក្ខទាល់តែឃើញការពិត ហើយលះបង់នូវចំណង់លោកិយក្នុងចិត្តខ្លួនឯង ។

ត្រូវប្រយ័ត្នចំពោះរាគៈក្នុងចិត្តខ្លួនឯង វាធ្វើឲ្យវង្វេង ឃើញរឿងដែលនាំឲ្យកើតទុក្ខ ថានាំឲ្យសប្បាយ ឃើញរឿងឥតប្រយោជន៍

ថាមានប្រយោជន៍ សូម្បីដឹងថាអំពើមិនល្អហើយ តែវាធ្វើឲ្យមានសេចក្តីប្រមាទ ឲ្យគិតថាមិនអីទេ ។

យើងមិនអាចបានអ្វីពីការយល់សប្តិនោះទេ ដូច្នេះយើងគប្បីភ្ញាក់ឡើងធ្វើការងារឲ្យសម្រេចប្រយោជន៍ យ៉ាងណាមិញ យើងក៏មិនអាចបានអ្វីអំពីលោកនេះក្នុងដំណេកកិលេស ដោយគ្រាន់តែតណ្ហាទិដ្ឋិប្រកាន់ដូចជាការយល់សប្តិថា នោះជារបស់យើង ដូច្នេះឡើយ គឺយើងត្រូវតែភ្ញាក់ដឹងខ្លួនឡើង តាមរយៈនៃសំឡេងប្រកាសនូវអរិយសច្ចធម៌ ហើយបដិបត្តិដើម្បីប្រយោជន៍រួចផុតចាកទុក្ខ ក៏យ៉ាងនោះដែរ ។

បើយើងមិនស្រឡាញ់ខ្លួនឯងហើយ មិនធ្វើឲ្យខ្លួនឯងមានតម្លៃទេនោះ តើអ្នកណាគេមកស្រឡាញ់ មកឲ្យតម្លៃយើង ដូច្នេះការសាងសេចក្តីល្អនេះឯងគឺជាការសំខាន់ណាស់ ខំប្រឹងធ្វើទៅទាន់មានឱកាសល្អ ។ សេចក្តីល្អនោះ ទោះជាមិនមានអ្នកណាដឹងក៏ជាសេចក្តីល្អស្រេចទៅហើយ ប៉ុន្តែមិនខ្វះអ្នកដែលដឹងនោះទេ យ៉ាងហោចណាស់ក៏មានខ្លួនយើងម្នាក់ដែរ ហើយយើងក៏បានដឹងរសជាតិនៃសេចក្តីសុខក្នុងអំពើល្អដែលយើងបានធ្វើ យើងឈប់កើតទុក្ខជាមួយនឹងមនុស្សម្នាក់ដែលចោលយើង ដោយយើងមកមានសេចក្តីសុខជាមួយនឹងកល្យាណមិត្ត ជាមួយនឹងអំពើល្អរបស់យើងហ្នឹង

ឯង ។ ម្យ៉ាងទៀតអំពើល្អរបស់យើង ប្រៀបដូចខ្យល់អាកាសអ៊ីចឹងដែរ ខ្យល់អាកាសសំខាន់ណាស់ សម្រាប់គ្រប់គ្នាដកដង្ហើម ទាំងមនុស្សទាំងសត្វ យ៉ាងណា អំពើល្អក៏យ៉ាងនោះដែរ មិនថាទាន មិនថាសីល សុទ្ធតែជួយឲ្យគេបានរស់ បានសុខ មិនមានភ័យ ចំណែកខ្លួនយើងសប្បាយចិត្តរាល់ថ្ងៃ មិនមែនអត់អំពីមនុស្សម្នាក់នោះទៅយើងអត់ខ្យល់ដកដង្ហើមនោះទេ ។

នៅពេលសុខ យើងមិនចង់ឲ្យពេលវេលាកន្លងទៅទេ តែឃាត់មិនបាន នៅពេលទុក្ខ យើងចង់ឲ្យពេលវេលាឆាប់កន្លងផុតទៅ តែបង្គាប់បញ្ជាមិនបាន ដូច្នេះមានតែរៀនរស់នៅឲ្យបានសុខជាមួយ នឹងធម៌ពិត ទើបសុខគ្រប់វេលា ព្រោះពេលណាក៏មានធម៌ពិតដែរ ។ ដើម្បីរៀនរស់នៅឲ្យបានសុខជាមួយនឹងធម៌ពិត គឺត្រូវតែរៀនយក ព្រះពុទ្ធដីកាឲ្យបានចេះដឹង ហើយបដិបត្តិឲ្យបានត្រឹមត្រូវទើបបាន សម្រេច ។

ការខឹងស្អប់ គឺជាកាំបិតអារចិត្តខ្លួនឯង ចំណែកការឲ្យអភ័យគឺជាថ្នាំព្យាបាលរបួស បើយើងមិនព្យាបាលទេ របួសនឹងក្លាយទៅជាដំបៅ មានតែការឈឺចាប់ បាត់បង់ពេលវេលាដែលត្រូវបានសុខជាមួយនឹងអ្នកដែលស្រឡាញ់យើងយ៉ាងច្រើន មានមាតាបិតា

ជាដើម ។ បើយើងព្រមស្លាប់ដោយធ្វើអត្តឃាតដើម្បីមនុស្សម្នាក់ដែលមិនស្រឡាញ់យើង តើគប្បីចំពោះមាតាបិតាដែលខំបីបាច់ថ្នាក់-ថ្នមយើង ចិញ្ចឹមយើងតាំងពីតូចដល់ធំ ទាំងដែលយើងមិនទាន់បានតបស្នងសងគុណគាត់ផងនោះ ដែរឬទេ ? តើការស្លាប់របស់យើងមានតម្លៃដែរឬទេ ?

វាដូចជាសត្វកណ្ដុរមួយក្បាលស្លាប់ក្នុងផ្ទះ គឺមិនចាំបាច់ដុតផ្ទះនោះចោលទេ ពិតមែនតែវាមានក្លិនស្អុយពេញផ្ទះ ប៉ុន្តែដល់យកវាទៅកប់ចោលទៅ លាងទីនោះឲ្យស្អាត បើកទ្វារបង្អួចឲ្យខ្យល់ចេញចូល យើងក៏មិនមានបញ្ហានឹងក្លិនស្អុយនោះទៀតដែរ យ៉ាងណារឿងរ៉ាវអ្វីមួយក្នុងគំនិត មិនចាំបាច់ធ្វើអត្តឃាតទេ យកតែគំនិតដែលដូចជាកណ្ដុរងាប់នោះឯង ទៅកប់ចោលក្នុងដីគឺអតីតកាលនោះទៅសេចក្ដីទុក្ខដែលដូចជាក្លិនស្អុយក៏វាបាត់ទៅដែរ យកទឹកគឺការឲ្យអភ័យមកលាងជម្រះ បើកទ្វារបង្អួចឲ្យខ្យល់អាកាសចេញចូលបានល្អ គឺបើកភ្នែកមើលព្រះត្រៃបិដកជាដើម បើកត្រចៀកស្ដាប់ធម៌ ធ្វើសេចក្ដីល្អ ដើម្បីឲ្យដូចជាខ្យល់អាកាសបរិសុទ្ធ ដកដង្ហើមស្រួលគឺរស់នៅបានសុខ ប្រាសចាកក្លិនស្អុយគឺសេចក្ដីទុក្ខដែលរសាយអស់ទៅនោះឯង ផ្ទះគឺអត្តភាពនៅគង់វង់ដើម្បីបានរស់នៅធ្វើសេចក្ដីល្អបានច្រើនទៀតណាស់ ក៏យ៉ាងនោះដែរ ។

ជីវិតគឺជាការដើរផ្លូវ ដូច្នេះត្រូវតែរៀនលះបង់នូវគ្រឿងជាប់ជំពាក់ ព្រោះមុខតែទៅចោលដដែលទេ កុំឲ្យវាសៅហ្មងចិត្ត អ្វីដែលឥតប្រយោជន៍គឺអកុសលកម្មកុំយកទៅជាមួយគឺកុំធ្វើវា ចំណែកអ្វីដែលមានប្រយោជន៍គឺកុសលកម្ម ចាំបាច់ត្រូវជាប់ទៅជាមួយអ្នកដើរផ្លូវ គឺត្រូវសាងសន្សំអប់រំ ទាំងយប់ទាំងថ្ងៃ ពេលណាក៏ធ្វើបុណ្យបានបុណ្យដែរ កុំប្រមាទក្នុងការបំពេញកុសលធម៌ទាំងឡាយ ។

សម័យកាលដែលព្រះដ៏មានព្រះភាគ ទ្រង់គង់ព្រះជន្មនៅពេលថ្ងៃរសៀលពុទ្ធបរិស័ទនាំគ្នាយកគ្រឿងសក្ការបូជា ទៅវត្តស្តាប់ព្រះធម៌ទេសនារបស់ព្រះអង្គ សម័យសព្វថ្ងៃព្រះធម៌ជំនួសព្រះបរម-សាស្តា មានតែពុទ្ធបរិស័ទមកវត្តស្តាប់ព្រះធម៌ទេសនា សន្ទនាព្រះធម៌ ឆ្លល់អ្វីសាកសួរ យកចិត្តទុកដាក់រៀនសូត្រ បានចំណេះដឹងអប់រំចិត្តតាមផ្លូវព្រះធម៌ មិនលុះក្នុងអំណាចនៃកិលេសមារក្នុងចិត្តខ្លួនឯង ។

លោកនេះ ជីវិតនេះ ភារៈនេះ សម្រាប់មនុស្សល្ងង់ហួងហែងរែកពុនលីសែង រអ៊ូរទាំយំសោក ប៉ុន្តែសម្រាប់អ្នកមានបញ្ញា កំណត់ដឹងនិងដាក់ចុះ ។

ការជួបជាដំបូង ការជុំជាកណ្តាល ទីបំផុតត្រូវតែមានការព្រាត់ប្រាស នេះគឺជាការពិតមួយក្នុងលោក មិនមានអ្នកណាម្នាក់

បាននូវការជួបជុំមិនព្រាត់ប្រាសនោះឡើយ ប៉ុន្តែវាមានការស្រឡាញ់ហួងហែង ប្រកបដោយសេចក្តីល្ងង់ខ្លៅដោយឡែកឯណោះទេ ដែលនាំឲ្យកើតមានសេចក្តីទុក្ខសោក ក្តៅក្រហាយចិត្ត ។

មុននឹងហួងហែងថាអ្វីៗជារបស់យើង តើមានគិតដល់ចំណុចនៃការហួងហែង និងរបស់ដែលខ្លួនហួងហែងនោះថា មិនទៀងដែរឬទេ ?

បើការហួងហែង វាចូលមកដល់ដំណាក់កាលនៃសេចក្តីទុក្ខសោកហើយ ដំណោះស្រាយដើម្បីឲ្យបានសុខគឺការឲ្យអភ័យនិងការលះបង់នូវសេចក្តីហួងហែងនោះឯង ។

យើងគួរតែសិក្សានូវចំណុចនៃកោសម្ពិយសូត្រ ត្រង់សារាណីយធម៌ ៦ ប្រការ គឺយើងមិនគប្បីធ្វើអ្វី និយាយអ្វី គិតអ្វី សូម្បីតែតាមរយៈទឹកមុខនិងក្រសែភ្នែក ក្នុងសភាពនៃការបៀតបៀន សង-សឹកនោះទេ គួរតែសិក្សានៅក្នុងគុណតម្លៃដែលជាខ្លឹមសារនៃជីវិតឲ្យជាទីនឹករលឹកជ្រះថ្លារបស់មនុស្សនិងទេវតាទាំងឡាយ គឺធ្វើអ្វី និយាយអ្វី គិតអ្វី ឲ្យអ្នកដទៃបានប្រយោជន៍ បានសុខ បានចម្រើន ។

សម្រាប់ព្រះភិក្ខុទាំងឡាយ ការបំពេញនូវអភិសមាចារិកធម៌ដោយចិត្តមេត្តា ឈ្មោះថា **មេត្តាកាយកម្ម** សម្រាប់គ្រហស្ថទាំងឡាយ កម្មជាដើមយ៉ាងនេះគឺ ការទៅដើម្បីប្រយោជន៍ក្នុងការ

ថ្វាយបង្គំព្រះចេតិយ ថ្វាយបង្គំព្រះពោធិព្រឹក្ស និមន្តព្រះសង្ឃក្តី ការឃើញព្រះភិក្ខុទាំងឡាយនិមន្តបិណ្ឌបាតក្នុងស្រុកហើយ បដិសណ្ឋារៈទទួលក្តី ការទទួលបាត្រក្តី ការក្រាលអាសនៈក្តី ការជូនដំណើរនិមន្តក្តី ឈ្មោះថា **មេត្តាកាយកម្ម** ។

សម្រាប់ព្រះភិក្ខុ គឺការប្រាប់បញ្ញត្តិទាក់ទងនិងមារយាទសិក្ខាបទ និងការប្រាប់នូវកម្មដ្ឋាន ព្រមទាំងការសម្តែងធម៌ ប្រកាសនូវព្រះពុទ្ធវចនៈគឺព្រះត្រៃបិដក ដូចនេះ ឈ្មោះថា **មេត្តាវចីកម្ម** សម្រាប់គ្រហស្ថ ក្នុងពេលដែលពោលពាក្យជាដើមថា យើងទៅថ្វាយបង្គំព្រះចេតិយជាមួយគ្នា យើងទៅថ្វាយបង្គំព្រះពោធិព្រឹក្សដូច្នេះក្តី ការចាត់ចែងធ្វើឲ្យមានការស្តាប់ព្រះធម៌ បូជាប្រទីប ផ្កាកម្រងក្តី ណែនាំឲ្យបដិបត្តិក្នុងសុចរិត ៣ ក្តី ប្រកាសក្នុងការថ្វាយទានមានសលាកភត្ត វស្សិកសាដក បច្ច័យ ៤ ដល់សង្ឃក្តី ណែនាំក្នុងការនិមន្តព្រះសង្ឃ ពោលពាក្យឲ្យបដិសណ្ឋារៈចំពោះព្រះសង្ឃសព្វគ្រប់ក្តី កើតការពេញចិត្តប្រកបដោយមេត្តាក្នុងវាចាដែលពោលនោះៗ ឈ្មោះថា **មេត្តាវចីកម្ម** ។

សម្រាប់ព្រះភិក្ខុ និមន្តក្រោកឡើងពេលជិតភ្លឺ ហើយបដិបត្តិសរីរាងកាយ រួចធ្វើវត្តក្នុងបរិវេណនៃចេតិយជាដើម គង់អង្គុយលើ

អាសនៈដ៏ស្ងាត់ នឹកក្នុងចិត្តថា សូមឲ្យពួកភិក្ខុក្នុងវិហារនេះ មានសេចក្ដីសុខ មិនមានពៀរ មិនបៀតបៀនដល់គ្នានឹងគ្នាចុះ ឈ្មោះថា **មេត្តាមនោកម្ម** សម្រាប់គ្រហស្ថ ការធ្វើទុកក្នុងចិត្តថា សូមព្រះគុណម្ចាស់ទាំងឡាយគង់នៅក្នុងព្រះផ្នួសឲ្យជាសុខចុះ ប្រាសចាកពៀរ ប្រាសចាកការបៀតបៀនដល់គ្នានឹងគ្នា នេះឈ្មោះថា **មេត្តាមនោកម្ម** ។

ចំពោះមេត្តាកាយកម្ម មេត្តាវចីកម្ម ក្នុងទីចំពោះមុខទាំងក្នុងទីកំបាំងមុខ ក៏គួរជ្រាបបាន ចំណែកមេត្តាមនោកម្មក្នុងទីកំបាំងមុខព្រោះគិតក្នុងចិត្ត ក៏គួរជ្រាបបានដែរ ប៉ុន្តែចំពោះមេត្តាមនោកម្មក្នុងទីចំពោះមុខតើដូចម្ដេច ? គឺក្រសែភ្នែកដែលប្រកបដោយមេត្តា និងការសម្លឹងមើលដោយទឹកមុខស្រស់បស់ ត្រជាក់ត្រជុំដោយប្រការដូច្នេះឯង ។

## បញ្ញា ១ ទ្រព្យ ១ កេរ្តិ៍ឈ្មោះ ១ ចងមិត្ត ១

បាននូវបញ្ញាព្រោះការស្ដាប់ល្អ ទ្រព្យបានតាមធម៌ប្រឹងរក៏ទុកដាក់
កេរ្តិ៍ឈ្មោះក្រអូបអប់ដោយសច្ចៈ ចងមិត្តគ្រប់ថ្នាក់សមស័ក្តិព្រោះទាន។

# ៩. ព្រហ្មនិមន្តនិកសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅនាព្រះមហាវិហារជេតពន ព្រះអង្គទ្រង់ត្រាស់សម្តែងនូវព្រះសូត្រនេះ ចំពោះភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សម័យមួយតថាគត នៅក្នុងសុភគវ័ន ទៀបគល់សាលរាជព្រឹក្ស នាដែនឧក្កដ្ឋា ។ ម្នាលភិក្ខុទាំងឡាយ សម័យនោះឯង ទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះ កើតឡើងដល់ព្រហ្មឈ្មោះពកៈថា ឋានព្រហ្មនេះជារបស់ទៀង ជារបស់ឋិតថេរ ជារបស់មាននៅគ្រប់កាល ជារបស់មិនផ្លុះផ្លាយ ជារបស់មិនឃ្លៀងឃ្លាត ព្រោះថាឋានព្រហ្មនេះ មិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនឧប្បត្តិឯឋានដទៃ ជាទីរលាស់ខ្លួនចេញចាកទុក្ខ ឲ្យក្រៃលែងជាងឋានព្រហ្មនេះ មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ តថាគតបានដឹងនូវសេចក្តីត្រិះរិះក្នុងចិត្តរបស់ពកព្រហ្ម ដោយចិត្តរបស់តថាគតហើយ ក៏បាត់អំពីសុភគវ័នទៀបគល់សាលរាជព្រឹក្សក្នុងក្រុងឧក្កដ្ឋា ទៅប្រាកដក្នុងព្រហ្មលោកនោះ ដូចជាបុរសមានកម្លាំងលាដៃដែលបត់ចូល ឬបត់ដៃដែលលាចេញ

ដូច្នោះឯង ។

ទិដ្ឋិអាក្រក់របស់ពកព្រហ្ម គឺបដិសេធនូវព្រហ្មលោកជាន់លើ និងបដិសេធមគ្គផលព្រះនិព្វាន ។

**អវិជ្ជាគតោ** ជាអ្នកទៅដោយអវិជ្ជា គឺជាបុគ្គលប្រកបដោយអវិជ្ជា ជាបុគ្គលល្ងង់ខ្លៅមិនដឹងនូវសច្ចធម៌ ជាបុគ្គលមិនមានភ្នែកបញ្ញា ។

ពកព្រហ្ម បានពោលទៅរកព្រះដ៏មានព្រះភាគថា នែភិក្ខុលោកមិនឃើញនូវឋានដទៃ ជាទីរលាស់ខ្លួនចេញចាកទុក្ខតទៅទៀតទេ លោកជាអ្នកមានចំណែកនៃសេចក្ដីលំបាក និងសេចក្ដីចង្អៀត-ចង្អល់តែម្យ៉ាងប៉ុណ្ណោះ ។ នែភិក្ខុ សូម្បីពួកសមណព្រាហ្មណ៍ក្នុងលោក ដែលជាអ្នកប្រព្រឹត្តតបៈមុនភិក្ខុឯងទៅទៀត ជាមនុស្សចាស់ៗមានអាយុច្រើន ក៏នៅតែរកមិនឃើញឋានដទៃដែលជាទីរលាស់ខ្លួនចេញចាកទុក្ខតទៅទៀតនោះទេ ចំណង់ខ្លួនអ្នកដែលទើបតែកើតមានមាត់មិនទាន់បាត់ធុំក្លិនទឹកដោះផង តើនឹងដឹងអ្វីទៅ ។ នែភិក្ខុ ប្រសិនបើលោកបរិភោគលេបនូវផែនដីដោយសេចក្ដីប្រកាន់ ( **បឋវី អជ្ឈោសិស្សសិ** ) លោកឈ្មោះថាដេកនៅក្បែរខ្ញុំ ឈ្មោះថាដេកត្រាំនៅក្នុងវត្ថុរបស់ខ្ញុំ ខ្ញុំនឹងធ្វើលោកឲ្យទៅតាមសេចក្ដីប្រាថ្នារបស់ខ្ញុំ ឲ្យលោកជាមនុស្សថោកទាបក៏បាន ។

ពកព្រហ្មក្នុងពេលនោះ មានការប្រកាន់ខ្លួនខ្លាំង បានពោលពាក្យគ្របសង្កត់មករកព្រះដ៏មានព្រះភាគដូច្នេះឯង តាមសេចក្ដីដែលព្រះអដ្ឋកថាបានពន្យល់បន្ថែមផង សូម្បីក្នុងរឿងទឹក ភ្លើង ខ្យល់ ពពួកសត្វ ទេវតា បជាបតិទេវរាជ ព្រហ្ម ទាំងអស់នេះ ក៏ពកព្រហ្មបានពោលមានទំនងដូចគ្នានឹងពាក្យថា **បថវឹ អជ្ឈោសិស្សសិ** ដែរ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រហ្ម តថាគតក៏ដឹងនូវហេតុនេះដែរ គឺថាប្រសិនបើតថាគតបរិភោគលេបនូវផែនដីដោយសេចក្ដីប្រកាន់ តថាគតឈ្មោះថាដេកនៅក្បែរអ្នក ឈ្មោះថាដេកត្រាំនៅក្នុងវត្ថុរបស់អ្នក អ្នកគួរនឹងធ្វើតថាគតតាមសេចក្ដីប្រាថ្នារបស់អ្នកឲ្យតថាគតជាមនុស្សថោកទាបបានមែន ប៉ុន្តែ ម្នាលព្រហ្ម តថាគតដឹងច្បាស់នូវផែនដី ថាជាផែនដីពិត ( គឺព្រះអង្គទ្រង់ដឹងច្បាស់ដោយបរិញ្ញា ៣ ដូចនៅក្នុងមូលបរិយាយសូត្រ ) ដឹងច្បាស់នូវព្រះនិព្វានដែលសត្វមិនធ្លាប់ដល់ដោយសភាពនៃផែនដី បានជាតថាគតមិនប្រកាន់នូវផែនដីថាជារបស់តថាគត មិនប្រកាសផែនដី ( ក្នុងព្រះនិព្វាន ) ។

ក្នុងពាក្យថា **បថវិយា បថវិត្តេន អននុភូតំ** ប្រែថា ព្រះនិព្វានដែលសត្វមិនធ្លាប់ដល់ គឺដល់មិនបាន ព្រោះការប្រកាន់ដីថាជាដី ដោយសេចក្ដីថា ព្រះនិព្វាននោះឈ្មោះថា **អននុភូតំ** គឺសត្វ

មិនអាចទៅដល់បានដោយការប្រកាន់ថាជាផែនដី ព្រោះព្រះនិព្វាន ផុតចាកអំពីសភាវៈដែលត្រូវតាក់តែងដោយបច្ច័យគ្រប់យ៉ាង ។

ពាក្យថា **តទភិញ្ញាយ** គឺដឹងច្បាស់នូវព្រះនិព្វាន ។

នៅក្នុងមូលបរិយាយសូត្រ ចំពោះបុថុជ្ជន មិនមានបរិញ្ញា ៣ ក្នុងបឋវីជាដើម ទើបនាំឲ្យមានសេចក្ដីប្រកាន់ដោយអំណាចតណ្ហា មានះនិងទិដ្ឋិ ចំណែកព្រះដ៏មានព្រះភាគ ទ្រង់មិនចាប់យកផែនដី ដោយសេចក្ដីប្រកាន់យ៉ាងណានោះឡើយ ទើបព្រះអង្គទ្រង់ត្រាស់ ជាបន្តថា ម្នាលព្រហ្ម កាលបើយ៉ាងនេះ តថាគតមិនមែនជាបុគ្គល ស្មើនឹងអ្នកទេ តថាគតត្រាស់ដឹងហើយ នឹងឲ្យថោកថយជាងអ្នក ដូចម្ដេចបាន តថាគតត្រូវតែប្រសើរជាងអ្នកដោយពិត ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់រំលឹកព្រហ្មថា ម្នាលព្រហ្ម តថាគតស្គាល់គតិរបស់អ្នក ស្គាល់អានុភាពរបស់អ្នកហើយថា ពក-ព្រហ្មមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ មានស័ក្តិធំយ៉ាងនេះ ។ ពកព្រហ្មទូលសួរព្រះដ៏មានព្រះភាគអំពីគតិរបស់ខ្លួន និងអានុភាពរបស់ខ្លួន តើដោយប្រការដូចម្ដេច ទើបព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់ឆ្លើយតបមាននៅក្នុងព្រះសូត្រស្រាប់ហើយ ។

ពកព្រហ្ម ធ្លាប់បួសជាតាបសមានឫទ្ធិអភិញ្ញាច្រើន ធ្លាប់ជួយ

អ្នករទេះគោរាប់រយឲ្យបានទឹកបរិភោគ ធ្លាប់ជួយអ្នកស្រុកទាំងភូមិ ដែលត្រូវពួកចោរប្លន់ ធ្លាប់ជួយអ្នកធ្វើដំណើរដោយទូកតាមទន្លេគង្គា ឲ្យផុតពីគ្រោះថ្នាក់ និងធ្លាប់ជាតាបសឈ្មោះកេសវៈ ដែលមានព្រះបរមពោធិសត្វឈ្មោះកប្បៈ ជាកូនសិស្សដ៏ពូកែឆ្លាតទៀតផង ។ ពកព្រហ្មនេះ ធ្លាប់កើតនៅព្រហ្មវេហប្ផលា មានអាយុ ៥០០ កប្ប ចុតិមកកើតនៅព្រហ្មសុភកិណ្ហា មានអាយុ ៦៤ កប្ប រួចហើយចុតិមកកើតនៅព្រហ្មអាភស្សរា មានអាយុ ៨ កប្ប បានចុតិមកកើតជាពកព្រហ្មនៅមហាព្រហ្មា ជាន់បឋមជ្ឈានភូមិ មានអាយុ ១ កប្ប នេះឯង ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ជាបន្តថា **សព្វំ ខោ អហំ ព្រហ្មេ សព្វតោ អភិញ្ញាយ** ប្រែថា ម្នាលព្រហ្ម តថាគតដឹងច្បាស់វត្ថុទាំងពួង ថាជាវត្ថុទាំងពួងពិត ( **សព្វំ** = **សក្កាយ** ) ។ **យាវតា សព្វស្ស សព្វត្តេន អននុភូតំ តទភិញ្ញាយ** ប្រែថា ដឹងច្បាស់នូវព្រះនិព្វាន ដែលសត្វមិនធ្លាប់ដល់ ដោយសភាពនៃវត្ថុទាំងពួង ថាជាវត្ថុទាំងពួង ។ **សព្វំ មេតិ នាហោសី** បានជាតថាគតមិនប្រកាន់នូវវត្ថុទាំងពួងថាជារបស់តថាគត មិនប្រកាសនូវវត្ថុទាំងពួង ( ក្នុងព្រះនិព្វាន ) ។

ព្រះដ៏មានព្រះភាគ ទ្រង់មានបរិញ្ញា ៣ ក្នុង **សព្វំ** បានដល់

**សក្កាយ** គឺឧបាទានក្ខន្ធ ៥ ឬ **តេភូមិកធម៌** គឺធម៌ប្រព្រឹត្តទៅក្នុងភូមិ ៣ ( វៀរលោកុត្តរភូមិ ) ។

ពកព្រហ្ម ស្តាប់មិនដឹងក្នុងពាក្យថា **សព្វំ** ដែលព្រះពុទ្ធអង្គត្រាស់សំដៅដល់តេភូមិកធម៌ គឺឧបានក្ខន្ធ ៥ នេះទេ ដោយពកព្រហ្មគិតថា **សព្វសព្វំ** គឺអ្វីៗទាំងឡាយទាំងពួង សុទ្ធតែមិនអាចចូលដល់ព្រះនិព្វានអ៊ីចឹង តើវាមានការរលាស់ខ្លួនចេញចាកទុក្ខក្នុងទីណាបានទៅ ទើបពកព្រហ្មពោលគ្របសង្កត់ព្រះដ៏មានព្រះភាគថា ព្រះអង្គទ្រង់ពោលកុហក ដោយពាក្យព្រហ្មដែលបានពោលថា បពិត្រព្រះអង្គទ្រង់និរទុក្ខ បើព្រះអង្គដឹងនូវព្រះនិព្វានដែលសត្វមិនអាចដល់បានដោយសភាពនៃវត្ថុទាំងពួងហើយ សូមកុំឲ្យពាក្យរបស់ព្រះអង្គសោះសូន្យទទេ ឥតអំពើឡើយ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អំពីព្រះនិព្វានគឺ

**វិញ្ញាណំ** គប្បីដឹងច្បាស់បាន ព្រោះថាព្រះនិព្វានជាអារម្មណ៍ដែលគប្បីធ្វើឲ្យជាក់ច្បាស់បាន ។

**អនិទស្សនំ** គឺមិនអាចមើលឃើញដោយចក្ខុវិញ្ញាណបានឡើយ ព្រោះមិនមែនជារូបារម្មណ៍ ។

**អនន្តំ** គឺមិនមានទីបំផុត ព្រោះមិនមានការកើតនិងការរលត់ ។

**សព្វតោបភំ** គឺសម្បូណ៌ដោយភាពភ្លឺស្វាងក្នុងទីទាំងពួង ដោយប្រការទាំងពួង មិនមានអ្វីដែលភ្លឺស្វាងដូចឡើយ ( មិនមែនពន្លឺដែលជារូបារម្មណ៍ទេ តែនេះជាអារម្មណ៍របស់ញាណដ៏ភ្លឺស្វាង ) ម្យ៉ាងទៀត **បភំ** នេះ ជាឈ្មោះនៃកំពង់ ដោយសេចក្តីថា ព្រះនិព្វានមានកំពង់គ្រប់កន្លែង បានដល់កំពង់គឺកម្មដ្ឋានទាំងពួង ( សមថយានិក វិបស្សនាយានិក ) ។

ព្រះនិព្វាន សត្វមិនអាចដល់បានដោយសភាពនៃដី ទឹក ភ្លើង ខ្យល់ ។ល។ មិនអាចដល់បានដោយសភាពនៃវត្ថុទាំងពួង ប៉ុន្តែព្រះនិព្វាន បុគ្គលសម្រេចបានដោយការកំណត់ដឹងនូវទុក្ខ ដែលជាឧបាទានក្ខន្ធ ៥ ហើយរំលត់តណ្ហាដែលជាហេតុនៃទុក្ខបាន ដោយអរិយមគ្គ ។

ពកព្រហ្ម មិនមានពាក្យអ្វីដើម្បីនឹងសង្កត់សង្កិនព្រះដ៏មាន-ព្រះភាគតទៅទៀត ចង់បំបាំងកាយគេចខ្លួន តែព្រះពុទ្ធអង្គទ្រង់ធ្វើមិនឲ្យបំបាំងកាយបានឡើយ មានតែព្រះអង្គប៉ុណ្ណោះ ដែលពេលនោះទ្រង់បានបំបាំងព្រះកាយមិនអាចឲ្យព្រហ្មទាំងឡាយមើលឃើញ ហើយព្រះអង្គទ្រង់ប្រកាសសម្តែងសច្ចធម៌ ឲ្យពួកព្រហ្មដឹងថា ព្រះ-អង្គទ្រង់គង់នៅទីដដែលហ្នឹងឯង តែមើលព្រះអង្គមិនឃើញ នាំគ្នា

អស្វាស្សក្នុងចិត្តផង ស្តាប់ព្រះធម៌ផង ដោយព្រះអង្គទ្រង់ត្រាស់ថា

**ភវេវាហំ ភយំ ទិស្វា ភវញ្ច វិភវេសិនំ**
**ភវំ នាភិវទឹ កិញ្ចិ នន្ទិញ្ច ន ឧបាទិយន្តិ ។**

តថាគតឃើញភ័យក្នុងភព និងឃើញភពរបស់សត្វដែលជាអ្នកស្វែងរកទីដែលប្រាសចាកភពហើយ មិនបានពោលសរសើរនូវភពណាមួយ ទាំងមិនប្រកាន់នូវភវតណ្ហាឡើយ ។

ក្នុងព្រះគាថានេះ មានអដ្ឋកថាថា ព្រះតថាគតឃើញភ័យក្នុងភពដោយពិត ទាំងបានឃើញភពរបស់សត្វទាំង ៣ មានកាមភពជាដើម ដែលបុគ្គលស្វែងរកទីប្រាសចាកភព ហើយនៅតែក្នុងភពនោះឯងរឿយៗ ចំណែកព្រះអង្គ មិនបានលើកតម្កើងភព សរសើរភព គឺមិនស្វែងរកភពណាៗ ដោយអំណាចនៃតណ្ហានិងទិដ្ឋិឡើយ ហើយព្រះអង្គទ្រង់មិនប្រកាន់នូវនន្ទិដែលជាតួភវតណ្ហានេះទេ ។

នៅពេលចប់ព្រះធម៌ទេសនា ព្រហ្មប្រមាណ ១ ហ្មឺនអង្គ មានវិបស្សនាតាមក្រសែធម៌ ហើយបានក្រេបផឹកនូវទឹកអម្រឹត ពោលគឺសម្រេចមគ្គផលជាលោកុត្តរធម៌ ។

នៅក្នុងព្រះសូត្រនេះ ក៏មានតួអង្គមារចូលរួមផងដែរ ប៉ុន្តែមិនអាចរារាំងព្រះដ៏មានព្រះភាគក្នុងព្រះពុទ្ធដំណើរប្រោសពពួកព្រហ្មមានពកព្រហ្មជាដើមនេះបានឡើយ ។ ដោយពកព្រហ្មបានអារាធនា

យាងព្រះដ៏មានព្រះភាគ ក្នុងពេលដែលព្រះអង្គទើបតែយាងទៅដល់ ក្នុងកិច្ចបដិសណ្ឋារៈផង អារាធនាយាងព្រះអង្គឲ្យសម្ដែងអំពីគតិនិង អានុភាព ព្រមទាំងបុព្វកម្មរបស់ខ្លួនផង ទើបព្រះសូត្រនេះមាន ឈ្មោះថា ព្រហ្មនិមន្តនិកសូត្រ ។

សូមអនុមោទនា !

## ពាក្យរបស់ពកព្រហ្មក្នុងពកសូត្រ

( បិដកលេខ ៣០, ទំព័រលេខ ៤៣ )

**អនន្តទស្សី ភគវាហមស្មិ**
**ជាតិជរំ សោកមុបាតិវត្តោ**
**កឹ មេ បុរាណំ វតសីលវត្តំ**
**អាចិក្ខមេតំ យមហំ វិជញ្ញាតិ ។**

ពកព្រហ្ម ទូលថា បពិត្រព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ ឃើញនូវអារម្មណ៍មិនមានទីបំផុត ប្រព្រឹត្តកន្លងនូវជាតិ ជរានិង សេចក្តីសោក តើសីលវត្តរបស់ខ្ញុំព្រះអង្គអំពីមុនដូចម្តេច ខ្ញុំព្រះអង្គ អាចដឹងច្បាស់នូវសីលវត្តណា សូមព្រះអង្គទ្រង់ត្រាស់ប្រាប់នូវ

សីលវត្តនោះ ដល់ខ្ញុំព្រះអង្គ ។

## ព្រះពុទ្ធអង្គទ្រង់ត្រាស់ប្រាប់ពកព្រហ្ម

អ្នកបានញុំាងមនុស្សដ៏ច្រើនដែលស្រេកទឹក ត្រូវកម្តៅថ្ងៃគ្របសង្កត់ក្នុងរដូវក្តៅ ឲ្យបានទឹកបរិភោគ ដោយហេតុណា ហេតុនោះ ជាសីលវត្ត មានមកអំពីដើមរបស់អ្នក តថាគតរលឹកបាន ដូចបុគ្គលដេកលក់ហើយភ្ញាក់ឡើង ដូច្នោះឯង ។

អ្នកបានញុំាងពពួកជន ដែលត្រូវចោរចាប់នៅឆ្នេរទន្លេគង្គា ឈ្មោះឯណិ ដើម្បីនាំទៅធ្វើជាឈ្លើយ ឲ្យរួចខ្លួនបាន ដោយអំពើណា អំពើនោះ ជាសីលវត្ត មានមកអំពីដើមរបស់អ្នក តថាគតរលឹកបាន ដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង ។

អ្នកបានញុំាងទូកដែលនាគរាជកំណាច កំហែងចាប់ដោយកម្លាំង ត្រង់ខ្សែទឹកនៃទន្លេគង្គា ឲ្យរួចខ្លួនបាន ដោយសេចក្តីអនុគ្រោះដល់មនុស្ស អំពើនោះ ជាសីលវត្ត មានមកអំពីដើមរបស់អ្នក តថាគតរលឹកបាន ដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង ។

ពីដើមតថាគត ឈ្មោះកប្បៈ ជាកូនសិស្សរបស់អ្នក រាប់អាន

អ្នកជាបុគ្គលមានប្រាជ្ញាល្អ បរិបូណ៌ដោយវត្ត អំពើនោះ ជាសីលវត្ត មានមកអំពីដើមរបស់អ្នក តថាគតរលឹកបាន ដូចជាបុគ្គលដេកលក់ ហើយភ្ញាក់ឡើង ដូច្នោះឯង ។

## ពកព្រហ្មទូលថា

ព្រះអង្គទ្រង់ជ្រាបនូវអាយុនោះ របស់ខ្ញុំព្រះអង្គដោយពិតម្យ៉ាងទៀត អ្វីៗដទៃទៀតទាំងអស់ ព្រះអង្គក៏ទ្រង់ជ្រាបបាន ព្រោះព្រះអង្គជាព្រះពុទ្ធ ព្រោះហេតុដូច្នោះ ទើបអានុភាពរបស់ព្រះអង្គរុងរឿង ញ៉ាំងព្រហ្មលោកឲ្យភ្លឺស្វាងហើយឋិតនៅ ។

## សិរីសួស្តីនៃជីវិត

មនុស្សដែលឃើញគុណតម្លៃនៃជីវិតរបស់យើង គឺជាមនុស្សដែលយើងចង់រស់នៅជាមួយ យើងវិញក៏ដូច្នោះដែរ ត្រូវរៀនមើលគុណតម្លៃរបស់មនុស្ស ត្រូវចេះឲ្យតម្លៃគុណដោយការដឹងគុណនិងប្រកបដោយមេត្តាធម៌ ។ សរុបមក មនុស្សយើងត្រូវចេះសាងគុណ

តម្លៃឲ្យដល់ខ្លួនឯង ជីវិតមានសិរីសួស្តី ព្រោះជីវិតមាននូវគុណតម្លៃនេះឯង មានជាតួយ៉ាងស្រាប់ ដូចជាពកព្រហ្មជាដើម ដែលជាបុគ្គលមានសិរីសួស្តី ព្រោះមានគុណតម្លៃដែលបានសន្សំទុកមក ទើបធ្វើឲ្យព្រះពុទ្ធអង្គស្តេចយាងទៅប្រោស ប្រតិស្ឋានក្នុងភូមិព្រះអរិយៈ ។

## ត្រូវចេះរស់នៅក្នុងទីដ៏សមគួរ

ស្មៅដុះនៅផើងផ្កា គេមិនត្រូវការ គេដកចេញ គេថែតែដើមផ្កាក្នុងផើងនោះប៉ុណ្ណោះ ប៉ុន្តែមានស្មៅដែលគេដាំ គេថែក្នុងទីវាលកន្លែងខ្លះគេមិនឲ្យមនុស្សដើរជាន់លើទៀតផង សេចក្តីនេះយ៉ាងណាមនុស្សយើងគួរតែចេះរស់នៅក្នុងទីដ៏សមគួរ សមនឹងចំណេះដឹងសមនឹងគុណតម្លៃ ទើបជីវិតមានសិរីសួស្តី ។

## ធ្វើដើមផ្កាត្រូវបញ្ចេញផ្កា

មនុស្សយើងដែលមានគេស្រឡាញ់ចូលចិត្ត គឺដូចជាដើមផ្កាដែលគេដាំក្នុងផើង គេមើលគេថែព្រោះគេស្រឡាញ់ផ្កា ក្នុងសេចក្តី

នេះ គឺយើងមិនត្រូវភ្លេចឡើយថា អ្នកដែលស្រឡាញ់យើងជាងគេគឺខ្លួនយើង ដូច្នេះដើម្បីឲ្យយើងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការមើលថៃខ្លួនឯង គឺយើងត្រូវតែមាននូវចំណេះដឹងនិងគុណធម៌ ចំណេះដឹងនិងគុណធម៌ ប្រៀបដូចជាផ្កាដែលមានពណ៌ស្រស់ស្អាត និងមានក្លិនក្រអូប សមគួរនឹងថ្វាយព្រះ ។ មនុស្សយើងដែលខ្វះចំណេះដឹងនិងគុណធម៌ រមែងដូចជាដើមផ្កាដែលអត់មានផ្កាដូច្នោះឯង ។

## រឿងដែលលាយគ្នាមិនបាន

ថ្នាំពេទ្យខ្លះ ឬចំណីអាហារខ្លះ អាចបរិភោគផ្សេងគ្នាបាន តែមិនអាចបរិភោគចូលគ្នាបានទេ វាធ្វើឲ្យឈឺឬដល់ថ្នាក់ស្លាប់ទៀតផងយ៉ាងណា បេះដូងបុរសស្ត្រី ដែលបានទទួលសេចក្តីស្រឡាញ់អំពីគ្នាមកនោះ ធ្វើឲ្យដឹងខ្លួនថាមានការរីករាយ ប៉ុន្តែកាលពីមិនទាន់បានទទួលនូវសេចក្តីស្រឡាញ់ ក៏មិនមានអ្វីជាទុក្ខសោកដែរ គ្រាន់តែថា កុំឲ្យសេចក្តីស្រឡាញ់និងការមិនស្រឡាញ់ដែលចូលមកតាមក្រោយវានៅលាយគ្នាឲ្យសោះ ព្រោះវានឹងបង្កទៅជាពិសវាយប្រហារបេះដូងនោះឯង ត្រូវតែចាក់ចោលនូវសេចក្តីស្រឡាញ់ស្នេហាដែល

គេបានដាក់ចូលមកមុននោះ ឲ្យអស់ពីបេះដូង ទើបវាមិនលាយគ្នាជាមួយនឹងការមិនស្រឡាញ់ដែលគេដាក់មកតាមក្រោយ គឺវាមិនមានប្រតិកម្មអ្វីឲ្យឈឺចាប់នោះទេ សេចក្តីនេះ បើពោលតាមអភិធម្ម គឺជាសញ្ញាចាំរឿង ។ កាមសញ្ញាចាំរឿងអតីតកាល យករឿងអតីតកាលនោះមកលាយគ្នានឹងរឿងបច្ចុប្បន្ន ធ្វើឲ្យមានប្រតិកម្មធ្ងន់ធ្ងរណាស់ ដូច្នេះត្រូវតែលះបង់នូវកាមសញ្ញានោះចេញ រស់នៅជាមួយនឹងបច្ចុប្បន្នដោយបញ្ញា មានការពិតជាអារម្មណ៍ ទើបបាននូវសេចក្តីសុខស្ងប់ចម្រើនឡើង ។

## លះបង់កាមសញ្ញា

រូបកាយដូចជាមន្ទីរពេទ្យ សេចក្តីទុក្ខសោកប្រៀបដូចជារោគ ឯកាមសញ្ញាជាសមុដ្ឋាននៃរោគ យើងលំបាកនឹងលះបង់នូវកាម-សញ្ញានេះណាស់ ណាមួយនឹកអាល័យទឹកចិត្តស្រឡាញ់របស់ខ្លួនឯងដែរ ណាមួយទៀត នឹកអាល័យខ្លួនប្រាណជាដើម ដូច្នេះត្រូវព្យាយាមសិក្សាប្រតិបត្តិព្រះធម៌ ដើម្បីកម្ចាត់បង់នូវសមុដ្ឋានរបស់រោគនោះឯង គឺត្រូវតែឲ្យបាននូវបញ្ញាកំណត់ដឹងថា អ្វីៗក្នុងលោកមាន

ការវិនាសទៅ អស់ទៅជាម្ចាស់ មិនមានអ្វីជារបស់យើងឡើយ យើងមិនមាន អ្នកដទៃក៏មិនមានដែរដោយបរមត្ថនោះ ។

# កំណាព្យស្មៅក្នុងផើងផ្កា

ស្មៅក្នុងផើងផ្កាវាសនាអាប់ គេដកប្រញាប់ឆាប់ឲ្យងាប់
គេខំថែផ្កាចិន្តាគាប់ ផ្កាល្អមានភ័ព្វគេរាប់អាន ។
មនុស្សយើងរស់នៅត្រូវសិក្សា ជុំវិញយ៉ាងណាការសមប្រាណ
គេឲ្យតម្លៃថ្លៃថ្កើងថ្កាន នោះទើបជាឋានបានសួស្តី។
ការឲ្យតម្លៃសេចក្តីល្អ នេះជាគុណធម៌គួរគប្បី
អប់រំសន្សំសាងបារមី លះធម៌អប្រីយ៍លុះព្រហ្មចារ្យ។
មួយចំណេះដឹងពីរគុណធម៌ គួគាប់បវរល្អដូចផ្កា
ទាំងពណ៌ទាំងក្លិនប៉ិនរចនា មានគេត្រូវការឲ្យតម្លៃ ។
រស់រៀនសម្លឹងដឹងគុណទោស ឃើញខ្លួនឯងខុសខំកែខៃ
សម្លឹងមើលគុណអ្នកដទៃ គុណតិចច្រើនក្តីគប្បីនឹក ។
ចិត្តខឹងចិត្តខូចដូចហាលថ្ងៃ តស្សាចង្រៃក្រែស្រេកទឹក
គុណអ្នកដទៃលៃរលឹក គឺបានក្រេបផឹកទឹកមេត្តា ។
នឹករឿងស្នេហាក្តៅផ្សាពិត មិនបានដូចចិត្តគិតប្រាថ្នា

កើតរោគហួងហែងរឿងរៀបការ បាត់បង់ស្នេហាឱភាពេល ។
ទឹកដមស្រឡាញ់វេញចូលគ្នា គួរនាដូចជាការញីឈ្មោល
ជាប់ស្អិតក្នុងចិត្តមិនអាចចោល ប្រចណ្ឌផុតពេលរាលប្រហារ។
ព្រោះហេតុតែល្ងង់លង់អារម្មណ៍ ធម៌អភិធម្មមិនសិក្សា
ចង់យកឈ្នះចាញ់រឿងស្នេហា ដណ្ដើមកាមាបានការអ្វី ។
មានរឿងសន្ទឹកនឹកឲ្យសុខ លះរឿងស្មាញស្មុគគុកលោកីយ៍
កបដោយសទ្ធាគុណកែវបី ជាមនុស្សសិរីរួចចាករោគ ។
ចាំបាច់បានអ្វីពីមនុស្សម្នាក់ រួចពីអន្ទាក់ជាក់ជ័យជោគ
ទាំងឲ្យអភ័យរឿងវិយោគ រឿងផុតចាកលោកទើបសំខាន់។
នឹករឿងពីក្មេងរត់លេងដី ក្មេងប្រុសក្មេងស្រីគ្មានប្រកាន់
គ្មានរឿងស្នេហាគ្មានប្រចណ្ឌ រឿងដែលសំខាន់រឿងញ៉ាំនំ។
លុះធំបន្តិចមានមិត្តភ័ក្តិ មានរឿងជំពាក់នឹងក្រមុំ
មានរឿងស្នេហារឿងគំនុំ កិលេសឡើងធំគុំធ្វើខ្លាំង ។
ជារដូវកាលនៃជីវិត ក្លាយជាអតីត[១]វស្សាប្រាំង
ដល់វ័យចាស់ខ្សោះអស់កម្លាំង មិនអាចតតាំងនឹងជរា ។
កុំចង់ដូចស្មៅនៅធើងផ្កា សុខក្នុងលោកាមិនយូរយារ
មានជួបមានព្រាត់សែនរងា សាងផ្នួសសូមលាឈប់ជួបទៀត។

១ - អានថា អឌិត

ស្វែងរកក្ដីស្ងប់មកដាក់ខ្លួន លះការគុំកួនកាមមិនបៀត
ចិត្តធំទូលាយមិនចង្អៀត អស់ការកើតទៀតផុតទុក្ខហោង៕

ដោយ **ម.ស.ទ.**

## រៀនរស់នៅជាមួយនឹងបច្ចុប្បន្នឲ្យបានល្អ

យើងមិនអាចកែខែអ្វីៗជាអតីតកាលបានទេ ប៉ុន្តែ យើងអាចកែ យើងអាចដោះស្រាយសេចក្ដីទុក្ខដែលមានរឿងអតីតជាអារម្មណ៍បាន ដោយការរស់នៅជាមួយបច្ចុប្បន្នឲ្យបានល្អ ។ អតីតកាលកន្លងទៅ ប្រៀបដូចអ្នកស្លាប់បាត់បង់ជីវិតចោលយើងទៅដូច្នោះឯង យើងមិនអាចត្រឡប់ទៅរស់នៅក្នុងអតីតកាលវិញបានឡើយ ដូច្នេះយើងមានតែរៀនរស់នៅឲ្យបានសុខជាមួយនឹងអារម្មណ៍បច្ចុប្បន្នហ្នឹងឯង ខំធ្វើបច្ចុប្បន្នឲ្យបានល្អដើម្បីយើងរស់នៅជាមួយបានសុខ និងបានល្អតទៅមុខទៀត ក្នុងដំណើររួចផុតចាកទុក្ខ ។

# ១០. មារតជ្ជនីយសូត្រ

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងភេសកឡាវ័ន ជាទីឲ្យអភ័យដល់ម្រឹគ ជិតក្រុងឈ្មោះសុំសុមារគិរៈ ក្នុងភគ្គជនបទ ។ គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុចង្ក្រមក្នុងទីវាល ហើយមារមានចិត្តបាបបានចូលទៅនៅក្នុងផ្ទៃ សំងំក្នុងពោះវៀនរបស់ព្រះមហាមោគ្គល្លាន ។

កាលដែលព្រះមហាមោគ្គល្លានដ៏មានអាយុ បានជ្រាបថាជាមារហើយ មារក៏ចេញមកក្រៅឋិតនៅត្រង់សន្ទះទ្វារ ។ កាលពីមារនៅខាងក្នុងផ្ទៃ ព្រះមហាមោគ្គល្លានត្ថេរបានទូន្មានមារថា កុំឲ្យបៀតបៀនព្រះតថាគត កុំបៀតបៀនសាវ័កព្រះតថាគតឡើយ ការបៀតបៀនដែលប្រព្រឹត្តទៅដើម្បីសេចក្តីមិនចម្រើន ដើម្បីសេចក្តីទុក្ខអស់កាលជាអង្វែង កុំមានដល់អ្នកឡើយ ម្នាលមារមានចិត្តបាប អ្នកចូរចេញទៅ ។

ពាក្យថា **មា តថាគតំ វិហេសេសិ** កុំបៀតបៀនព្រះតថាគត ដោយសេចក្តីថា កាលដែលសាវ័ករបស់ព្រះតថាគត

ត្រូវបៀតបៀន ព្រះតថាគតក៏ឈ្មោះថា ត្រូវបៀតបៀនផងដែរ ប្រៀប ដូចជាកូនៗត្រូវគេបៀតបៀន ក៏ជាការបៀតបៀនដល់មាតាបិតា របស់កូនហ្នឹងឯង ដូច្នេះទើបព្រះមហាថេរ ពោលថា អ្នកកុំបៀតបៀន ព្រះតថាគតឡើយ ។

នៅពេលមារចេញមកខាងក្រៅ ព្រះមហាមោគ្គល្លានដ៏មាន-អាយុ បានសម្តែងអំពីប្រវត្តិរបស់លោកគឺប្រវត្តិរបស់ព្រះមហា-មោគ្គល្លានហ្នឹងឯង ធ្លាប់កើតជាមារឈ្មោះទូសី ក្នុងសាសនា ព្រះសម្មាសម្ពុទ្ធកកុសន្ធោ ក្នុងកាលនោះ ប្អូនស្រីរបស់ទូសីមារ ឈ្មោះនាងកាឡី ចំណែកមារជាកូនប្រុសរបស់នាងកាឡី ត្រូវជា ក្មួយរបស់ទូសីមារ បានសេចក្តីថា មារាធិរាជ ធ្លាប់ជាក្មួយបង្កើត របស់ព្រះមហាមោគ្គល្លានត្ថេរ ។

ក្នុងកាលនោះ ទូសីមារបានសម្តែងឲ្យអ្នកស្រុកឃើញនូវ អារម្មណ៍ដែលនាំឲ្យក្តៅក្រហាយចិត្តផ្សេងៗ គឺធ្វើឲ្យឃើញភិក្ខុ ទាំងឡាយចាប់ត្រី បាញ់សត្វ បណ្តើរស្រី អង្គុយនៅរោងស្រា រាំ ច្រៀងផ្សេងៗជាដើម ដែលធ្វើឲ្យអ្នកស្រុកនិយាយប្រាប់គ្នាហើយ ឈប់ប្រគេនចង្ហាន់ព្រះសង្ឃ គិតតែពីជេរដោយពាក្យអាក្រក់ៗដល់ ភិក្ខុអ្នកមានសីលទាំងឡាយ គឺជាការប្រព្រឹត្តបាបដោយចេតនាខ្លួន ឯង ត្រូវស្លាប់ទៅធ្លាក់នរក ប្រេត តិរច្ឆាន អសុរកាយ ។ ទូសីមារ

ធ្វើដូច្នេះ ព្រោះមានបំណងឲ្យភិក្ខុទាំងឡាយមានចិត្តរាយមាយ ទើប ក្នុងកាលនោះ ព្រះកកុសន្ធោសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ទូន្មានភិក្ខុទាំងឡាយឲ្យចម្រើននូវមេត្តាព្រហ្មវិហារជាដើម មានចិត្តប្រកបដោយមេត្តាដ៏ទូលំទូលាយ ជាមហគ្គត ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោកដែលមានសត្វទាំងអស់ ដោយយកខ្លួនឯងប្រៀបនឹងសត្វទាំងអស់ ក្នុងទីទាំងពួង គឺទិសខាងលើ ទិសខាងក្រោមនិងទិសទទឹងដោយជុំវិញ ។ ភិក្ខុទាំងឡាយ តាំងនៅក្នុងឱវាទព្រះពុទ្ធអង្គ ចម្រើននូវព្រហ្មវិហារទាំង ៤ មានឈានជាបាទនៃវិបស្សនា សម្រេចព្រះអរហត្ត ។

កាលដែលទូសីមារមិនបានសម្រេចបំណង ក៏មកសម្តែងអារម្មណ៍ដែលធ្វើឲ្យអ្នកស្រុកជ្រះថ្លាវិញម្តង គឺសម្តែងភិក្ខុទាំងឡាយនិមន្តទៅក្នុងអាកាស សម្រេចឥរិយាបថនិងកិច្ចការផ្សេងៗ មានសម្តែងធម៌ជាដើម សុទ្ធតែនៅក្នុងអាកាស មានទាំងសាមណេរតូចៗដល់ព្រមដោយឫទ្ធិ ដែលធ្វើឲ្យអ្នកស្រុកជ្រះថ្លាក្រៃលែង ថ្វាយបច្ច័យ ៤ ធ្វើបុណ្យជាមួយនឹងព្រះភិក្ខុមានសីលទាំងឡាយ សាងផ្លូវទៅកាន់ទេវលោក ដោយចេតនារបស់ខ្លួនឯងពិតៗ ។ ក្នុងកាលនោះ ព្រះសម្មាសម្ពុទ្ធសម្តែងធម៌ឲ្យភិក្ខុទាំងឡាយ ចម្រើនអសុភកម្មដ្ឋាន អាហារេបដិកូលសញ្ញា សព្វលោកេអនភិរតសញ្ញា និង សព្វ-

សង្ខារេសុ អនិច្ចានុបស្សនា ។

ក្នុងគ្រានោះដែរ ព្រះកកុសន្ធោសម្មាសម្ពុទ្ធ ទ្រង់ស្ដេចយាងបិណ្ឌបាត មានព្រះវិធុរអគ្គសាវ័កស្ដាំជាបច្ឆាសមណៈ ស្រាប់តែទូសីមារបានចូលជ្រែកសរីរៈកូនក្មេងម្នាក់ កាន់យកដុំថ្មចោលទៅត្រូវចំសីសៈព្រះវិធុរៈដ៏មានអាយុបែកចេញឈាមហូររហាម ព្រះសម្មា-សម្ពុទ្ធទ្រង់បែរព្រះវរកាយទតមើលមកក្រោយ ហើយទ្រង់ត្រាស់ថា **ន វា យំ ទូសី មារោ មត្តមញ្ញាសីតិ** ទូសីមារនេះ មិនដឹងប្រមាណឡើយ ដោយសេចក្ដីថា ទូសីមារនេះធ្វើបាប ដោយមិនបានដឹងប្រមាណ គឺបានធ្វើការប្រព្រឹត្តកន្លងនូវប្រមាណហើយ ។ ព្រមដោយការបែរព្រះវរកាយនៃព្រះពុទ្ធអង្គក្នុងពេលនោះ ទូសីមារក៏បានច្យុតចាកអត្តភាពរបស់ខ្លួនក្នុងទីនោះឯង ហើយក៏បដិសន្ធិក្នុងមហានរក ។

ព្រះមហាមោគ្គល្លានត្ថេរ បានគំរាមមារាធិរាជនៅខាងចុងនៃព្រះសូត្រថា ភ្លើងមិនដែលគិតថា អាត្មាអញនឹងឆេះបុគ្គលពាលម្ដងណាឡើយ ប៉ុន្តែបុគ្គលពាលចេះតែមកប៉ះពាល់ភ្លើងដែលកំពុងឆេះសន្ធោសន្ធៅ ហើយភ្លើងនោះក៏ឆេះទៅ យ៉ាងណា ម្នាលមារមានចិត្តបាប អ្នកឯងបៀតបៀនព្រះតថាគត គង់នឹងឆេះខ្លួនដោយខ្លួនឯងដូចជា បុគ្គលពាលប៉ះពាល់ភ្លើង យ៉ាងនោះដែរ ។ ម្នាលមារ បើអ្នក

បៀតបៀនព្រះតថាគតហើយ គង់នឹងបានបាបពុំខាន អ្នកឯងស្មានថាបាបមិនឲ្យផលដល់អាត្មាអញដូច្នេះឬ ម្នាលមារមានចិត្តបាប អ្នកឯងត្រូវដឹងថា បាបពិតជាឲ្យផលដល់អ្នកធ្វើបាប ឯបុគ្គលដែលសន្សំនូវបាបនោះ រមែងកន្ទក់កន្ទេញអស់កាលដ៏យូរអង្វែង ម្នាលមារ អ្នកចូរគេចចេញអំពីព្រះពុទ្ធអង្គទៅ កុំនៅបៀតបៀនពួកភិក្ខុឡើយ ។ ភិក្ខុគឺព្រះមហាមោគ្គល្លានដ៏មានអាយុ បានគំរាមមារក្នុងព្រៃភេសកឡាវ័នដូចបានរៀបរាប់មកនេះឯង រួចហើយ មារាធិរាជក៏មានចិត្តអាក់អន់គេចបាត់អំពីទីនោះទៅ ។

សូមអនុមោទនា !

# កំណាព្យវាចាធម្មតានមានឥទ្ធិពល

ជួបគ្នារាល់ថ្ងៃត្រូវលៃលក      កុំឲ្យកាន់យករករឿងឈ្លោះ
មុខមាត់វាចាការអនុគ្រោះ      បើមិនដូច្នោះរស់រងទុក្ខ ។
ក្រោធមានកម្លាំងខ្លាំងអស្ចារ្យ      ទម្លាយស្នេហាបានគ្រប់មុខ
អាវុធវាចាប្រហារសុខ      ពោលពាក្យស្នាញស្នុគគុកខ្លួនឯង។
កុំចង់បានគេល្អគ្រប់មុខ      ចង់ហួសនាំទុក្ខនាំចំបែង

ថាគេអាក្រក់ភ្លេចខ្លួនឯង ដេរគេក្តែងៗខ្លួនឯងសោះ ។
ម្តេចក៏មិនល្អខ្លួនឯងទៅ ល្អនៅក្នុងផ្លូវនៃសប្បុរស
មធុភាណីស្តីពីរោះ ក្រែងបានសប្បុរសទាំងអស់គ្នា។
កុំយកទឹកក្តៅស្រោចបន្លែ ដោយគិតថាថៃនោះពុំជា
ប្រដៅកូនចៅក្រោធគ្រប់គ្រា ប្រយ័ត្នរងាបាត់គ្នាអស់ ។
បុប្ផភាណីសម្តីផ្កា វៀរចាកមុសាបុប្ផាស្រស់
វាចាក្រអូបវៀរអសុរោះ វាចាខ្ជះខ្ជោះអស់អ្នកស្តាប់ ។
វាចាធម្មទានមានឥទ្ធិពល ស្តាប់យល់បានដល់ទីផុតស្លាប់
បងប្អូនកូនចៅត្រូវប្រញាប់ ទាន់មានធម៌ស្តាប់ឆាប់សិក្សា ។
សទ្ធាជាដៃបញ្ចេញមក ត្រងត្រាប់ស្តាប់យកអត្ថថ្លៃថ្លា
ចាក់ធ្លុះសេចក្តីដោយបញ្ញា លះការខ្វាយខ្វល់ដល់និព្វាន ៕

ដោយ **ច.ស.ទ.**

## កល្យាណមិត្ត

មនុស្សយើងសូម្បីមានកម្លាំងកាយច្រើន ប៉ុន្តែខ្វះកម្លាំងចិត្តក៏មិនអាចធ្វើអ្វីៗបានសម្រេចដែរ ផ្ទុយមកវិញ សូម្បីកម្លាំងកាយមិន

សម្បូណ៌ ឬរហូតដល់មានភាពវិកលពិការទៀតផង ប៉ុន្តែថា គេមានកម្លាំងចិត្តខ្លាំង គឺគេអាចពុះពារនូវឧបសគ្គផ្សេងៗដល់នូវសេចក្តីសម្រេចតាមបំណងបាន។ ពេលខ្លះ កម្លាំងចិត្តក៏ចាំបាច់ត្រូវអាស្រ័យបច្ច័យអំពីខាងក្រៅ មានកល្យាណមិត្តជាដើម ដូច្នេះក្នុងសភាពបែបនេះ អ្នកដែលមានមិត្តល្អ ឈ្មោះថាជាអ្នកមានភ័ព្វ មានជោគ ឬថាជាអ្នកមានបុណ្យច្រើនក៏បាន ។ ចំពោះការប្រតិបត្តិធម៌ កល្យាណមិត្តសំខាន់ណាស់ ដើម្បីជាកម្លាំងចិត្ត ម្យ៉ាងទៀត បរតោឃោសៈគឺព្រះធម៌ដែលយើងបានស្តាប់ បានរៀន និងបានទ្រទ្រង់ចាំទុកដោយល្អហ្នឹងឯង ជាកល្យាណមិត្តសំខាន់ណាស់ ព្រោះជាតំណាងព្រះបរមសាស្តា ឯចំណែកការនឹករលឹកដល់ព្រះធម៌ដែលបានទ្រទ្រង់ចាំទុកដោយល្អនោះ គឺជាការចូលគាល់ព្រះបរមសាស្តានៃពុទ្ធបរិស័ទយើងសព្វថ្ងៃនេះ ។ កាន់តែជិតណាស់ទៅទៀតនោះ កល្យាណមិត្តគឺកុសលដែលយើងបានបំពេញហើយ និងកំពុងតែបំពេញហ្នឹងឯងដែលជាឧបការឲ្យចម្រើនកម្លាំងចិត្ត មានបាមោជ្ជ បីតិ បស្សទ្ធិ សុខស្ងប់និងសមថៈ វិបស្សនា ។

# កំណាព្យមើមក្ខចប្រដូចនឹងអារម្មណ៍

ហូបក្ខចដូចគ្នាតែម្នាក់រស់ ឯម្នាក់ទៀតនោះលុះមរណា
អ្នករស់ព្រោះឆ្លាតយល់កិច្ចការ ឯអ្នកមរណាប្រាជ្ញាអាប់ ។
មើមក្ខចប្រដូចនឹងអារម្មណ៍ ធម៌អភិធម្មត្រូវខំស្តាប់
អារម្មណ៍មិនមែនល្អស្រាប់ៗ ប្រាជ្ញាចំណាប់ទើបស្តាប់បាន ។
អារម្មណ៍ល្អពិតព្រោះចិត្តបុណ្យ ទានសីលជាគុណទុនសន្តាន
បើចិត្តបាបខ្មៅគ្មានកល្យាណ អារម្មណ៍ប្រៀបបានឋាននរក ។
នេះពោលចំពោះរស់បច្ចុប្បន្ន សុខសួគ៌ទាន់ហន់មិនជាន់ភក់
ឬប្រេតតិរច្ឆានឋាននរក ត្រង់ចិត្តអាក្រក់និងចិត្តល្អ ។
ពោលតាមអភិធម្មធម៌បរមត្ថ មិនមែនជាសត្វសុទ្ធតែធម៌
អារម្មណ៍ជាឋានមិនបានល្អ ព្រោះចិត្តវឹកវរវង្វេងផ្លូវ ។
អារម្មណ៍ដែលជារមណីយៈ ព្រោះចិត្តត្រជាក់មគ្គត្រឹមត្រូវ
អារម្មណ៍កម្មដ្ឋានបានចូលជ្រៅ ដំណើរឆ្ពោះទៅកាន់និព្វាន ៕

ដោយ **ប.ស.ទ.**

## សន្តោសចំពោះរបស់ដែលបាន

ក្នុងលោកនេះ មិនមានអ្នកណាចេះតែបានអ្វីៗគ្រប់យ៉ាងតាមចិត្តប្រាថ្នាឡើយ ហើយក៏មិនមែនថាចេះតែខកចិត្តគ្រប់យ៉ាងទៅនោះដែរ ដូច្នេះដើម្បីរស់នៅឲ្យបានសុខក្នុងលោករបៀបនេះ ជាបណ្ដោះ-អាសន្ន មុននឹងទៅដល់ព្រះនិព្វាននោះ គឺត្រូវសន្តោសក្នុងរបស់ដែលបាន ព្រមទទួលក្នុងរបស់ដែលអត់ ។ សន្តោសចំពោះរបស់ដែលបានសុខសាន្តក្នុងរបស់ដែលអត់ ។

## ត្រូវប្រយ័ត្នពាក្យសម្ដី

កុំឲ្យពាក្យដែលចង់និយាយប៉ុន្មានពាក្យព្រោះខឹងនោះ ដុតរោលចិត្តខ្លួនឯងឲ្យក្ដៅក្រហាយពេញមួយថ្ងៃឡើយ ហើយក៏កុំឲ្យពាក្យប៉ុន្មានពាក្យរបស់អ្នកដទៃដែលយើងបានឮហើយ ដុតរោលចិត្តក្នុងថ្ងៃនេះផងដែរ ដែលថ្ងៃនេះគួរតែមានសេចក្ដីសុខព្រោះអារម្មណ៍ល្អៗជាច្រើនទៀត ។

## កុំភ្លេចល្អខ្លួនឯង

មនុស្សដែលស្រឡាញ់គ្នា មិនមែនទាល់តែគិតអ្វីត្រូវគ្នា ចូលចិត្តអ្វីដូចគ្នាទៅទាំងអស់នោះទេ វាដូចគ្នា ត្រូវគ្នាក្នុងរឿងធំៗហើយ ប៉ុន្តែវាមានរឿងខ្លះដែលចូលចិត្តខុសគ្នាដែរ ដូច្នេះសេចក្តីស្រឡាញ់ដែលមិនរង្គោះរង្គើ គឺនៅត្រង់ចេះយល់អធ្យាស្រ័យគ្នា ដឹងថាមនុស្សផ្សេងគ្នា ត្រូវតែខុសគ្នាខ្លះដូច្នេះឯង ម្យ៉ាងទៀតកុំចេះតែចង់ឲ្យគេល្អមករកយើងដោយសព្វគ្រប់ភ្លេចល្អខ្លួនឯងនោះ ឲ្យតែចេះសម្លឹងមើលឃើញសេចក្តីល្អរបស់គេដែលមានតាមពិតទៅបានហើយ សេចក្តីល្អដែលជាទីពឹងរបស់យើង គឺសេចក្តីល្អខ្លួនឯងទេតើ ។

## ត្រូវរក្សាចិត្តអ្នកដែលស្រឡាញ់យើង

ស្លាបប៉ាកកាអស់ទឹកខ្មៅ ខំប្រឹងសង្កត់ វាធ្វើឲ្យឆ្នូតស្នាមក្រដាសដែលសរសេរនោះ យ៉ាងណា ត្រូវប្រយ័ត្នពេលទាស់ចិត្ត អស់ទឹកចិត្តមេត្តា ហើយនិយាយឲ្យអ្នកដែលស្រឡាញ់យើងមានស្នាម

របួសក្នុងចិត្តក៏យ៉ាងនោះដែរ ។ កុំឲ្យពាក្យដែលយើងនិយាយអត់ចេះគិត ក្លាយជាកាំបិតអារចិត្តអ្នកដទៃ ។

## គ្រប់ឬមិនគ្រប់

សុខឬមិនសុខ មិនមែនវាស់គ្នាតាមមាន តាមក្រ ឬតាមល្បីមិនល្បីជាដើមនោះទេ គឺវាស់គ្នានៅត្រង់គ្រប់ឬមិនគ្រប់ ព្រោះគ្រប់គឺសុខ ឯមិនគ្រប់គឺមិនសុខ ។

## ទីបំផុតនៃសេចក្ដីប្រាថ្នា

នៅពេលដែលមានអ្នកដទៃមកជាទីស្រឡាញ់ ត្រូវតែរៀនឲ្យយល់អំពីសភាពការណ៍នៃការព្រាត់ប្រាស លុះពេលវេលានៃការបែកបាក់គ្នានោះមកដល់ យើងត្រូវតែព្រមទទួលឲ្យបាន ហើយត្រូវរស់នៅជាមួយនឹងសភាពការណ៍នេះឲ្យបាន វាមិនដូចដើមមែន តែវាក៏ជាការពិតដែរតើ ទីបំផុតនៃសេចក្ដីប្រាថ្នារបស់យើងគឺបញ្ញាចាក់ធ្លុះនូវការពិតនេះឯង ។

# ភ្ញៀវក្នុងជីវិតរបស់យើង

រូបកាយរបស់យើងគឺជាផ្ទះសម្នាក់នៃរោគ គឺថារោគដូចជាភ្ញៀវចូលចេញ ចេញចូល ជាធម្មតា ចំណែកអាយតនៈ ៦ ខាងក្នុងមានភ្នែក ត្រចៀកជាដើម ក៏ទទួលភ្ញៀវទៅតាមទ្វាររបស់ខ្លួនគ្រប់ទាំង ៦ ទ្វារ មានរូបសំឡេងជាដើម ជាភ្ញៀវមកហើយក៏ទៅ រហូតជានិច្ច ទាំងអស់នេះជាភ្ញៀវបរមត្ថតាមទ្វារ ៦ ។ ឯចំណែកភ្ញៀវបញ្ញត្តិវិញ គឺយើងអរគុណហើយ ត្រង់ដែលឃើញតម្លៃនៃជីវិតរបស់យើង ហើយបានមកស្រឡាញ់យើង លុះដល់ភ្ញៀវនោះត្រឡប់ទៅវិញ បែរខ្នងដាក់យើង ក៏យើងសូមអរគុណដែរ ត្រង់ដែលទុកឲ្យយើងឃើញគុណតម្លៃនៃជីវិតរបស់យើង ដោយខ្លួនឯង ព្រមទាំងអរគុណចំពោះសេចក្តីល្អផ្សេងៗ ដែលបានធ្វើក្នុងពេលមកស្នាក់នៅក្នុងជីវិតរបស់យើង ទាំងបានផ្តល់ឱកាសឲ្យយើងបានធ្វើល្អជាមួយទៀតផង ។ អ្វីៗដែលកើតឡើងក្នុងជីវិតរបស់យើង គឺសុទ្ធតែជាធម្មតាទាំងអស់ ។

# កុំបណ្ដោយឲ្យទុក្ខកើតឡើងងាយៗ

ទុក្ខផ្លូវចិត្តយើងរាល់ថ្ងៃ គឺទុក្ខតែជាមួយនឹងរឿងធម្មតាៗហ្នឹងឯង ដូចជាការងារ មិត្តរួមការងារ ស្ទះរថយន្តតាមទីក្រុង រាជធានី អាកាសធាតុ ។ល។ តាមពិត យើងសុទ្ធតែជាអ្នកប្រាថ្នាសេចក្ដីសុខ ដូច្នេះត្រូវកុំបណ្ដោយឲ្យចេះតែកើតទុក្ខក្នុងរឿងរាល់ថ្ងៃអ៊ីចឹងឡើយ ខំប្រឹងរកសេចក្ដីសុខសឹងណា សឹងណី ចេះមកបណ្ដោយឲ្យទុក្ខកើតឡើងងាយៗ តិចថាខឹង តិចថាច្រណែន តិចថាស្អប់... ត្រូវមានស្មារតីឡើង ពិនិត្យរកឲ្យឃើញនូវចំណុចល្អក្នុងជីវិតធម្មតារាល់ថ្ងៃ ដើម្បីមានសេរីភាពរស់នៅជាមួយនឹងសេចក្ដីសុខ កុំព្រោះតែចង់បាន ចង់ទាមទារពេកទៅនូវរបស់ដែលអត់ ធ្វើឲ្យមើលរំលងការពិតដែលជាចំណុចសំខាន់នៃសេចក្ដីសុខស្ងប់នៃជីវិតនេះឡើយ ។

# បុណ្យចោរលួចមិនបាន

អ្នកដទៃជេរយើងបាន រិះគន់និន្ទាយើងបាន មួលបង្កាច់យើងបាន តែបញ្ចុះគុណតម្លៃពិតៗក្នុងជីវិតរបស់យើងមិនបានឡើយ សូម្បី

យើងត្រូវចាស់ជរា ឈឺ ស្លាប់ ព្រាត់ប្រាស តែគុណតម្លៃនៃជីវិតដែលជាតួបុណ្យនោះ មិនចាស់ជរា មិនឈឺ មិនស្លាប់ហើយក៏មិនព្រាត់ប្រាសអំពីយើងដែរ ដូច្នេះ កាលបើយើងបានធ្វើខ្លួនឯងឲ្យមានទីពឹងហើយ ក៏មិនចាំបាច់កើតទុក្ខក្រែងថា អ្នកណាមកលួចបុណ្យយើងនោះទេ ព្រោះថាបុណ្យចោរលួចមិនបានឡើយ ។

## ត្រូវប្រយ័ត្នសេចក្ដីក្រោធ

ត្រូវប្រយ័ត្នពាក្យពោលនៅពេលខឹងក្រោធ គួរតែនៅស្ងៀមសិន ព្រោះថាដល់ពេលការខឹងក្រោធនោះ វារសាយទៅ ពាក្យដែលយើងនិយាយនៅពេលខឹងនោះ វាមិនបាត់អំពីចិត្តរបស់អ្នកស្ដាប់ឮនោះឡើយ ទោះជាយើងសូមអភ័យទោសក៏ដោយ វាមិនងាយដូចដើមនោះទេ ដូច្នេះត្រូវប្រយ័ត្នសេចក្ដីក្រោធ ព្រោះវាធ្វើឲ្យបុគ្គលជាទីស្រឡាញ់ទាំងឡាយ ក្លាយមកជាបុគ្គលគួរស្អប់ ធ្វើអ្នកមានគុណឲ្យក្លាយជាសត្រូវ ធ្វើអ្នកដែលស្រឡាញ់យើងឲ្យក្លាយមកជាអ្នកដែលយើងត្រូវស្អប់ទៅវិញ ទាំងធ្វើឲ្យពិភពលោកនេះអួរអាប់ មិនអាចឲ្យខ្លួនឯងរស់នៅបានទៀតផង ទើបមានអ្នកធ្វើអត្តឃាត ។

## បើយើងខុសមែន

បើកំហុសយើងមែនពិត យើងគប្បីកែខៃលះបង់នូវកំហុស នោះៗ នេះជាសេចក្ដីល្អរបស់យើង ដែលត្រូវទទួលបានពីការរិះគន់ រឿងកន្លងមកហើយមិនមានអ្នកណាមិនធ្លាប់ខុសទេ ព្រោះវាអាស្រ័យ កិលេសវដ្ដៈ កុំឲ្យតែវេចស្ដាយកិលេសវែងឆ្ងាយតទៅ ត្រូវធ្វើជា មនុស្សដែលគេប្រដៅបានដោយងាយ ប្រាកដជាឆាប់រួចផុតចាកទុក្ខ ក្នុងបវរនៃព្រះពុទ្ធសាសនា ។

## បើយើងអត់ខុសទេ

ពាក្យនិយាយដែលមិនពិត រិះគន់តាមទំនើងចិត្ត តាមស្អប់ តាមច្រណែន... គឺយើងមិនបាច់យកមកទុកក្នុងចិត្តទេ ថ្ងៃណាមួយ ការពិតនោះប្រាកដឡើង អ្នកដែលនិន្ទាយើង គេនឹងខ្មាសខ្លួនឯង ចំណែកយើងរឹងរឹតតែរីករាយក្នុងអំពើល្អដែលយើងបានធ្វើ ។ មាន ព្រះភិក្ខុមួយអង្គដែលទេវតាខំប្រឹងស្វែងរកទោសដាក់លោក បង្ករឿង ចោទប្រកាន់លោក ដែលធ្វើឲ្យលោកមានព្រះហឫទ័យរីករាយក្នុង

សីល ព្រោះលោកគិតថា សូម្បីតែទេវតាក៏រកទោសលោកមិនឃើញដែរ ទីបំផុតនៃព្រះហឫទ័យរីករាយក្នុងសីល ព្រះភិក្ខុអង្គនោះ ក៏សម្រេចព្រះអរហត្ត នៅចំពោះមុខទេវតាដែលកំពុងតែចោទប្រកាន់លោកនោះឯង ។

## កំណាព្យមិត្តល្អនាំឲ្យផុតទុក្ខ

មិត្តល្អតែម្នាក់ជាក់ជាកល្យាណ គឺល្អជាងបានរាប់លានដុល្លារ
ល្អជាងមិត្តរយញយខាងឥស្សា តែសូមសត្តាសុខាសួស្តី ។
សមុទ្រទឹកប្រៃក្នុងន័យវដ្តៈ លោកាមិសៈអន្ទាក់លោកីយ៍
ព្រះពុទ្ធមួយអង្គស្រង់សត្វប្រុសស្រី ដាក់ទៅលើដីដល់ត្រើយសុខា ។
ទឹកសមុទ្រច្រើនម្ល៉ោះតែទាស់រសប្រៃ ទឹកសាបក្បង់ដៃល្មមល្មៃពិសា
ទ្រព្យច្រើនតែដូចមានខ្មោចរក្សា ទ្រព្យតិចតែថាប្រាថ្នាឲ្យទាន ។
ព្រះពុទ្ធមួយអង្គទ្រង់និព្វានទៅ ព្រះធម៌តាំងនៅតំណាងទ្រង់ញាណ
បរិស័ទរៀនធម៌ទ្រទ្រង់ធម្មទាន គាល់ព្រះទ្រង់ញាណសន្តានជ្រះថ្លា។
សទ្ធាជាមិត្តក្នុងចិត្តមានញាណ នាំឲ្យធ្វើទានមានទាំងសីលា
ភាវនាកម្មដ្ឋានបានវិបស្សនា បួសទ្រង់សិក្ខាសទ្ធាជាលាភ ។
ការក្រែងចិត្តជាសម្បត្តិមនុស្សល្អ មារយាទបវរវាចាសុភាព

កាយគាប់ដោយគុណទន់ភ្លន់រាបទាប មេត្តាជ្រួតជ្រាបចិត្តជ្រៅត្រជាក់ ។
ចាស់ទៅសោកសៅក្តៅក្តុកក្តួលចិត្ត ស្ងួតហែងមែនពិតព្រោះចិត្តនៅរាក់
សីលជួយមនុស្សចាស់ឲ្យចិត្តត្រជាក់ ជាទីពឹងពាក់បរលោកជោគជ័យ ។
គ្រប់គ្នាត្រូវការប្រាថ្នារកសុខ តែចិត្តស្មាញស្មុគអផ្សុកមោះមៃ
អប់រំមនោសារសមាធិប្រពៃ មេត្តាអភ័យប្រពៃទន់ភ្លន់ ។
ភារា ហវេ បញ្ចក្ខន្ធា ខន្ធប្រាំគ្រប់គ្នាជាភារៈធ្ងន់
អប់រំបញ្ញាកាប់ឆ្ការលោភលន់ ដាក់ចុះគ្រឿងធ្ងន់គន់ឃើញនិព្វាន៕

ដោយ **ម.ស.ម.**

# កំណាព្យចាញ់បួនយ៉ាង

ញញឹមស្រស់ពិតចាញ់ចិត្តភក្តី ផ្អែមល្ហែមសម្តីចាញ់ន័យខ្លឹមសារ
ពោលថាស្រឡាញ់ចាញ់ចិត្តមេត្តា សុខក្នុងស្នេហាចាញ់សុខដែលស្មោះ ៕

ដោយ **ម.ស.ម.**

# កំណាព្យកុំបីយ៉ាង

សង្សារប្រុសស្រីឬប្តីប្រពន្ធ កុំឲ្យគយគន់ធ្ងន់ចាប់កំហុស

កុំឲ្យលាក់លៀមត្រូវត្រៀមស្រួលស្រុះ   កុំស្មានក្រែងខុសខូចចិត្តអត់រឿង៕

ដោយ **ម.ស.ទ.**

## កំណាព្យលោកនេះមិនសម្រាប់ភ័យទេ គឺសម្រាប់យល់

បើគ្មានអ្នកណាស្នេហាស្រឡាញ់ មិនត្រូវគ្នាន់ក្នាញ់ចុះចាញ់វាស្មា
ឲ្យតែយើងចេះស្រឡាញ់អាត្មា ជិះយានកុសលាយាត្រាចាកទុក្ខ ។
មិនមានភ័យខ្លាចអ្វីៗក្នុងលោក មិនចាំបាច់សោកក្នុងរឿងគ្រប់មុខ
នេះព្រោះបានយល់ហេតុផលសុខទុក្ខ គឺរឿងគ្រប់មុខជារឿងត្រូវយល់ ។
កុំខឹងក្រោធតបទៅនឹងអ្នកណា រឿងក្នុងលោកាមានហេតុមានផល
អកុសលវិបាកកម្មចាស់បានផ្តល់ មេត្តាតទល់រំងាប់វេរា ។
មច្ចុញញឹមសង្ឃឹមប្រហារ មិនវៀរសត្តាប្រហារគ្រប់គ្នា
យល់ដឹងមិនខ្លាចអំណាចនៃមារ ញញឹមតបជាទទួលការពិត ។
ជីវិតកើតស្លាប់ចាប់យកសេចក្តី តើមានខាតអ្វីក្នុងន័យជីវិត
កើតមកទទេទៅទទេពិត ទុក្ខព្រោះតែគិតប្រកាន់ហួងហែង ។
មានទ្រព្យគ្រប់មុខទិញសុខមិនបាន មកពីសន្តានមិនបានកោតក្រែង
ការពិតក្នុងលោកព្រះពុទ្ធសម្តែង ខ្វះការកោតក្រែងគោរពសិក្សា ។
ជីវិតអត់គួមិនមែនអត់ថ្លៃ តម្លៃជីវិតពិតមានខ្លឹមសារ
សច្ចៈខន្តីកតញ្ញុតា ជីវិតថ្លៃថ្លាដោយសារគុណធម៌ ។

យើងថាគេថោកក៏យើងមិនថ្លៃ ថាគេចង្រៃក៏យើងមិនល្អ
